ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១




ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ

# របាយការណ៍

# ប្រចាំត្រីមាសទី៣ ឆ្នាំ២០២១

(គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)

# របស់កំពង់ផែស្វយ័តភ្នំពេញ

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងកម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា

### ១.១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

<table>
<tr><th colspan="2">បរិយាយ</th><th>៣០ កញ្ញា ឆ្នាំ២០២១</th><th>៣១ ធ្នូ ឆ្នាំ២០២០</th><th>៣១ ធ្នូ ឆ្នាំ២០១៩</th></tr>
<tr><td colspan="5">ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)</td></tr>
<tr><td colspan="2">ទ្រព្យសកម្មសរុប</td><td>៨៨៨ ២២៨ ៣៩៣</td><td>៨៣៦ ៣២០ ៧១០</td><td>៨១៧ ៥៨២ ៩៨៨</td></tr>
<tr><td colspan="2">បំណុលសរុប</td><td>១៩១ ២៦១ ៧២២</td><td>១៨៨ ១៥៤ ១៥៩</td><td>១៩៨ ៥៨០ ៩៥២</td></tr>
<tr><td colspan="2">មូលធនសរុប</td><td>៦៩២ ៩៦២ ៦៧១</td><td>៦៥២ ១៦៦ ៥៥១</td><td>៦១៩ ០០១ ៩៩៦</td></tr>
<tr><td colspan="2">លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)</td><td>ត្រីមាសទី៣ ឆ្នាំ២០២១</td><td>ត្រីមាសទី៣ ឆ្នាំ២០២០</td><td>ត្រីមាសទី៣ ឆ្នាំ២០១៩</td></tr>
<tr><td colspan="2">ចំណូលសរុប</td><td>៣៦ ៨៩៣ ៦៧៨</td><td>៣១ ០០២ ៦១៨</td><td>៣៣ ២០៦ ៣០១</td></tr>
<tr><td colspan="2">ចំណេញ/(ខាត) មុនបង់ពន្ធ</td><td>២០ ០៨២ ៧៦២</td><td>១៥ ៩៧៨ ១៧៩</td><td>១៧ ៧៥១ ៥៣៨</td></tr>
<tr><td colspan="2">ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ</td><td>១៥ ៩៨០ ៦៣០</td><td>១២ ៦២០ ៨៣៥</td><td>១៩ ០៧០ ៨២១</td></tr>
<tr><td colspan="2">លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ</td><td>១៥ ៧០៦ ០៩២</td><td>១២ ៧៨៦ ៩០៩</td><td>១៩ ០៨០ ៦៩៧</td></tr>
<tr><td colspan="2">អនុបាតហិរញ្ញវត្ថុ</td><td>ត្រីមាសទី៣ ឆ្នាំ២០២១</td><td>៣១ ធ្នូ ឆ្នាំ២០២០</td><td>៣១ ធ្នូ ឆ្នាំ២០១៩</td></tr>
<tr><td colspan="2">អនុបាតសាធនភាព (ភាគរយ)</td><td>១០,០៨</td><td>២៨,៨០</td><td>៣០,១៣</td></tr>
<tr><td rowspan="2">អនុបាត សន្ទនីយភាព</td><td>អនុបាតចរន្ត (ចំនួនដង)</td><td>៣,៧៦</td><td>៣,៨៦</td><td>៨,១៧</td></tr>
<tr><td>អនុបាតចរន្តលឿន (ចំនួនដង)</td><td>៣,៧៦</td><td>៣,៨៦</td><td>៨,១៧</td></tr>
<tr><td colspan="2"></td><td>ត្រីមាសទី៣ ឆ្នាំ២០២១</td><td>ត្រីមាសទី៣ ឆ្នាំ២០២០</td><td>ត្រីមាសទី៣ ឆ្នាំ២០១៩</td></tr>
<tr><td rowspan="3">អនុបាត ចំណេញភាព</td><td>អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ភាគរយ)</td><td>១,៧៨</td><td>១,៥៣</td><td>១,៧៥</td></tr>
<tr><td>អនុបាតចំណេញធៀបនឹងមូលធន(ភាគរយ)</td><td>២,២៧</td><td>១,៩៦</td><td>២,៣១</td></tr>
<tr><td>អនុបាតគម្លាតចំណេញដុល (ភាគរយ)</td><td>៧១,៨៥</td><td>៧២,៥៦</td><td>៦៩,៦៤</td></tr>
</table>

| | | | | |
|---|---|---|---|---|
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ៤២,៥៧ | ៤១,១២ | ៤២,៤០ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៧៥៩,៣២ | ៦១៦,២៦ | ៦៨០,៧៤ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ២៤,៣១ | ១៧,៨៧ | ១៨,០៩ |

## ១.២. ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប (គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)






## ការបែងចែកប្រភេទចំណូលធៀបនឹងចំណូលសរុបពី ផលអាជីវកម្ម និងសេវាកម្ម




## ប្រាក់ចំណេញសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ (ពាន់រៀល)



## ប្រាក់ចំណេញសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ធៀបនឹងផែនការ ឆ្នាំ២០២១ (ពាន់រៀល)




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ ធៀបនឹងផែនការឆ្នាំ២០២១ (ពាន់រៀល)



## ១.៣. កម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា (គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១)

| ភាគហ៊ុន | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព |
|---|---|---|
| **ភាគហ៊ុនប្រភេទ("គ")** | | |
| ១.រដ្ឋ តំណាងដោយ (ស.ហ.វ.) | **៩៣ ៧៦៩ ១២០** | **១០០%** |
| **ភាគហ៊ុនធម្មតា (ប្រភេទ "ខ")** | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | **១៦ ៥៤៧ ៥៩២** | **៨០%** |
| **ភាគហ៊ុនធម្មតា (ប្រភេទ "ក")** | | |
| ១. ESOP | ២៤២ ៧២៤ | ១,១៧% |
| ២. ភាគហ៊ុនិកឯកជន | ៣ ៨៩៤ ១៤៩ | ១៨,៨៣% |
| **សរុបភាគហ៊ុនធម្មតា(ប្រភេទ "ក")** | **៤ ១៣៦ ៨៧៣** | **២០%** |

** ភាគហ៊ុនធម្មតាសរុប (២០.៦៨៤.៣៦៥ភាគហ៊ុន)។*



**តម្លៃជួញដូរភាគហ៊ុនជាមធ្យម (គិតជារៀល) និងបរិមាណជួញដូរជាមធ្យម (ភាគហ៊ុន) នៃភាគហ៊ុនប្រភេទ "ក"**



## ២. សមាសភាពក្រុមប្រឹក្សាភិបាល



ឯកឧត្តម ហ៊ី បាវី
ប្រធានក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយក ក.ស.ក.



ឯកឧត្តម សួន រចនា
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



ឯកឧត្តម កែន សម្បត្តិ
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឯកឧត្តម ប៉ែន សុវិជាតិ
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម



លោក ហ្គី អានវ៉ានិថ
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ



លោក ឌិត សុចល
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន



លោក យឹម ធឿន
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងនិយោជិត ក.ស.ក.

## ៣. សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល

សម្រាប់ការអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានចំនួន ៣៦ ៨៩៣ ៦៧៨ ពាន់រៀល (៩ ០៦៣ ៥២៥ដុល្លារអាមេរិក) សម្រេចបាន ៣១,២៩% នៃការគ្រោងផែនការឆ្នាំ២០២១ បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០ កើនឡើងចំនួន ៥ ៨៩១ ០៦០ ពាន់រៀល (១ ៤៨៧ ៤៨០ ដុល្លារអាមេរិក) ឬស្មើនឹង ១៩,០០%។ ចំណែកប្រាក់ចំណេញសុទ្ធក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួនសរុប ១៥ ៩៨០ ៦៣០ពាន់រៀល (៣ ៩២៦ ១៩៨ដុល្លារអាមេរិក) សម្រេចបាន ៣៥,៣៣% នៃការគ្រោងផែនការឆ្នាំ២០២១ និងធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០ កើនឡើងចំនួន ៣ ៣៥៩ ៧៩៥ពាន់រៀល (៨៤១ ០១១ ដុល្លារអាមេរិក) ឬស្មើនឹង ២៦,៦២%។ សម្រាប់រយៈពេល៩ខែ ដើមឆ្នាំ២០២១ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានចំនួន ៩២ ៩៤៣ ៩៦៥ ពាន់រៀល (២២ ៨៥៨ ៦៩៨ ដុល្លារអាមេរិក) សម្រេចបាន ៧៨,៨៣% នៃការគ្រោងផែនការឆ្នាំ២០២១ និងធៀបនឹង៩ខែ ដើមឆ្នាំ២០២០ កើនឡើងចំនួន ៩ ៤៩៥ ១៨៧ ពាន់រៀល (២ ៤១៥ ៧១០ ដុល្លារអាមេរិក) ឬស្មើនឹង ១១,៣៨% ។ ចំណែកប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទសរុបចំនួន ៣៨ ៦០៨ ២៣៦ពាន់រៀល (៩ ៤៩៥ ៣៨៥ ដុល្លារអាមេរិក) សម្រេចបាន ៨៥,៣៦% នៃគ្រោងផែនការឆ្នាំ២០២១ និងធៀបនឹង៩ខែ ដើមឆ្នាំ២០២០ កើនឡើងចំនួន ៧ ៥៧៦ ៦០៧ ពាន់រៀល( ១ ៨៩៣ ៣២០ ដុល្លារអាមេរិក) ឬស្មើនឹង ២៤,៤២%។

ដោយឡែក ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី៣ ឆ្នាំ២០២១ (Basic Earnings Per Share) គឺចំនួន ៧៥៩,៣២រៀល (០,១៩ ដុល្លារអាមេរិក) ។

សមិទ្ធិផលខាងលើអាស្រ័យដោយ ក. ស. ភ. តែងប្រកាន់ភ្ជាប់នូវការយកចិត្តទុកដាក់ក្នុងការបម្រើសេវាកម្មប្រតិបត្តិការផែជូនអតិថិជនប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទំនុកចិត្តខ្ពស់ចំពោះតម្រូវការរបស់អតិថិជន។ ជាក់ស្តែង ក.ស.ភ. បានប្រើប្រាស់គ្រប់យន្តការតាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពលើកដាក់ និងផ្ទេរផ្ទុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការជួសជុលថែទាំ ការងារជលធារសាស្ត្រ និងការងារបំពាក់គ្រឿងចក្រ និងឧបករណ៍ថ្មីៗជាដើម។

### ក. ទិសដៅការងារអនុវត្តចម្បងរបស់ ក. ស. ភ.

- បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុក
- ធានាគុណភាព តម្លៃ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្តល់សេវាកម្មជូនអតិថិជន
- ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភ័ស្តុភារកម្ម
- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីឆ្លើយតបនឹងការវិវឌ្ឍរបស់អង្គភាពស្របទៅនឹងការផ្លាស់ប្តូរចរន្តភាវូបនីយកម្ម និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយបណ្តាកំពង់ផែក្នុងតំបន់ និងបណ្តាកំពង់ផែដទៃទៀតនៅលើពិភពលោក
- ខិតខំ និងបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដារ និងប្រព័ន្ធបច្ចេកវិទ្យា
- បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុង និងក្រៅប្រទេស
- បង្ខិតសេវាកម្មកំពង់ផែឱ្យកាន់តែខិតជិតអ្នកប្រើប្រាស់
- ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

## ខ. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ក. ស. ភ. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ១ លើក ដូចខាងក្រោម៖

*១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១១ អាណត្តិទី៧ នាថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ (តាមរយៈប្រព័ន្ធ online)*

- បានសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេល ៦ខែ ដើមឆ្នាំ២០២១ របស់ ក. ស. ភ.
- បានសម្រេចឱ្យ ក. ស. ភ. ពិនិត្យ និងកែសម្រួលឡើងវិញនូវ កិច្ចព្រមព្រៀងស្តីពីកិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង TS១១ រវាង ក. ស. ភ និងក្រុមហ៊ុន ភីធីអិលអេស ខូអបភើរេសិន (PTLS COOPERATION CO.,LTD) និងលើកសំណើសុំការពិនិត្យ និងសម្រេចឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើសំណើទៅក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីពិនិត្យ និងសម្រេចលើការកំណត់គោលការណ៍រួម សម្រាប់កិច្ចសហការវិនិយោគជាមួយឯកជនក្នុងការអភិវឌ្ឍចំណតផែរណបរបស់ ក. ស. ភ. នៅទន្លេបិទ, កោះរកា, ព្រែកអញ្ចាញ, ព្រែកក្តាម, ខេត្តកំពង់ឆ្នាំង និងនៅឆ្លងខេត្តក្រចេះ ព្រមទាំងទីតាំងសមស្របផ្សេងៗទៀតនាពេលអនាគត
- បានពិនិត្យ និងសម្រេចលើសំណើសុំពន្យារពេលសងប្រាក់ត្រលប់មក ក. ស. ភ. របស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប
- បានពិភាក្សា និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើសំណើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីកំណត់ឈ្មោះចំណតផែរណបរបស់ ក. ស. ភ. នៅកោះរកា ជា "ចំណតផែរណបពហុបំណងកោះរកា LM២៦" និងចំណតផែនៅក្អមសំណ ជា "ចំណតផែក្អមសំណ LM២៧"
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ផ្ទេរប៉ុងតុងចំនួន ១ គ្រឿង នៅចំណតផែបណ្តែត TS១ យកទៅដាក់នៅចំណតផែកោះរកា ដើម្បីបម្រើឱ្យប្រតិបត្តិការលើកដាក់ទំនិញ។

## គ. ការកំណត់ទិសដៅសម្រាប់ ឆ្នាំ២០២១

ទស្សនវិស័យទៅអនាគត ក. ស. ភ. នឹងកំណត់ទិសដៅសម្រាប់អនុវត្តរួមមាន៖

- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស
- បន្តជំរុញការបង្កើតមជ្ឈមណ្ឌលភ័ស្តុភារកម្ម ឃ្លាំងទំនើប និងឃ្លាំងត្រជាក់
- បន្តជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ
- បន្តជំរុញការបង្កើតសេវាកម្មដឹកជញ្ជូនតាមផ្លូវទឹក ទៅកាន់ផែមេដទៃ ក្រៅពីផែកៃម៉េប
- បន្តជំរុញការនាំចូលទំនិញដែលប្រើប្រាស់រួចមួយទឹក (ទំនិញជជុះ) តាមរយៈ ក. ស. ភ.
- បន្តយកចិត្តទុកដាក់លើការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ នៅចំណតផែកុងតឺន័រLM១៧
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញចាក់ធារ និងបង្កើតចំណតផែសម្រាប់ទំនិញចាក់ធារ
- អភិវឌ្ឍន៍ចំណតផែទេសចរណ៍អន្តរជាតិ (TS៣ និង TS១)
- បន្តជំរុញបង្កើតចំណតផែពហុបំណងតាមដងទន្លេបន្ថែមទៀត
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញកសិកម្ម តាមចំណតផែនៃបណ្តាខេត្តផ្នែកខាងលើនៃទន្លេមេគង្គ
- ថែទាំផ្លូវនាវាចរណ៍ និងធ្វើការបូមស្តារទីតាំងប្រឡាយស្តៅ សម្រួលការដឹកជញ្ជូនទំនិញ រវាងខេត្តនានានៅតាមភូមិភាគឦសាន មកភ្នំពេញតាមទន្លេមេគង្គ និងតាមព្រំប្រទល់កម្ពុជា-វៀតណាម

- បន្តជំរុញការផ្តល់សេវាកម្មដឹកជញ្ជូនកុងតឺន័ររវាងចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ. និងរោងចក្រ/ឃ្លាំងរបស់អតិថិជន ឬពីរោងចក្រ/ឃ្លាំងរបស់អតិថិជនទៅកាន់ចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ.
- បន្តជំរុញការផ្តល់សេវាកម្មជាកញ្ចប់សម្រាប់ការនាំចេញផ្លែឈើត្រជាក់តាមចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ.។

ក. ស. ភ. មានជំនឿចិត្ត និងគោលជំហរយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងប្រតិបត្តិការនៅតាមបណ្តាចំណតផែនានា ឱ្យមានតម្លាភាព ឱ្យមានភាពឆាប់រហ័ស ដើម្បីបង្កើននូវទំនុកចិត្ត និងការទាក់ទាញនៃការផ្តល់សេវាកម្មកំពង់ផែប្រកបដោយស្តង់ដារជូនដល់អតិថិជន។

ក. ស. ភ. សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលជានិច្ចជាកាលតែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ ក. ស. ភ. រៀងរហូតមក។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

PHNOM PENH AUTONOMOUS PORT

**ហ៊ី_ប្រាំ**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប

១-ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងកម្មសិទ្ធិភាពភាគហ៊ុនិកជម្មតា i

២-សមាសភាពក្រុមប្រឹក្សាភិបាល vii

៣-សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល viii

**ផ្នែកទី១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ១

ក-អត្តសញ្ញាណកំពង់ផែស្វយ័តភ្នំពេញ ២

ខ-លក្ខណៈនៃធុរកិច្ច ២

គ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ របស់កំពង់ផែស្វយ័តភ្នំពេញ ៩

**ផ្នែកទី២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ១០

ក-លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ១១

ខ-រចនាសម្ព័ន្ធចំណូល ១៧

**ផ្នែកទី៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ១៨

**ផ្នែកទី៤ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ៥៨

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ៥៩

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ៧០

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ៧២

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ៧២

ង-ផលប៉ះពាល់ពីអតិផរណា ៧៣

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ៧៣

**ផ្នែកទី៥ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន** ៧៥

**ហត្ថលេខាអភិបាលកំពង់ផែស្វយ័តភ្នំពេញ**

# ផ្នែកទី១
# ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

## ក. អត្តសញ្ញាណកំពង់ផែស្វយ័តភ្នំពេញ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ : **កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)**

ជាអក្សរឡាតាំង : **PHNOM PENH AUTONOMOUS PORT (PPAP)**

- អក្សរកូដ : **KH១០០០០៨០០០១**
- អាសយដ្ឋាន : **អគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
- លេខទូរស័ព្ទ : **+៨៥៥ (0) ២៣ ៨២៧ ៨០២** លេខទូរសារ : **+៨៥៥ (0) ២៣ ៨២៧ ៨០២**
- គេហទំព័រ : **www.ppap.com.kh** អ៊ីម៉ែល : **ppapmpwt@online.com.kh**
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : **CO.៧១៧៥ Et/២០០៤**
  កាលបរិច្ឆេទ : **២៣/វិច្ឆិកា/២០០៤**
- លេខអាជ្ញាបណ្ណអាជីវកម្ម : **០០១៤ ពណ.ចបព** **ចេញដោយ: ក្រសួងពាណិជ្ជកម្ម**
  កាលបរិច្ឆេទ : **០៥/មករា/២០១៥**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ : **០៧៤/១៥/គ.ម.ក./ស.ស.រ**
  ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ : **ឯកឧត្តម ហ៊ី បាវី**

## ខ. លក្ខណៈនៃធុរកិច្ច

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមផែអន្តរជាតិទាំងពីររបស់ប្រទេសកម្ពុជា ដែលបម្រើសេវានាំចូល នាំចេញកុងតឺន័រ និងទំនិញទូទៅ។ ដូចនេះ ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ ក. ស. ភ. កំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ដទៃទៀតដែលជាដំណើរការធុរកិច្ចរបស់ ក. ស. ភ.។

### *១. ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ*

ក្នុងនាមជាប្រតិបត្តិករផែ ក. ស. ភ. មានភារកិច្ចបម្រើសេវាសំខាន់ៗ រួមមាន ៖

- ផ្តល់សេវាលើកដាក់ទំនិញ ការស្តុកទំនិញ ការច្រកនិងរើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រ សម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស
- ផ្តល់សេវាកណ្ឌធារកិច្ច នាំនាវាចេញ-ចូល
- ផ្តល់សេវាចំណតផែអ្នកដំណើរ និងទេសចរ
- សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា។

### *២. ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ*

ក្នុងនាមជាអាជ្ញាធរផែ ក. ស. ភ. មានតួនាទី៖

- ថែទាំផ្លូវនាវាចរណ៍ បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញាសម្គាល់ទិសនាវាចរណ៍ រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ
- ចាត់វិធានការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

## ៣. សេវាកម្ម/អាជីវកម្ម ផ្សេងទៀត

ជាមួយនឹងការផ្តល់សេវាកម្មស្នូលលើការងារប្រតិបត្តិការផែ និងអាជ្ញាធរផែ ក. ស. ភ. ក៏មានសេវាកម្ម/អាជីវកម្មបន្ទាប់បន្សំផ្សេងទៀត ដែលអាចបង្កើតឲ្យមានចំណូលបន្ថែមដូចជា៖

- សេវាកម្មបូមស្តារ៖ ក. ស. ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្តារចំនួន ២គ្រឿង សម្រាប់ផ្តល់សេវាកម្មបូមស្តារដើម្បីចាក់បំពេញខ្សាច់ជូនដល់អតិថិជន
- សេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់៖ ក. ស. ភ. ទទួលបានអាជ្ញាបណ្ណបូមស្តារប្រឡាយនាវាចរណ៍ និងធ្វើអាជីវកម្មខ្សាច់នៅទីតាំងចំនួន ២ ដោយអនុលោមតាមប្រកាសលេខ ០១ និង០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល
- សេវាកម្មវាស់ស្ទង់ និងបំពាក់ពោង៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មវាស់ស្ទង់ និងបំពាក់ ពោងតាមតម្រូវការរបស់អតិថិជន
- សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រ៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រគ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជន
- ការជួលអចលនទ្រព្យ និងគ្រឿងចក្រផ្សេងៗ៖ ក្រៅពីការប្រើប្រាស់អចលនទ្រព្យ និងគ្រឿងចក្រសម្រាប់បម្រើឲ្យការងារអាជីវកម្ម និងប្រតិបត្តិការ អចលនទ្រព្យ និងគ្រឿងចក្រទាំងនោះក៏ត្រូវបានប្រើប្រាស់ និងចាត់ចែងសម្រាប់ការជួល ដើម្បីបង្កើនចំណូលបន្ថែមជូនដល់ ក. ស. ភ. ផងដែរ។

## ៤. មណ្ឌលអាជីវកម្មផែ

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ មណ្ឌលអាជីវកម្មរបស់ ក. ស. ភ. មានប្រវែង ១៦៦គីឡូម៉ែត្រ គិតចាប់ពីទន្លេបួនមុខ៖ ទន្លេមេគង្គលើ ១០០គីឡូម៉ែត្រ ទន្លេមេគង្គ ក្រោម ៦០គីឡូម៉ែត្រ និងទន្លេសាប ៦គីឡូម៉ែត្រ។ ក្នុងនាមអាជ្ញាធរ ក. ស. ភ. មានតួនាទីគ្រប់គ្រងចំណតផែឯកជននានា នៅក្នុងមណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក. ស. ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បងចំនួន ៦ រួមមាន៖

### ៤.១. ចំណតផែដែលកំពុងប្រតិបត្តិការ

#### ៤.១.១ ចំណតផែកុងតឺន័រ LM១៧

ត្រឹមរយៈពេល៩ខែ ដើមឆ្នាំ២០២១ ក. ស. ភ. បានបញ្ចប់គម្រោងពង្រីកទីលានផ្ទុកកុងតឺន័រ ជំហានទី៣ ដំណាក់កាលទី១ គម្រោងសាងសង់ស្ពានផែសម្រាប់ដំឡើងដងយោង FCC ចំនួន ២គ្រឿង និងការងារ

តបណ្តាញអគ្គីនីដើម្បីផ្គត់ផ្គង់ទីលានផ្ទុកកុងតឺន័រជំហានទី៣ ខាងលើ។ សម្រាប់ជំហានទី៣ទាំងមូលអាចពង្រីកសមត្ថភាពលើកដាក់កុងតឺន័របាន ២០០.០០០ TEUs ក្នុងមួយឆ្នាំបន្ថែមទៀត។ ដូចនេះបន្ទាប់ពីការសាងសង់គម្រោងខាងលើត្រូវបានបញ្ចប់ ចំណតផែកុងតឺន័រLM១៧ មានសមត្ថភាពលើកដាក់កុងតឺន័របានរហូតដល់ ៥០០.០០០ TEUs ក្នុងមួយឆ្នាំ។ ចំណតផែកុងតឺន័រLM១៧ បច្ចុប្បន្នមានស្ពានផែ ដែលមានបណ្តោយប្រវែង ៣០០ម៉ែត្រ ទទឹង ២២ម៉ែត្រ និងបំពាក់ដោយដងយោង TCC ចំនួន ៤គ្រឿង រថស្ទូច RTG ចំនួន ១២គ្រឿង និងគ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Constacker) ចំនួន ៥គ្រឿង (Sky Stacker) ចំនួន ៤គ្រឿង និងរថយន្ត ៥៩គ្រឿងបាននិងកំពុងបំពេញការងារប្រតិបត្តិការ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងលិច ចម្ងាយ ២៥គីឡូម៉ែត្រពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°២៨'២៣.៦" និងរយៈបណ្តោយខាងកើត ១០៥°០៨'៤៩.៨" |
| **ទំហំផ្ទៃដីសរុប** | ៣៧៩.១៧៣ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដី ចុះបញ្ជី** | ៣៧៨.៣៦៧ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីកំពុងធ្វើប្លង់កម្មសិទ្ធិ** | ៨០៦ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងបោះយុថ្កា របស់ចំណតផែកុងតឺន័រ LM១៧ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°២៨'២៨.១៤" និងរយៈបណ្តោយខាងកើត ១០៥°៩'២.៣២" ចន្លោះជម្រៅទឹកពី ៨ម៉ែត្រ ទៅ ១៧ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ហើយចរន្តទឹកមានកម្លាំងខ្លាំងនៅរដូវវស្សា |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០.២០ម៉ែត្រ ដល់ ០.៤៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤.៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥.៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែកុងតឺន័រ LM១៧ អាស្រ័យជម្រៅទឹក នៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោង (Traveling Cargo Crane) រថស្ទូច (Rubber Tyred Gantry) គ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker Constacker & Sky Stacker) |

### ៤.១.២. ចំណតផែពហុបំណង TS៣

ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក. ស. ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ ចាប់តាំងពីចំណតផែកុងតឺន័រ LM១៧ ត្រូវបានស្ថាបនារួចរាល់ ចំណតផែពហុបំណង TS៣ ត្រូវបានក្លាយទៅជាចំណតផែពហុបំណង សម្រាប់បម្រើការលើកដាក់ទំនិញរាយ កុងតឺន័រ និងប្រើជាចំណតផែអ្នកដំណើរ និងទេសចរ។ បច្ចុប្បន្ន ក.ស.ភ. បាននិងកំពុង រៀបចំកែប្រែចំណតផែនេះ ឱ្យក្លាយទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិ។

| | |
|---|---|
| **អាសយដ្ឋាន** | អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេសាប ត្រើយខាងលិច ចម្ងាយ ៣,២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៣៤'៥៩,៦៨" និងរយៈបណ្តោយខាងកើត ១០៤°៥៥' ១៧,៤១" |
| **ទំហំផ្ទៃដីសរុប** | ៤៨.៤៣៨.៧៦ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីចុះបញ្ជី*** | ៣២.៨៥៤ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅទន្លេសាបខាងមុខចំណតផែ និងមួយកន្លែងទៀតនៅទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹង ខាងជើង ១១°៣៣' ៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៤°៥៦'៣៤,៥៧" មានជម្រៅទឹកពី ៥ម៉ែត្រ ទៅ១៥ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ដែលអាចបោះយុថ្កាជាប់បានល្អ |
| **រលក** | ផលប៉ះពាល់ មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១០ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែពហុបំណង៣ អាស្រ័យលើជម្រៅទឹក នៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane និង Crawler crane) ដងយោងបណ្តែត (Floating crane) |

*<u>សម្គាល់៖</u> *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### *៤.១.៣ ចំណតផែរណបពហុបំណងទន្លេបិទ UM២*

ក.ស.ភ. បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ជាមួយក្រុមហ៊ុន *មៀង លីហេង អ៊ិនវេសមិន* ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍចំណតផែពហុបំណងទន្លេបិទ UM២។ កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេល ២០ឆ្នាំ គិតចាប់ពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០៣២។ យោងតាមកិច្ចព្រមព្រៀងនេះ ក. ស. ភ. ទទួលខុសត្រូវលើសេវាកម្មលើកដាក់ក្រោមដងយោង រីឯដៃគូឯកជនទទួលខុសត្រូវលើការផ្តល់សេវាកម្មស្តុកទំនិញ។ ចំណូលពីថ្លៃឈ្នួលទាំងនេះ ត្រូវគិតដាច់ដោយឡែកពីគ្នា ផ្អែកលើប្រភេទសេវាកម្ម ដែលផ្តល់ដោយភាគីនីមួយៗ។គោលបំណងសំខាន់ក្នុងការបង្កើតចំណតផែនេះ គឺដើម្បីធ្វើជាកន្លែងប្រមូលផ្តុំកសិផល និងលើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក។ បច្ចុប្បន្ន ដំឡូងមីជាប្រភេទផលិតផលសំខាន់ ដែលត្រូវបាននាំចេញតាមចំណតផែនេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទីតាំងចំណតផែ** | ចំណតផែទន្លេបិទUM២ ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៥៧'៤៧,៧៣" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៣៣,១៣" |
| **ទំហំផ្ទៃដី** | ទំហំតូច ចំណតនៅតាមច្រាំងទន្លេប្រវែង ១០០ម៉ែត្រ (ដោយមានបំពាក់ប៉ង់តុងដងយោងចល័ត និងកុងវ៉ូយ័រ) |
| **ចំណតនាវា** | ចំនួន ១ (ប៉ង់តុងបណ្តែតទំហំ ១៥ម៉ែត្រ x ៤២ម៉ែត្រ) |
| **ទីតាំងបោះយុថ្កា** | ទីតាំង ដែលអាចបោះយុថ្កានៅចំណតផែទន្លេបិទ UM២ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៥៨'៤៣,៤១" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៩,៥៨" ក្នុងចន្លោះជម្រៅទឹកពី ៦ម៉ែត្រ ទៅ ២០ម៉ែត្រ។ នារដូវវស្សា នៅបាតទន្លេមានដីភក់ និងខ្សាច់ ហើយមានចរន្តទឹកមានកម្លាំងខ្លាំង។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែទន្លេបិទ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីរ) |
| **ជម្រៅទឹកផ្លូវនាវាចរ** | ចាប់ពីទន្លេចតុមុខទៅដល់ខេត្តត្បូងឃ្មុំ តាមប្រឡាយស្តៅមានទទឹង៦០ម៉ែត្រ និងបណ្តោយ ៣៥០០ម៉ែត្រ។ ជម្រៅទឹក មានជម្រៅ ៥ម៉ែត្រ ក្នុងរដូវប្រាំង (ដោយមានការថែទាំទៀងទាត់) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និងកុងវ៉ូយ័រ (Conveyer) |

### ៤.១.៤. ចំណតអ្នកដំណើរ និងទេសចរ TS១

ចំណតផែអ្នកដំណើរ និងទេសចរ TS១ ជាចំណតផែអ្នកដំណើរចម្បងរបស់ ក. ស. ភ.។ ចំណតផែនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើជាចំណតផែអ្នកដំណើរក្នុងស្រុក ក៏ដូចជាទៅកំពង់ផែនៃប្រទេសវៀតណាម។ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ចំនួនអ្នកដំណើរឆ្លងកាត់ចំណតផែអ្នកដំណើរ និងទេសចរ TS១ មានចំនួន ៧ ៦៥៥ នាក់។ តួលេខនេះ រាប់បញ្ចូលទាំងអ្នកដំណើរ ពីភ្នំពេញទៅចំណតផែក្នុងស្រុកនានា ពីភ្នំពេញទៅប្រទេសវៀតណាម ព្រមទាំងអ្នកទេសចរ ដែលធ្វើដំណើរឆ្លងកាត់តាមដងទន្លេមេគង្គ ក្បែររាជធានីភ្នំពេញ។

| | |
|---|---|
| **អាសយដ្ឋាន** | វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតអ្នកដំណើរ និងទេសចរ TS១ ស្ថិតនៅតាមដងទន្លេសាបត្រើយខាងលិចចម្ងាយ ២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងរយៈទទឹងខាងជើង ១១°៣៤'៣២,៤៥" និងរយៈបណ្តោយខាងកើត ១០៤°៥៥'៣៦,៨៤។ |
| **ទំហំផ្ទៃដីសរុប** | ៦.៦៧៦ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីចុះបញ្ជី*** | ១.៦៩៩ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មានប៉ង់តុងចំនួន ២គ្រឿង |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាននៅខាងមុខចំណតផែតំបន់ទន្លេសាប និង មួយទីតាំងទៀតនៅតំបន់ទន្លេចតុមុខ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៤°៥៦'២៤,៥៧" ចន្លោះជម្រៅទឹកពី ៥ម៉ែត្រទៅ ១៥ម៉ែត្រ។ នារដូវវស្សា បាតទន្លេមានដីភក់ និងខ្សាច់ ដែលជាផ្ទៃមានកម្លាំងទប់ជាប់ល្អ ហើយជម្រើសទីតាំងទី២ ដើម្បីបោះយុថ្កាមានចរន្តទឹកខ្លាំង។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹក** | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតផែពហុបំណង TS៣ គឺអាស្រ័យទៅលើជម្រៅស៊ីទឹក នៅច្រកគូទីរ) |
| **ប្រតិបត្តិការ** | ២៤ម៉ោង/ថ្ងៃ |
| **គ្រឿងចក្រលើកដាក់** | មានប៉ង់តុងចំនួន ២គ្រឿង ដោយមានស្ពានតភ្ជាប់ទៅច្រាំងទន្លេ |

*<u>សម្គាល់៖</u> *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

## ៤.២ ចំណតផែដែលគ្រោងអភិវឌ្ឍន៍នាពេលអនាគត

### ៤.២.១ ចំណតផែរណបពហុបំណង TS១១ (KM៦)

ចំណតផែរណបពហុបំណងTS១១ មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានចម្ងាយប្រហែល៦,៦គីឡូម៉ែត្រ ឬរយៈពេល ២០នាទី បើគិតពីចំណុចវត្តភ្នំទៅចំណតនេះ។ ចំណតផែនេះ គឺជាទីតាំងយុទ្ធសាស្ត្រសំខាន់បំផុតសម្រាប់ជាទីតាំងចែកចាយ និងប្រមូលផ្តុំទំនិញរវាង អ្នកផលិតនិងអ្នកប្រើប្រាស់យ៉ាងសំខាន់ក្នុងតំបន់ ដោយហេតុថា

ទីតាំងនេះស្ថិតនៅជៀកនឹង ទីប្រជុំជន ក្នុងរាជធានីភ្នំពេញ។ ការអភិវឌ្ឍចំណតផែនេះ នឹងសម្រួលដល់កកស្ទះនៃការដឹកជញ្ជូនផ្លូវគោក ចេញចូលទីប្រជុំជន។ ម្យ៉ាងវិញទៀត ចំណតផែពហុបំណងTS៣ មិនអាចធ្វើប្រតិបត្តិការឱ្យអស់លទ្ធភាពបានឡើយ ដោយហេតុថាទីតាំងនេះស្ថិតនៅចំកណ្តាល រាជធានីភ្នំពេញ ដែលសាលាក្រុងរាជធានីភ្នំពេញ មិនអនុញ្ញាត ឱ្យរថយន្តធុនធ្ងន់ធ្វើចរាចរនៅពេលថ្ងៃបានឡើយ។ ដូចនេះ ដើម្បីជំរុញឱ្យមានការដឹកជញ្ជូនតាមផ្លូវទឹក ក៏ដូចជាសេវាកម្ម Door to Door Service ការអភិវឌ្ឍចំណតផែពហុបំណងTS១១ ពិតជាសំខាន់ និង ចាំបាច់បំផុតក្នុងការតភ្ជាប់ទំនិញពីបណ្តាខេត្តផ្សេងៗឱ្យមានជម្រើសនិងមានតម្លៃកាន់តែទាប។

| | |
|---|---|
| **អាសយដ្ឋាន** | ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតផែពហុបំណងTS១១ ស្ថិតនៅតាមដងទន្លេសាប ចម្ងាយប្រហែល ៦ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១° ៣៧'៣៤,៦" និងរយៈបណ្តោយខាងកើត ១០៤°៥៥' ២៩,៤" |
| **ទីតាំងបោះយុថ្កា** | ទីតាំងដែលអាចបោះយុថ្កានៅចំណតផែពហុបំណងTS១១ មាន២ទីតាំង<br>-ទីតាំងទី១៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៣៤'២៦,៦" និងរយៈបណ្តោយខាងកើត ១០៤°៥៥'៥០,៤"<br>-ទីតាំងទី២៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៣៣'៣៩,៩" និងរយៈបណ្តោយខាងកើត ១០៤°៥៦'៥០,៧"<br>ស្ថិតនៅតំបន់ទន្លេចតុមុខពីព្រោះ ស្ថានភាពទន្លេនៅតំបន់ចំណតផែរណបពហុបំណងTS១១ មានសភាពតូចចង្អៀតពិបាកអោយនាវាបោះយុថ្ការង់ចាំ។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) |

### *៤.៦. ចំណតផែរណបពហុបំណងកោះរកា*

ចំណតផែរណបពហុបំណងកោះរកា មានទីតាំងស្ថិននៅឃុំកោះរកា ស្រុកពាមជរ នៃខេត្តព្រៃវែង ផ្នែកខាងត្បូងនៃប្រទេសកម្ពុជា និងមានចំងាយប្រមាណត្រឹមតែជាង៣គីឡូម៉ែត្រប៉ុណ្ណោះពីព្រំដែនខេត្តដុងថាប់ ប្រទេសវៀតណាម។ ចំណតផែនេះជាទីតាំងដែលមានសក្តានុពលសម្រាប់ប្រជាជនកម្ពុជាក្នុងការដឹកជញ្ជូនទំនិញកសិផលចេញទៅប្រទេសវៀតណាម និងនាំចូលមកវិញនូវទំនិញវត្ថុធាតុដើម និងទំនិញជាគ្រឿងសំណង់។ មិនតែប៉ុណ្ណោះចំណតផែនេះ នឹងតភ្ជាប់វិស័យទេសចរណ៍តាមបណ្តាខេត្តជិតខាងរវាងប្រទេសទាំងពីរ ប៉ុន្តែបច្ចុប្បន្ន កំពង់ផែមួយនេះទើបតែបានចាប់ផ្តើមធ្វើការអភិវឌ្ឍចាក់ខ្សាច់បំពេញទីលាន ដោយពុំទាន់បំពាក់គ្រឿងចក្រ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធផែឱ្យបានសមស្របនៅឡើយ។ ដូចនេះ ការពន្លឿនការអភិវឌ្ឍចំណតផែកោះរកា នឹងឆ្លើយតបទៅនឹងតម្រូវការនៃលំហូរទំនិញចេញចូលរបស់ប្រទេសទាំងពីរ និងការតភ្ជាប់ការដឹកជញ្ជូនតាមផ្លូវទឹក សម្រាប់ធ្វើការនាំចេញទៅកាន់ទីផ្សារសកលលោកឱ្យកាន់តែមានប្រសិទ្ធិភាព ក៏ដូចជាចូលរួមចំណែកកាត់បន្ថយការចំណាយភស្តុភារកម្ម និងការប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគោក។ នៅពេលបច្ចុប្បន្ន ចំណតផែពហុបំណងកោះរកាបានបញ្ចប់ការសាងសង់

ទីលានរួចហើយ ដែលគ្រោងដាក់ឲ្យប្រើប្រាស់សម្រាប់ប្រតិបត្តិការលើកដាក់ទំនិញរាយជាបណ្តើរៗសិនរហូតដល់មានការលើកដាក់ទំនិញជាកុងតឺន័រនៅជំហានបន្ទាប់។

ក.ស.ភ. បាននិងកំពុងសាងសង់ Conveyor ចំនួន ៣គ្រឿង ដើម្បីសម្រួលលំហូរប្រតិបត្តិការ ក្នុងការនាំចេញទំនិញកសិផល ដែលគ្រោងនឹងដាក់ឲ្យអនុវត្តជាជំហានៗនៅចុងឆ្នាំ២០២១ នេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ឃុំកោះរកា ស្រុកពាមជរ នៃខេត្តព្រៃវែង |
| **ទីតាំងចំណតផែ** | ចំណតផែរណបពហុបំណងកោះរកាស្ថិតនៅតាមដងទន្លេមេគង្គក្រោម ត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១០°៥៥'៤០,៥" និងរយៈបណ្តោយខាងកើត ១០៥° ១១' ៣០,៦" |
| **ទំហំផ្ទៃដី** | ១១៥.៥៦០ ម៉ែត្រការ៉េ |
| **ទំហំដីចុះបញ្ជី** | ១០៥.១៩២ ម៉ែត្រការ៉េ |
| **ទំហំដីកំពុងធ្វើប្លង់កម្មសិទ្ធ** | ១០.៣៨៦ ម៉ែត្រការ៉េ |
| **ទីតាំងបោះយុថ្កា** | ទីតាំងដែលអាចបោះយុថ្កានៅចំណតផែពហុបំណងTS១១ មាន២ទីតាំង<br>-ទីតាំងទី១៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១០°៥៦'០១,៩" និងរយៈបណ្តោយខាងកើត ១០៥°១១'១៧,៦"<br>-ទីតាំងទី២៖ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១០°៥៥'១០,១" និងរយៈបណ្តោយខាងកើត ១០៥°១១'២៤,៥" |
| **រលក** | មិនមានផលប៉ះពាល់ |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និងកុងវ៉ូយ័រ (Conveyer) |

## គ- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ក. ស. ភ. ពុំមានការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចនោះទេ។

# ផ្នែកទី២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាម

### ១. តារាងស្ថិតិបរិមាណទំនិញ និងនាវាឆ្លងកាត់ ក.ស.ក.

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០២១ | អនុវត្តត្រីមាសទី៣ | | | អនុវត្ត៩ខែ | | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | | | |
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧=(៥/១) | ៨=(២/៣)-១០០% | ៩=(៣/៤)-១០០% |
| I | បរិមាណទំនិញ និង ប្រេងឥន្ធនៈឆ្លងកាត់ | តោន | ៤ ០៥៦ ០១៤ | ៩៧៧ ៩៤៤ | ១ ០០០ ៨០៤ | ៩៩០ ៧៦៨ | ២ ៩១៥ ៨៧៤ | ២ ៧៩៧ ៩៤៤ | ៧១.៨៩% | -២.២៨% | +១.០១% |
| | **ក. បរិមាណទំនិញឆ្លងកាត់** | - | ២ ៣០៤ ៩៤០ | ៦១៤ ០១៤ | ៥៦៧ ៦០៤ | ៦៣៥ ៩០៨ | ១ ៥៧២ ៣១៨ | ១ ៥៤៤ ៩៧៧ | ៦៨.២៣% | +៨.១៨% | -១០.៦៧% |
| | - ទំនិញនាំចូល | - | ១ ៤៩៧ ៨៨៦ | ៣៦៥ ៩៧០ | ៣៧៧ ២៥៤ | ៤២៣ ៧០៣ | ៩២៨ ៥៩៩ | ១ ០៣៧ ៣០០ | | | |
| | - ទំនិញនាំចេញ | - | ៨០៦ ៥៥៤ | ២៤៨ ០៤៤ | ១៩០ ៣៤៩ | ២១១ ៧០៦ | ៦៤៣ ៧២០ | ៥០៧ ១៧៦ | | | |
| | **ខ. បរិមាណទំនិញលើកដាក់ចល័ត** | - | ៨៨៥ ៨៦៨ | ១៧៨ ២៨៨ | ២២៨ ៣០៥ | ១៥៥ ៩០៤ | ៦៣៩ ០៨៤ | ៦០៨ ៥៩២ | ៧២.១៤% | -២១.៩១% | +៤៦.៩១% |
| | - ទំនិញលើកដាក់ក្នុងផៃ | - | ៧០ ៨៦៩ | ៧ ៩១៨ | ១៣ ៣៥៦ | ១៦ ៥២៦ | ៣៨ ១៦៩ | ៣២ ៧២២ | | | |
| | - ទំនិញលើកដាក់ក្រៅផៃ | - | ៨១៤ ៩៩៩ | ១៧០ ៣៦៩ | ២១៤ ៩៤៩ | ១៣៨ ៨៧៨ | ៦០០ ៩១៥ | ៥៧៥ ៨៧០ | | | |
| | គ.បរិមាណប្រេងឥន្ធនៈ និងហ្គាសឆ្លងកាត់ | - | ៨៦៥ ៧០៦ | ១៨៥ ៦៤៣ | ២០៤ ៨៩៥ | ១៩៩ ៩៥៦ | ៧០៤ ៤៧១ | ៦៤៤ ៣៧៥ | ៨១.៣៨% | -៩.៤០% | +២.៤៧% |
| | បរិមាណកុងតឺន័រឆ្លងកាត់ | TEU | ៣២១ ០៦៦ | ១០៩ ១២៤ | ៨៥ ៦៨១ | ៩២ ៨៩៤ | ២៥៦ ៤០៧ | ២២១ ២៨២ | ៧៩.៨៦% | +២៧.៣៦% | -៧.៣៧% |
| | -មានទំនិញ | - | ២៣៤ ៣៧៨ | ៦៩ ២៤៣ | ៥៨ ៩៩២ | ៦៦ ០៨៧ | ១៧៨ ៩៦៣ | ១៥៨ ៥៣៧ | | | |
| | -គ្មានទំនិញ | - | ៨៦ ៦៨៨ | ៣៩ ៨៨១ | ២៦ ៦៨៩ | ២៦ ៨០៧ | ៧៧ ៤៤៤ | ៦២ ៧៤៥ | | | |
| II | បរិមាណទំនិញលើកដាក់ | តោន | ៣ ១៩០ ៣០៨ | ៧៩២ ៣០២ | ៧៩៥ ៩០៨ | ៧៩០ ៨១២ | ២ ២១១ ៤០២ | ២ ១៥៣ ០៦៩ | ៦៩.៣២% | -០.៤៥% | +០.៦៤% |
| | -ប្រគល់ផ្ទាល់ | - | ៨៨៥ ៨៦៨ | ១៧៨ ២៨៨ | ២២៨ ៣០៥ | ១៥៥ ៩០៤ | ៦៣៩ ០៨៤ | ៦០៨ ៥៩២ | | | |
| | -ឆ្លងកាត់ឃ្លាំង - ទីលាន | - | ២ ៣០៤ ៩៤០ | ៦១៤ ០១៤ | ៥៦៧ ៦០៤ | ៦៣៥ ៩០៨ | ១ ៥៧២ ៣១៨ | ១ ៥៤៤ ៩៧៧ | | | |

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០២១ | អនុវត្តត្រីមាសទី៣ | | | អនុវត្ត៩ខែ | | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | | | |
| *ក* | *ខ* | *គ* | *១* | *២* | *៣* | *៤* | *៥* | *៦* | *៧=(៥/១)* | *៨=(២/៣)-១០០%* | *៩=(៣/៤)-១០០%* |
| III | **បរិមាណនាវាសរុប** | គ្រឿង | **២ ៤០៩** | **៦០០** | **៦២៣** | **៦២៥** | **១ ៧៤៤** | **១ ៧៥៨** | ៧២.៤០% | -៣.៦៩% | -០.៣២% |
| | -នាវា-សាឡង់បណ្តាប្រទេសផ្សេងៗ | - | ១ ៨០២ | ៤៩១ | ៤៩៧ | ៤៩០ | ១ ៣៣២ | ១ ៣៤៦ | | | |
| | -នាវា-សាឡង់កម្ពុជា | - | ១០ | - | - | ៣ | - | - | | | |
| | -នាវា-សាឡង់ប្រេងឥន្ធនៈ | - | ៥៩៧ | ១០៩ | ១២៦ | ១៣២ | ៤១២ | ៤១២ | | | |
| IV | **បរិមាណនាវាអ្នកដំណើរទេសចរក្នុងស្រុក (ចេញ-ចូល)** | ជើង | **១ ៨៩៨** | **១ ៩៣៨** | **៤៥៦** | **៤២៦** | **២ ៧១៤** | **១ ៣៥២** | ១៤២.៩៩% | +៣២៥.០០% | +៧.០៤% |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ១០ | - | - | - | - | - | | | |
| | - នាវាទេសចរណ៍ក្នុងក្រុង | - | ១ ៨៨៨ | ១ ៩៣៨ | ៤៥៦ | ៤២៦ | ២ ៧១៤ | ១ ៣៥២ | | | |
| V | **បរិមាណអ្នកដំណើរ និងទេសចរក្នុងស្រុក (ចេញ-ចូល)** | នាក់ | **១០ ៥០៨** | **៧ ៦៥៥** | **៣ ៣៤៧** | **២ ៣៦១** | **១៤ ៧០៣** | **៦ ៩៧៩** | ១៣៩.៩២% | ១២៨.៧១% | +៤១.៧៦% |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ២០០ | - | - | - | - | - | | | |
| | - ទេសចរណ៍ក្នុងក្រុង | - | ១០.៣០៨ | ៧.៦៥៥ | ៣.៣៤៧ | ២.៣៦១ | ១៤.៧០៣ | ៦.៩៧៩ | | | |
| VI | **បរិមាណនាវាអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់កម្ពុជា-វៀតណាម** | ជើង | **៨៤០** | **-** | **-** | **៥៤៣** | **-** | **៦៩២** | 0.00% | 0.00% | -១០០.០០% |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ២៦៤ | - | - | ៣៧៤ | - | ៤៤០ | | | |

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០២១ | អនុវត្តត្រីមាសទី៣ | | | អនុវត្ត៩ខែ | | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | ឆ្នាំ២០២១ | ឆ្នាំ២០២០ | | | |
| *ក* | *ខ* | *គ* | *១* | *២* | *៣* | *៤* | *៥* | *៦* | *៧=(៥/១)* | *៨=(២/៣)-១០០%* | *៩=(៣/៤)-១០០%* |
| | - ចំនួននាវាទេសចរណ៍ | - | ១៧៦ | - | - | ១៦៩ | - | ២៥២ | 0.00% | 0.00% | -១០០.00% |
| VII | <u>បរិមាណអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់កម្ពុជា-វៀតណាម</u> | <u>នាក់</u> | <u>១៤ ៦៦៧</u> | <u>-</u> | <u>-</u> | <u>៩ ៧៧២</u> | <u>-</u> | <u>១៨ ៣៣៤</u> | 0.00% | 0.00% | -១០០.00% |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៦ ៨៨១ | - | - | ៤ ០៨៧ | - | ៨ ៦០១ | | | |
| | - ចំនួនភ្ញៀវទេសចរណ៍ | - | ៧ ៧៨៦ | - | - | ៥ ៦៨៥ | - | ៩ ៧៣៣ | 0.00% | 0.00% | -១០០.00% |

*<u>(ប្រភពៈនាយកដ្ឋានផែនការ/ទីផ្សារ)</u>*

- បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់ ក. ស. ភ. ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ៩៧៧ ៩៤៤ តោន ថយចុះ -២,២៨% ធៀបនឹងការអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២០ (១ ០០០ ៨០៤ តោន) សម្រាប់៩ខែ ដើមឆ្នាំ២០២១ នេះ ក. ស. ភ. សម្រេចបាន ៧១,៨៩% ធៀបនឹងផែនការ ឆ្នាំ២០២១ (៤០៥៦ ០១៤ តោន)។
- នាវាឆ្លងកាត់ ក. ស. ភ. ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ៦០០គ្រឿង ថយចុះ ៣.៦៩% ធៀបនឹងការអនុវត្តក្នុង ត្រីមាសទី៣ ឆ្នាំ២០២០ (៦២៣ គ្រឿង) សម្រាប់៩ខែដើមឆ្នាំ២០២១ ក. ស. ភ. សម្រេចបាន ៧២.៤០% ធៀបនឹងផែនការ ឆ្នាំ២០២១ (២ ៨០៩ គ្រឿង)។
- នាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ពុំមាន ចំនួនជើង ស្មើនឹង ០,០០% ធៀបនឹងការអនុវត្តត្រីមាសទី៣ ឆ្នាំ២០២០ (០ជើង) សម្រាប់៩ខែដើមឆ្នាំ២០២១ នេះ ក. ស. ភ. សម្រេចបាន ០,០០% ធៀបនឹងផែនការឆ្នាំ២០២១ (៤៤០ ជើង)។
- បរិមាណកុងតឺន័រក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ១០៩.១២៤ TEUs កើនឡើង ២៧.៣៦% ធៀបនឹងការអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០២០ (៨៥ ៦៨១ TEUs) សម្រាប់៩ខែដើមឆ្នាំ២០២១ នេះ ក. ស. ភ. សម្រេចបាន ៧៩.៨៦% ធៀបនឹងផែនការឆ្នាំ២០២១ (៣២១ ០៦៦ TEUs)។

- បរិមាណអ្នកដំណើរ និងទេសចរឆ្លងកាត់ ក. ស. ភ. ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ពុំមាន ថយចុះ១០០% ធៀបនឹងការអនុវត្តត្រីមាសទី៣ ឆ្នាំ២០២០ (០នាក់) សម្រាប់៩ខែដើម ឆ្នាំ២០២១ ក. ស. ភ. សម្រេចបាន ០,០០% ធៀបនឹងផែនការ ឆ្នាំ២០២១ (១៤ ៦៦៧ នាក់)។

## ក្រាហ្វិក ស្តីពីការប្រៀបធៀបការអនុវត្តត្រីមាសទី៣ ឆ្នាំ ២០២១ - ឆ្នាំ២០២០ - ឆ្នាំ២០១៩ និងផែនការឆ្នាំ២០២១



## ២. ការអនុវត្តការងារជលធារសាស្ត្រ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងចក្រ

- *ការងារជលធារសាស្ត្រ*

- សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១នេះ ការងារគ្រប់គ្រងលើដំណើរការបូមស្តារដើម្បីយកខ្សាច់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុក ដែលបូមចេញពីទីតាំងប្រឡាយកោះកែវ មានបរិមាណសរុបចំនួន ២៨៩.៧២៣ ម៉ែត្រត្រីគុណ
- បានធ្វើការបូមស្តារប្រឡាយនាវាចរណ៍ស្តៅដែលស្ថិតនៅឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម អនុវត្តបាន ១០០% នៃផែនការ
- បូមស្តារជាឃ្លូងសម្រាប់នាវា ចេញ-ចូល និងយកអាចម៍ដីចាក់បំពេញទីលានផែរណបពហុបំណងកោះរកា បាន ១០០% នៃផែនការ។

- *ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ*

- គម្រោងសាងសង់ស្ពានផែទំហំ ១២មx១៩៩ម, ដៃស្ពានផែទំហំ៨មx៣២ម, ជើងគ្រឹះដងយោង FCC ២គ្រឿង ទំហំ ៩មx១០ម, ផ្លូវ Asphalt-Concrete ទំហំ ១១.៣១០ម៉ែត្រក្រឡា, បង្គោលភ្លើងបំភ្លឺទីលានចំនួន២បង្គោល (កម្ពស់៣៥ម) សម្រេចបាន ១០០% នៃគម្រោង
- គម្រោងសាងសង់ច្រកទ្វារចេញ-ចូលថ្មី ទំហំ ២១ម៉ែត្រx៣០ម៉ែត្រ និងផ្លូវ Asphalt concrete ទំហំ ៥.៥៦០ ម៉ែត្រក្រឡា សម្រេចបាន ១០០% នៃគម្រោង
- គម្រោងសាងសង់ទូអូស្តូទំហំ ៤០ហ្វិត ចំនួន ៣គ្រឿងធ្វើជាជម្រកកម្មករ និយោជិក រង់ចាំបំពេញការងារ នៅចំណតផែកុងតឺន័រ LM១៧ សម្រេចបាន ១០០% នៃគម្រោង
- គម្រោងសាងសង់ Dolphin បន្ថែមចំនួន ២គ្រឿង ស្ថិតនៅចំណតផែកុងតឺន័រ LM១៧ (ប្លង់B) ដើម្បីផ្តល់សុវត្ថិភាព និងភាពងាយស្រួលដល់ការចូលចតរបស់នាវា សម្រេចបាន ១០០% នៃគម្រោង
- គម្រោងសាងសង់អគារស្នាក់នៅរបស់កម្មករ ទំហំ ១៦ម៉ែត្រ x ៥៥ម៉ែត្រ កម្ពស់៤ជាន់ នៅចំណតផែកុងតឺន័រLM១៧ សម្រេចបាន ៨៥% នៃគម្រោង
- គម្រោងតបណ្តាញអគ្គិសនីសម្រាប់ផ្គត់ផ្គង់ទីលានផ្ទុកកុងតឺន័រ ជំហានទី២&៣ ស្ថិតនៅចំណតផែកុងតឺន័រ LM១៧ សម្រេចបាន ៩០% នៃគម្រោង
- គម្រោងសាងសង់ដៃស្ពានផែបណ្តែតទឹក និងប៉ុងតុងចំនួន ៣ គ្រឿង ទំហំ១៥ម៉ែត្រx៤២ម៉ែត្រ កម្ពស់២,៥ម៉ែត្រ នៅចំណតផែពហុបំណងTS៣ សម្រេចបាន ៧០% នៃគម្រោង
- គម្រោងសាងសង់ផ្លូវថ្នមិច និងទីលាន ដើម្បីផ្តល់ភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការលើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ នៅចំណតផែរណបពហុបំណងកោះរកា សម្រេចបាន ៩៩,៥% នៃផែនការ

- គម្រោងសាងសង់ផ្លូវក្រាលថ្មម៉ិច ទំហំ ៣.០៥១ ម៉ែត្រក្រឡា កម្រាស់ 0,៥ម៉ែត្រ នៅច្រកចេញ-ចូលថ្មី នៃចំណតផែកុងតឺន័រ LM១៧ ដើម្បីសម្រួលចរាចរណ៍ដឹកជញ្ជូនក្នុងចំណតផែ សម្រេចបាន ១០០% នៃផែនការ
- បានរៀបចំទូអូស្ត ទំហំ ៤០ហ្វីត ចំនួន១គ្រឿង ដើម្បីធ្វើជាការិយាល័យ និងអគារស្នាក់នៅចល័ត ស្ថិតនៅចំណតផែរណបពហុបំណងកោះរកាជូនបុគ្គលិកសម្រេចបាន១០០%នៃគម្រោង
- សាងសង់រោងស្តេនរថយន្តដឹកកុងតឺន័រទំហំ (១៦ម x ៣២ម) នៅប្លង់ B-LM១៧សម្រេចបាន ៩,១.%
- សាងសង់ចំណតម៉ូតូ កង់ ទំហំ (១០,៥ម x ៣៦ម) នៅក្បែច្រកចេញចូលប្លង់ A-LM១៧ សម្រេចបាន ៦៧%.

❖ ***ការទិញ/បំពាក់គ្រឿងចក្រ ឬឧបករណ៍ថ្មី***

- បានបញ្ជាទិញរថយន្តដឹកទូកុងតឺន័រក្នុងផែ Terminal Tractor ចំនួន ១០គ្រឿង សម្រាប់ប្រតិបត្តិការលើទីលានផ្ទុកទូកុងតឺន័រ
- បានបញ្ជាទិញរថស្ទូច Empty Stacker ចំនួន ២គ្រឿង សម្រាប់ប្រតិបត្តិការលើទីលានផ្ទុកកុងតឺន័រ
- បានបញ្ចប់ការងារដំឡើងរថស្ទូចកុងតឺន័រ (RTG) ចំនួន៤គ្រឿង នៅចំណតផែកុងតឺន័រLM១៧
- បានបញ្ចប់ការងារដំឡើងដងយោង (FCC) ចំនួន ២គ្រឿង នៅចំណតផែកុងតឺន័រLM១៧
- ការងារបំពាក់ឧបករណ៍ និងតបណ្តាញប្រព័ន្ធព័ត៌មានវិទ្យា អនុវត្តបាន ៧៥% នៃផែនការ។

## ខ- រចនាសម្ព័ន្ធចំណូល

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ១៦ ៧២៥ ១០៩ | ៤៥,៣៤% | ១៣ ៨៧៩ ៦២២ | ៤៤,៧៧% | ១៤ ០៤០ ៣៩០ | ៤២,២៨% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ១៣ ៣៦៥ ៨៣៩ | ៣៦,២៣% | ១១ ៣៣៧ ១៩៨ | ៣៦,៥៧% | ១១ ៨៧៧ ៥៤១ | ៣៥,៧៧% |
| ចំណូលពីកិច្ចការផែ | ៤ ០២៤ ៩៦៣ | ១០,៩១% | ៣ ៨៨៥ ៥៨៥ | ១២,៥៣% | ៤ ៣៧៩ ៩០៦ | ១៣,១៩% |
| ចំណូលពីច្រកទ្វារ | ១ ១៣២ ៩៧៩ | ៣,០៧% | ៨២៩ ៧២៦ | ២,៦៨% | ៨៤៤ ៥៧៧ | ២,៥៤% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៩១៣ ៦២៨ | ២,៤៨% | ៦៨៨ ៥៨២ | ២,២២% | ១ ៧៤០ ២៦៧ | ៥,២៤% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ១១ ៤៣៤ | ០,០៣% | ៦ ០៦៨ | ០,០២% | ១ ៣៨៩ | ០,០០% |
| ចំណូលពីការរើរៀបទំនិញ | ២៦ ៥០៩ | ០,០៧% | ២៩ ៨៨៩ | ០,១០% | ១៧ ៧៩១ | ០,០៥% |
| ចំណូលពីការដឹកជញ្ជូន | ៤៥០ ៩៨៦ | ១,២២% | ២៦០ ៥១១ | ០,៨៤% | ១២៧ ៧២៤ | ០,៣៨% |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ២១៨ ៤៣១ | ០,៥៩% | ៤៩ ០៧៨ | ០,១៦% | ១៧៦ ៧១៦ | ០,៥៣% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ២៣ ៨០០ | ០,០៦% | ៣៦ ៣៥៩ | ០,១២% | - | ០,០០% |
| សរុបៈ | **៣៦ ៨៩៣ ៦៧៨** | **១០០,០០%** | **៣១ ០០២ ៦១៨** | **១០០,០០%** | **៣៣ ២០៦ ៣០១** | **១០០,០០%** |

# ផ្នែកទី ៣

# របាយការណ៍ហិរញ្ញវត្ថុ ដែលបានត្រួតពិនិត្យឡើងវិញដោយ សវនករឯករាជ្យ

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤

**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន**
**សម្រាប់រយៈពេល ៩ ខែ បញ្ចប់ថ្ងៃទី៣០ កញ្ញា ២០២១**

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤

**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

| **មាតិកា** | **ទំព័រ** |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប | ៣ - ៤ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប | ៥ - ៦ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេប | ៧ - ៨ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេប | ៩ - ១០ |
| កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ១១ - ៣៧ |

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤

១

**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នរបស់ កំពង់ផែស្វយ័តភ្នំពេញ ហៅកាត់ថា ("ក.ស.ភ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ព្រមទាំង របាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប របាយការណ៍បម្រែបម្រួលមូលធនសង្ខេប និង របាយការណ៍លំហូរសាច់ប្រាក់សង្ខេប សម្រាប់រយៈពេល ៩ខែ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត្រូវបានគេស្គាល់ផងដែរថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន") បានរៀបចំឡើងត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ទៅតាម ស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន*។

**តាងនាមឱ្យក្រុមប្រឹក្សាភិបាល**

**ឯកឧត្តម ហ៊ី បាវី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

**កញ្ញា ឈាង វណ្ណឌា**
នាយកគណនេយ្យ/ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

BDO

Tel: +855 23 218 128
Fax: +855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



**របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន**
**ជូនចំពោះភាគហ៊ុនិករបស់កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខ Co.៧១៧៥ Et/២០០៤)

**សេចក្ដីផ្ដើម**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់ កំពង់ផែស្វយ័តភ្នំពេញ ហៅកាត់ថា ("ក.ស.ភ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបនាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប របាយការណ៍បម្រែបម្រួលមូលធនសង្ខេប និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេប សម្រាប់រយៈពេល ៩ខែ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែមផ្សេងៗ ("ត្រូវបានគេហៅថាជាព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន")។ អគ្គនាយកជាអ្នកទទួលការខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន។ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្នដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

**វិសាលភាពនៃការត្រួតពិនិត្យ**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាម ស្ដង់ដារអន្តរជាតិកម្ពុជាលើកិច្ចព្រមព្រៀងការត្រួតពិនិត្យលេខ ២៤១០ ស្ដីពី *ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុបណ្ដោះអាសន្ន ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុបណ្ដោះអាសន្ន រួមមានការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្ដង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថាបានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បានក្នុងពេលធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

**សេចក្ដីសន្និដ្ឋាន**

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន ដែលបានភ្ជាប់មកជាមួយនេះ មិនបានរៀបចំឡើងត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ទៅតាមស្ដង់ដារគណនេយ្យអន្តរជាតិកម្ពុជាលេខ ៣៤ ស្ដីពី *របាយការណ៍ហិរញ្ញវត្ថុបណ្ដោះអាសន្ន* នោះទេ។

BDO Cambodia

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤



## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប
## នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ ដុល្លារអាមេរិក | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ ដុល្លារអាមេរិក | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ គិតជាពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ៩៧.០០៧.៣៨៤ | ៣៩៥.៦៩៣.១១៩ | ៨៨.៨២៩.៨៦៣ | ៣៥៩.៣១៦.៧៩៦ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ៥ | ៣.៦៨៦.១២៥ | ១៥.០៣៥.៧០៤ | - | - |
| ទ្រព្យសម្បត្តិវិនិយោគ | ៦ | ៨៤.៦៤១.៣៣០ | ៣៤៥.២៥១.៩៨៥ | ៨៤.៦៨៧.០០០ | ៣៤២.៥៥៨.៩១៥ |
| ការជួលត្រូវទទួល | ៥ | ៤.៣០០.១១១ | ១៧.៥៤០.១៩៣ | ៤.៣១០.៤៧៧ | ១៧.៤៣៥.៨៧៩ |
| គណនីត្រូវទទួលផ្សេងៗ | ៧ | ៦៧.៥៨៥ | ២៧៥.៦៧៩ | ៦៤.៩៨៦ | ២៦២.៨៦៨ |
| ទ្រព្យសកម្មពន្ធពន្យារ | ៨ | ៤៤៧.៩៧៣ | ១.៨២៧.២៨២ | ៤៣៩.៩៩១ | ១.៧៧៩.៧៦៤ |
| | | ១៩០.១៥០.៥០៨ | ៧៧៥.៦២៣.៩២២ | ១៧៨.៣៣២.៣១៧ | ៧២១.៣៥៤.២២២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ៧ | ១២.២៤៤.១៩២ | ៤៩.៩៤៣.៨៥៥ | ១០.៧២៤.៦៧៣ | ៤៣.៣៨១.៣០២ |
| ការជួលត្រូវទទួល | ៥ | ១៣.៧៥៥ | ៥៦.១០៧ | ១៣.៣៦២ | ៥៤.០៤៩ |
| សាច់ប្រាក់ និងសាច់ប្រាក់នៅធនាគារ | ៩ | ១៤.៣៦៦.៣៩១ | ៥៨.៦០០.៥០៩ | ១៧.៦៨៣.៨៤១ | ៧១.៥៣១.១៣៧ |
| | | ២៦.៦២៤.២៨៨ | ១០៨.៦០០.៤៧១ | ២៨.៤២១.៨៧៦ | ១១៤.៩៦៦.៤៨៨ |
| **ទ្រព្យសកម្មសរុប** | | ២១៦.៧៧៤.៧៩៦ | ៨៨៤.២២៤.៣៩៣ | ២០៦.៧៥៤.១៩៣ | ៨៣៦.៣២០.៧១០ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១០ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ |
| បុព្វលាភភាគហ៊ុន | ១១ | ១៥៥.៥០២ | ៦២២.០០៨ | ១៥៥.៥០២ | ៦២២.០០៨ |
| ទុនបម្រុង | ១២ | ៤៥.៨៦១.៣៨០ | ១៨៧.០៦៨.៥៦៩ | ៣៦.៩៣៩.៦០៦ | ១៤៧.៨០២.៧០៥ |
| ចំណេញរក្សាទុក | | ៩.៤១៥.០៦៤ | ៣៨.៤០៤.០៤៦ | ១០.០៧៩.២៣២ | ៤១.១០៣.១១០ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | ៩.០៥៤.១០៨ | - | ៤.៨២៤.៧៨៨ |
| **មូលធនសរុប** | | ១៦៩.៨៨៥.៤៣១ | ៦៩២.៩៦២.៦៧១ | ១៦១.២២៧.៨២៥ | ៦៥២.១៦៦.៥៥១ |

## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប
## នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១(ត)

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ ដុល្លារអាមេរិក | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ ដុល្លារអាមេរិក | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ គិតជាពាន់រៀល |
|---|---|---|---|---|---|
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| គណនីត្រូវបង់ផ្សេងៗ | ១៣ | ៣៣.៧៩៣ | ១៣៧.៨៤២ | ៣២.៤៩៣ | ១៣១.៤៣៤ |
| ប្រាក់កម្ចី | ១៤ | ១៨.៦២៩.៧៦៧ | ៧៥.៩៩០.៨២០ | ២០.៦៩៩.៧៤១ | ៨៣.៧៣០.៤៥២ |
| សំវិធានធនលើមូលនិធិសោធនិវត្តន៍ | ១៥ | ៦៧៦.៨២៩ | ២.៧៦០.៧៨៥ | ៦១៦.៤២២ | ២.៤៩៣.៤២៩ |
| បំណុលពីការជួល | ៥ | ៦.៧៤២.៦២៣ | ២៧.៥០៣.១៥៩ | ២.៨៧៣.៦៥០ | ១១.៦២៣.៩១៤ |
| កិច្ចសន្យាបំណុល | ១៦ | ១៣.៧២៥.០០០ | ៥៥.៩៨៤.២៧៥ | ១៣.៩៥០.០០០ | ៥៦.៤២៧.៧៥០ |
| | | ៣៩.៨០៨.០១២ | ១៦២.៣៧៦.៨៨១ | ៣៨.១៧២.៣០៦ | ១៥៤.៤០៦.៩៧៩ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | ១៣ | ២.៩៣៤.២៥៤ | ១១.៩៦៨.៨២៤ | ៣.០៥៥.៤០០ | ១២.៣៥៩.០៩២ |
| ប្រាក់កម្ចី | ១៤ | ២.០៦៩.៩៧៤ | ៨.៤៤៣.៤២៤ | ២.០៦៩.៩៧៤ | ៨.៣៧៣.០៤៥ |
| បំណុលពីការជួល | ៥ | ៩.១៧៣ | ៣៧.៤១៧ | ៨.៩០៩ | ៣៦.០៣៧ |
| កិច្ចសន្យាបំណុល | ១៦ | ៣០០.០០០ | ១.២២៣.៧០០ | ៣០០.០០០ | ១.២១៣.៥០០ |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ១.៧៦៧.៩៥២ | ៧.២១១.៤៧៦ | ១.៩១៩.៧៧៩ | ៧.៧៦៥.៥០៦ |
| | | ៧.០៨១.៣៥៣ | ២៨.៨៨៤.៨៤១ | ៧.៣៥៤.០៦២ | ២៩.៧៤៧.១៨០ |
| **បំណុលសរុប** | | ៤៦.៨៨៩.៣៦៥ | ១៩១.២៦១.៧២២ | ៤៥.៥២៦.៣៦៨ | ១៨៤.១៥៤.១៥៩ |
| **មូលធន និងបំណុលសរុប** | | ២១៦.៧៧៤.៧៩៦ | ៨៨៤.២២៤.៣៩៣ | ២០៦.៧៥៤.១៩៣ | ៨៣៦.៣២០.៧១០ |

*របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

លេខបញ្ជីពាណិជ្ជកម្មៈ
Co.៧១៧៥ Et/២០០៤



## គំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

| | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ៣០ កញ្ញា ២០២១[១] | | ៣០ កញ្ញា ២០២០[២] | | ៣០ កញ្ញា ២០២១[១] | | ៣០ កញ្ញា ២០២០[២] | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូល | ១៨ | ៩.០៦៣.៥២៥ | ៣៦.៨៩៣.៦៧៨ | ៧.៥៧៦.០៤៥ | ៣១.០០២.៦១៨ | ២២.៨៥៨.៦៩៨ | ៩២.៩៤៣.៤៦៥ | ២០.៤៤២.៩៨៨ | ៨៣.៤៤៨.២៧៨ |
| ថ្លៃដើមសេវាកម្ម | ១៩ | (២.៥៨៧.៥៩២) | (១០.៥៣៤.៧៤០) | (២.០៧៨.៣៤៦) | (៨.៥០៧.៥៨៨) | (៧.១១៨.៣០៤) | (២៨.៩៤៣.០២៣) | (៦.០៤១.៦៨៥) | (២៤.៦៦២.១៥៧) |
| ប្រាក់ចំណេញដុល | | ៦.៤៧៥.៩៣៣ | ២៦.៣៥៨.៩៣៨ | ៥.៤៩៧.៦៩៩ | ២២.៤៩៥.០៣០ | ១៥.៧៤០.៣៩៤ | ៦៤.០០០.៤៤២ | ១៤.៤០១.៣០៣ | ៥៨.៧៨៦.១២១ |
| ចំណូលផ្សេងៗ | ២០ | ៦៣៦.៦៩៥ | ២.៥៩៣.៣៣៩ | ៥៧៩.២៩៧ | ២.៣៧២.១៤៧ | ២.១៤៩.២៤៣ | ៨.៧៣៨.៨២២ | ១.៨២១.៨៨៨ | ៧.៤៣៦.៩៤៧ |
| ចំណាយទូទៅ និង ចំណាយរដ្ឋបាល | ២១ | (១.៨៨២.១២៦) | (៧.៦៦៣.៤៧១) | (១.៩០៣.០៨១) | (៧.៧៩១.១៥៥) | (៥.៤៦៤.៧១៨) | (២២.២១៩.៥៤២) | (៥.៦៩៩.១២៧) | (២៣.២៦៣.៨៣៩) |
| ចំណេញប្រតិបត្តិការ | | ៥.២៣០.៥០២ | ២១.២៨៨.៨០៦ | ៤.១៧៣.៩១៥ | ១៧.០៧៦.០២២ | ១២.៤២៤.៩១៩ | ៥០.៥១៩.៧២២ | ១០.៥២៤.០៦៤ | ៤២.៩៥៩.២២៩ |
| ចំណាយហិរញ្ញប្បទាន | ២២ | (២៩៦.១៩៨) | (១.២០៦.០៤៤) | (២៦៩.១១២) | (១.១០១.៨៤៣) | (៨៦៣.៨២៧) | (៣.៥១២.៣២១) | (៨២៣.៧៨០) | (៣.៣៦២.៦៧០) |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ៤.៩៣៤.៣០៤ | ២០.០៨២.៧៦២ | ៣.៩០៤.៨០៣ | ១៥.៩៧៤.១៧៩ | ១១.៥៦១.០៩២ | ៤៧.០០៧.៤០១ | ៩.៧០០.២៨៤ | ៣៩.៥៩៦.៥៥៩ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៣ | (១.០០៨.១០៦) | (៤.១០២.១៣២) | (៨១៩.៦១៦) | (៣.៣៥៣.៣៤៤) | (២.០៦៥.៧០៧) | (៨.៣៩៩.១៦៥) | (២.០៩៨.២១៩) | (៨.៥៦៤.៩៣០) |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | | ៣.៩២៦.១៩៨ | ១៥.៩៨០.៦៣០ | ៣.០៨៥.១៨៧ | ១២.៦២០.៨៣៥ | ៩.៤៩៥.៣៨៥ | ៣៨.៦០៨.២៣៦ | ៧.៦០២.០៦៥ | ៣១.០៣១.៦២៩ |

## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ (ត)

| | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ៣០ កញ្ញា ២០២១(១) | | ៣០ កញ្ញា ២០២០(២) | | ៣០ កញ្ញា ២០២១(១) | | ៣០ កញ្ញា ២០២០(២) | |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| លទ្ធផលផ្សេងៗ ពន្ធសុទ្ធ | | | | | | | | | |
| ខ្ទង់គណនីដែលមិនបានបែងចែក ចំណេញ ឬខាត៖ | | | | | | | | | |
| ការកំណត់ឡើងវិញនូវសំវិធានធន លើមូលនិធិសោធនិវត្តន៍ | | (៦៧.៥១១) | (២៧៤.៥៣៨) | ៣០.៨៧១ | ១២៦.០៧៤ | (៨០.៣២១) | (៣២៦.៥៨៥) | ៤០.៧០៩ | ១៦៦.១៧៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៣.៨៥៨.៦៨៧ | ១៥.៧០៦.០៩២ | ៣.១១៦.០៥៨ | ១២.៧៤៦.៩០៩ | ៩.៤១៥.០៦៤ | ៣៨.២៨១.៦៥១ | ៧.៦៤២.៧៧៤ | ៣១.១៩៧.៨០៣ |
| ចំណេញក្នុងមួយភាគហ៊ុន | | | | | | | | | |
| ក្នុងមួយភាគហ៊ុនគោល | ២៤ | 0,១៩ | 0,៧៦ | 0,១៥ | 0,៦២ | 0,៤៦ | ១,៨៥ | 0,៣៧ | ១,៥១ |
| ក្នុងមួយភាគហ៊ុនថយចុះ | ២៤ | 0,១៩ | 0,៧៦ | 0,១៥ | 0,៦២ | 0,៤៦ | ១,៨៥ | 0,៣៧ | ១,៥១ |

***កំណត់សម្គាល់៖***

*(១) របាយការណ៍ចំណេញ ឬខាត និងលទ្ធផលផ្សេងៗសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្ដោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទបានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្មទេ។*

លេខបញ្ជីពាណិជ្ជកម្មៈ
Co.៧១៧៥ Et/២០០៤



## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | លម្អៀងនៃការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី ១ មករា ២០២១** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៣៦.៥៣៩.៦០៦** | **១០.០៧៩.២៣២** | - | **១៦១.២២៧.៨២៥** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ៩.៤៩៥.៣៨៥ | - | ៩.៤៩៥.៣៨៥ |
| ខាតពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធនិវត្តន៍ | | - | - | - | (៨០.៣២១) | - | (៨០.៣២១) |
| លទ្ធផលចំណេញសរុបក្នុងការិយបរិច្ឆេទ | | - | - | - | ៩.៤១៥.០៦៤ | - | ៩.៤១៥.០៦៤ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង | ១២ | - | - | ៩.៣២១.៧៧៤ | (៩.៣២១.៧៧៤) | - | - |
| ភាគលាភ | ២៥ | - | - | - | (៧៥៧.៤៥៨) | - | (៧៥៧.៤៥៨) |
| សរុបប្រតិបត្តិការជាមួយភាគហ៊ុនិក | | - | - | ៩.៣២១.៧៧៤ | (១០.០៧៩.២៣២) | - | (៧៥៧.៤៥៨) |
| **សមតុល្យនាថ្ងៃទី ៣០ កញ្ញា ២០២១**[(១)] | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៤៥.៨៦១.៣៨០** | **៩.៤១៥.០៦៤** | - | **១៦៩.៨៨៥.៤៣១** |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | *៦២២.០០៨* | *១៨៦.០៦៨.៥៦៩* | *៣៨.៤០៤.០៤៦* | *៩.០៥៤.១០៨* | *៦៩២.៩៦២.៦៧១* |

## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១(ត)

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | លម្អៀងនៃការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី ១ មករា ២០២០** | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **២៥.៦៥១.៤១៩** | **១១.៦៤១.៩២៤** | - | **១៥១.៩០២.៣៣០** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ៧.៦០២.០៦៥ | - | ៧.៦០២.០៦៥ |
| ចំណេញពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | | - | - | - | ៤០.៧០៩ | - | ៤០.៧០៩ |
| លទ្ធផលចំណេញសរុបក្នុងការិយបរិច្ឆេទ | | - | - | - | ៧.៦៤២.៧៧៤ | - | ៧.៦៤២.៧៧៤ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង | ១២ | - | - | ១០.៨៨៨.១៨៧ | (១០.៨៨៨.១៨៧) | - | - |
| ភាគលាភ | | - | - | - | (៧៥៣.៧៣៧) | - | (៧៥៣.៧៣៧) |
| សរុបប្រតិបត្តិការជាមួយភាគហ៊ុនិក | | - | - | ១០.៨៨៨.១៨៧ | (១១.៦៤១.៩២៤) | - | (៧៥៣.៧៣៧) |
| **សមតុល្យនាថ្ងៃទី ៣០ កញ្ញា ២០២០**(២) | | **១១៤.៤៥៣.៤៨៥** | **១៥៥.៥០២** | **៣៦.៥៣៩.៦០៦** | **៧.៦៤២.៧៧៤** | - | **១៥៨.៧៩១.៣៦៧** |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | *៦២២.០០៨* | *១៤៩.៨១២.៣៨៥* | *៣១.១៩៧.៨០៣* | *១១.៥៩៨.៤៧៣* | *៦៥១.០៤៤.៦០៩* |

***កំណត់សម្គាល់៖***

*(១) របាយកាណ៍បម្រែបម្រួលមូលធនសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទបានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្មទេ។*

លេខបញ្ជីពាណិជ្ជកម្មៈ
Co.៧១៧៥ Et/២០០៤



## កំពង់ផែស្វយ័តភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

| | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ៣០ កញ្ញា ២០២១[១] | | ៣០ កញ្ញា ២០២០[២] | |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធ មុនបង់ពន្ធ | | ១១.៥៦១.០៩២ | ៤៧.០០៧.៤០១ | ៩.៧០០.២៨៤ | ៣៩.៥៩៦.៥៥៩ |
| និយ័តកម្មៈ | | | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ២.៣១៣.៧៩២ | ៩.៤០៧.៨៧៨ | ១.៩៦៦.៤៩១ | ៨.០២៧.២១៦ |
| រំលស់ទ្រព្យសម្បត្តិវិនិយោគ | ៦ | ៤៥.៦៧០ | ១៨៥.៦៩៤ | ៤៧.៦៥១ | ១៩៤.៥១១ |
| រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | | ៧៥.៣៩៩ | ៣០៦.៥៧២ | ៨២២.៥៣០ | ៣.៣៥៧.៥៦៧ |
| ចំណាយហិរញ្ញប្បទាន | | ៨៦២.៥២៧ | ៣.៥០៧.០៣៥ | ២៥៧.៦៨២ | ១.០៥១.៨៥៨ |
| ឱនភាពនៃការខាតបង់លើគណនីពាណិជ្ជ | | ៣០៥.៧១១ | ១.២៤៣.០២១ | - | - |
| ចំណូលការប្រាក់ | | (៨២១.៥៩៤) | (៣.៣៤០.៦០១) | (១.០១៨.៨៧៨) | (៤.១៥៩.០៦០) |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិវិនិយោគ | | - | - | ១០៣.៣៧៦ | ៤២១.៩៨១ |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | - | - | ៦០.៣២៤ | ២៤៦.២៤៣ |
| ផលប៉ះពាល់នៃការដាក់ប្រាក់រយៈពេលវែង | | (១.២៩៩) | (៥.២៨២) | (១.២៤៩) | (៥.០៩៨) |
| ការជម្រះចេញពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | - | - | ១២៥.៩០១ | ៥១៣.៩២៨ |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ១៥ | ១៣៣.៩៦៣ | ៥៤៤.៦៩៤ | ៤៤.២០១ | ១៨០.៤២៨ |
| ចំណេញពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | | - | - | (១.៤៧៨) | (៦.០៣៣) |
| ចំណូលប្រតិបត្តិការ មុនបម្រែបម្រួលដើមទុនបង្វិល | | ១៤.៤៧៥.២៦១ | ៥៨.៨៥៦.៤១២ | ១២.១០៦.៨៣៥ | ៤៩.៤២០.១០០ |
| បម្រែបម្រួលដើមទុនបង្វិលៈ | | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | | (១.៤០៦.៥៦០) | (៥.៧១៩.០៧៣) | (១៧០.៦៤៧) | (៦៩៦.៥៨១) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | | (៣៣៨.១៥៨) | (១.៣៧៤.៩៥០) | (៥៣៣.១២១) | (២.១៧៦.២០០) |
| កិច្ចសន្យាបំណុល | | (២២៥.០០០) | (៩១៤.៨៥០) | (២២៥.០០០) | (៩១៨.៤៥០) |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ១៣.១៨១.៨៥៩ | ៥៣.៥៩៧.៤៣៩ | ១១.១៧៨.០៦៧ | ៤៥.៦២៨.៨៦៩ |
| ចំណាយបង់ពន្ធ | | (២.២២៥.៥១៦) | (៩.០៤៨.៩៤៨) | (២.៤៩០.៩៦២)) | (១០.១៦៨.១០៧) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | ១៥ | (១៥.៨៧៨) | (៦៤.៥៥៩) | (៣៧.៩២២) | (១៥៤.៧៩៨) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ១០.៩៤០.៤៦៥ | ៤៤.៤៨៣.៩៣១ | ៨.៦៤៩.១៨៣ | ៣៥.៣០៥.៩៦៤ |

លេខបញ្ជីពាណិជ្ជកម្មៈ
Co.៧១៧៥ Et/២០០៤



## កំពង់ផែស្វយ័តភ្នំពេញ
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១(ត)

| | | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|---|
| | កំណត់ | ៣០ កញ្ញា ២០២១[១] | | ៣០ កញ្ញា ២០២០[២] | |
| | សម្គាល់ | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | (១០.៤៩១.៣១៣) | (៤២.៦៥៧.៦៧៩) | (៩.១៤៥.៦៣៣) | (៣៧.៣៣២.៤៧៤) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | - | - | ១.៩១៣ | ៧.៨០៩ |
| ចំណូលពីការលក់ទ្រព្យសម្បត្តិវិនិយោគ | | - | - | ៣៥០ | ១.៤២៩ |
| ការប្រាក់ទទួលបាន | | ២៧៣.៣៩១ | ១.១១០.៦០៨ | ២០០.១៣៥ | ៨១៦.៩៥១ |
| ការដាក់ប្រាក់បញ្ញើជាមួយធនាគារដែលមានអាជ្ញាប័ណ្ណ | | ៣.៩៩៨.៤០៣ | ១៦.២៥៧.៥០៧ | ១.២០០.០០០ | ៤.៨៩៨.៤០០ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៦.២១៩.៥១៩) | (២៥.២៨៨.៥៦៤) | (៧.៧៤៣.២៣៥) | (៣១.៦០៧.៨៨៥) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភបានបង់ | | (១.០១៩.២៧២) | (៤.១៤៤.៣៦០) | (១.០១៣.៦២៤) | (៤.១៣៧.៦១៣) |
| ការប្រាក់បានបង់ | | (៨៩០.០៨៨) | (៣.៦១៩.០៩៨) | (៩៩៣.៧០៨) | (៤.០៥៦.៣១៦) |
| ការបង់ប្រាក់លើកិច្ចសន្យាបំណុល | | (៦០.៦៥៩) | (២៤៦.៦៣៩) | (១២៤.០៥០) | (៥០៦.៣៧២) |
| ការបង់ប្រាក់ដើមកម្ចី | | (២.០៦៩.៩៧៤) | (៨.៤១៦.៥១៤) | (២.០៦៩.៩៧៤) | (៨.៤៤៩.៦៣៤) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (៤.០៣៩.៩៩៣) | (១៦.៤២៦.៦១១) | (៤.២០១.៣៥៦) | (១៧.១៤៩.៩៣៥) |
| **កំណើន/(តំហយ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៦៨០.៩៥៣ | ២.៧៦៨.៧៥៥ | (៣.២៩៥.៤០៨) | (១៣.៤៥១.៨៥៦) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ២.៦៨៣.៨៤១ | ១០.៩៣៦.៦៥២ | ៩.៧៨៤.៩០៨ | ៣៩.៨៧៣.៥០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ១៥.៥៨៨ | - | ១៨៥.៣០៦ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | ៩ | ៣.៣៦៤.៧៩៤ | ១៣.៧២៤.៩៩៥ | ៦.៤៨៩.៥០០ | ២៦.៦០៦.៩៥០ |

***កំណត់សម្គាល់៖***

*(១) របាយការណ៍លំហូរសាច់ប្រាក់សង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទបានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្មទេ។*

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤



**កំពង់ផែស្វយ័តភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន**
**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២១**

## ១. ព័ត៌មានអំពីក្រុមហ៊ុន

កំពង់ផែស្វយ័តភ្នំពេញ ("ក.ស.ភ") ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ៥១ អនក្រ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("ក.ស.ហ") និងក្រសួងសាធារណការ និងដឹកជញ្ជូន ("ក.ស.ដ")។ ក្រុមហ៊ុនបានចុះបញ្ជីនៅទីផ្សារមូលបត្រកម្ពុជា នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ដែលមានលេខចុះបញ្ជី ០០៣ CSX/SC និងប្រែក្លាយជាសហគ្រាសសាធារណៈ ដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ ក.ស.ភ ស្ថិតនៅអគារលេខ៦៤៩ តិវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("US$") ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។ ការបង្ហាញបញ្ជាក់បន្ថែមទៀត ក៏ត្រូវបានរៀបចំជារូបិយប័ណ្ណខ្មែរ ("KHR") ដើម្បីបំពេញតំរូវការរបស់ច្បាប់គណនេយ្យ និងសវនកម្ម។ ក.ស.ភ ប្រើអត្រាប្តូរប្រាក់ផ្លូវការនាចុងការិយបរិច្ឆេទ និងអត្រាមធ្យមសម្រាប់ប្រតិបត្តិការដូចខាងក្រោមនេះ៖

| | | អត្រាចុងការិយបរិច្ឆេទ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | ១ ដុល្លារអាមេរិក = | ៤.០៧៩រៀល | ៤.០៦៦រៀល |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ១ ដុល្លារអាមេរិក = | ៤.០៤៥រៀល | ៤.០៧៨រៀល |
| ថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០២០ | ១ ដុល្លារអាមេរិក = | ៤.១០០រៀល | ៤.០៨២រៀល |

ការប្រែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថាតួលេខ ប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរតែត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១។

## ២. សកម្មភាពចម្បង

ក.ស.ភ មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែ រួមមាន៖

- ផ្តល់កណ្តធារកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង
- ធ្វើអាជីវកម្មបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- ត្រួតពិនិត្យការប្រតិបត្តិតាមលក្ខណៈបច្ចេកទេស និងជំរុញកិច្ចការពារសុវត្ថិភាព បរិស្ថាន សណ្តាប់ធ្នាប់ក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែ
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា

## ២. សកម្មភាពចម្បង (ត)

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែ រួមមាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភ័ស្តុភារកម្ម
- ចាត់វិធានការនានា ដើម្បីធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពាក់ព័ន្ធនឹងកំពង់ផែ និងមធ្យោបាយដឹកជញ្ជូននានាតាមផ្លូវទឹក
- លើកដាក់ ផ្ទេរ ផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរវាងកំពង់ផែ និងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវា ពាក់ និងដោះពួរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភ័ស្តុភារ ទឹកស្អាត អនាម័យដល់នាវា
- ផ្តល់សេវាកម្មវេរ និងច្រកទំនិញដាក់កុងតឺន័រ
- ផ្តល់សេវាកម្មជួសជុល និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងមណ្ឌលសេវាកម្មផែក្នុងស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្មបន្ថែមផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបម្រើដល់ការរីកចម្រើនរបស់ ក.ស.ភ។

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន

របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នមិនត្រូវបានធ្វើសវនកម្ម និងត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន*។ របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ គួរតែត្រូវបានអានផ្គួបផ្សំជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងកំណត់សម្គាល់មួយចំនួនដែលអមជាមួយ។

កំណត់សម្គាល់មួយចំនួន ត្រូវបានជ្រើសរើសដាក់ភ្ជាប់មកជាមួយដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗសម្រាប់ការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មរបស់ ក.ស.ភ ចាប់ពីដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មក។

គោលការណ៍គណនេយ្យ និងវិធីសាស្ត្រនៃការគណនាដែលបានអនុវត្ត គឺសមស្របទៅនឹងគោលការណ៍ និងវិធីសាស្ត្រដែលបានអនុវត្ត នៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ លើកលែងតែការអនុវត្តនៃស្តង់ដាគណនេយ្យ និងវិសោធនកម្មដូចខាងក្រោម៖

| | **ថ្ងៃចូលជាធរមាន** |
|---|---|
| *កំណែទម្រង់អត្រាការប្រាក់ - ដំណាក់កាលទី២* (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ ស.គ.អ.ក ៣៦ ស.រ.ហ.អ.ក ៧ ស.រ.ហ.អ.ក ៤ ស.រ.ហ.អ.ក ១៦) | ១ មករា ២០២១ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ *កូវីដ-១៩ ទាក់ទងនឹងការជួលសម្បទាន ក្រោយថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២១* | ១ មិថុនា ២០២០ (អនុវត្តមុន) |

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត)

*កំណែទម្រង់អត្រាការប្រាក់ - ដំណាក់កាលទី២ (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ ស.គ.អ.ក ៣៦ ស.រ.ហ.អ.ក ៧ ស.រ.ហ.អ.ក ៤ ស.រ.ហ.អ.ក ១៦*

ការផ្លាស់ប្តូរនៅក្នុង*កំណែទម្រង់គោលនៃអត្រាការប្រាក់ - ដំណាក់កាលទី ២* (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ ស.គ.អ.ក ៣៩ ស.រ.ហ.អ.ក ៧ ស.រ.ហ.អ.ក ៤ និង ស.រ.ហ.អ.ក ១៦) សំដៅទៅលើការផ្លាស់ប្តូរអត្រាការប្រាក់យោង ដូចជាអត្រាផ្តល់ដោយអន្តរធនាគារនៅទីក្រុងឡុងដ៍ ("LIBOR") និងអត្រាផ្តល់ដោយអន្តរធនាគារអឺរ៉ូ ("EURIBO") ជាមួយនឹងអត្រាការប្រាក់ជំនួស។ ការធ្វើវិសោធនកម្មទាំងនេះអនុវត្តចាប់ពីដំណាក់កាលដំបូងនៃការផ្តល់ជំនួយសង្គ្រោះដែលទាក់ទងនឹងអត្រាការប្រាក់អន្តរធនាគារ ("IBOR") ដែលបានចេញនៅខែកញ្ញា ឆ្នាំ២០១៩។

កំណែទម្រង់ IBOR នាំមកនូវផលប៉ះពាល់សំខាន់ៗជាច្រើនសម្រាប់អង្គភាពដែលរាយការណ៍នៅក្រោម ស.រ.ហ.អ.ក ក្នុងកំឡុងពេលមិនច្បាស់លាស់មុនពេលដែល IBOR ត្រូវបានជំនួស (ជំនួសបញ្ហាពីមុន) ក៏ដូចជានៅពេលដែល IBOR ត្រូវបានជំនួស (ជំនួសបញ្ហា) ទាំងពីរផងដែរ។ ដំណាក់កាលដំបូងនៃការធ្វើវិសោធនកម្មផ្តោតតែទៅលើជំនួសបញ្ហាពីមុនដែលទាក់ទងនឹងតម្រូវការគណនេយ្យទប់ស្កាត់ហានិភ័យ។ ដំណាក់កាលទី ២ នៃការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ផ្តោតលើបញ្ហាជំនួសទាក់ទងនឹងគណនេយ្យទប់ស្កាត់ហានិភ័យ និងផ្នែកគណនេយ្យផ្សេងទៀត។

*វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ កូវីដ-១៩ ទាក់ទងនឹងការជួលសម្បទានក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១*

វិសោធនកម្មលើ *ស.រ.ហ.អ.ក ១៦ កូវីដ-១៩ ទាក់ទងនឹងការជួលសម្បទានក្រោយថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០២១* បានធ្វើវិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ ជា៖

(ក) អនុញ្ញាតឱ្យអ្នកជួល អនុវត្តការអនុវត្តន៍ជាក់ស្តែង ទាក់ទងនឹងការផ្តល់សម្បទានជួលដែលទាក់ទងនឹងកូវីដ-១៩ ដើម្បីផ្តល់សម្បទានជួលលើការកាត់បន្ថយការទូទាត់ការជួលណាមួយ ដែលប៉ះពាល់ដល់តែការទូទាត់ដើមនៅ ឬមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ (ពីមុន តែចំពោះការទូទាត់ដល់ការកំណត់នៅ ឬមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១)

(ខ) តម្រូវឱ្យអ្នកជួលអនុវត្តការធ្វើវិសោធនកម្មនេះ ត្រលប់ទៅក្រោយដោយទទួលស្គាល់ផលប៉ះពាល់បង្គរនៃការអនុវត្តដំបូងលើវិសោធនកម្មនេះ ទៅនឹងលើសមតុល្យដើមគ្រានៃចំណេញរក្សាទុក (ឬធាតុផ្សំផ្សេងទៀតនៃមូលធន បើសមស្រប) នៅដើមរបាយការណ៍ប្រចាំឆ្នាំក្នុងរយៈពេលដែលអ្នកជួលអនុវត្តការធ្វើវិសោធនកម្មលើកដំបូង និង

(គ) ផ្តល់ជូនថាក្នុងរយៈពេលរាយការណ៍ ដែលអ្នកជួលអនុវត្តការធ្វើវិសោធនកម្មដំបូង អ្នកជួលមិនតម្រូវឱ្យបង្ហាញព័ត៌មានដែលទាមទារដោយកថាខណ្ឌ ២៨ (ច) នៃ ស.គ.អ.ក ៨ ទេ។

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត)

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្តមុន៖

| | **ថ្ងៃចូលជាធរមាន** |
|---|---|
| ការកែលម្អប្រចាំឆ្នាំលើស្តង់ដារ ស.រ.ហ.អ.ក ២០១៨ - ២០២០ | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ឯកសារយោងទៅនឹងក្របខណ្ឌគណនេយ្យ* | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.គ.អ.ក ១៦ *ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ - ចំណូលពីការលក់មុននឹងមានបំណងក្នុងការប្រើប្រាស់* | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.គ.អ.ក ៣៧ *កិច្ចសន្យាស្មុគស្មាញ - ចំណាយនៃការបំពេញកិច្ចសន្យា* | ១ មករា ២០២២ |
| វិសោធនកម្មលើ ស.គ.អ.ក ១ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង* | ១ មករា ២០២៣ |
| ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង - ការពង្រីកការលើកលែងជាបណ្តោះអាសន្នពីការអនុវត្ត ស.ក.អ.ហ.រ. ៩* | ១ មករា ២០២៣ |
| ការលាតត្រដាងគោលនយោបាយគណនេយ្យ *(វិសោធនកម្មលើ ស)គ.អ.ក ១ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ)* | ១ មករា ២០២៣ |
| ការលាតត្រដាងការប៉ាន់ស្មានគណនេយ្យ *(វិសោធនកម្មលើ ស)គ.អ.ក ៨ គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង)* | ១ មករា ២០២៣ |
| *ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុល ដែលកើតឡើងពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ ស.គ.អ.ក ១២)* | ១ មករា ២០២៣ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យរវាងសហគ្រិន និងញ្ញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ពន្យា |

ក.ស.ភ កំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យន និងវិសោធនកម្មទាំងនេះ ដោយហេតុថាក្រុមប្រឹក្សាភិបាលពុំទាន់មានជំហរ ដើម្បីសន្និដ្ឋានលើផលប៉ះពាល់ដែលមានសក្តានុពលលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ នៅឡើយទេ។

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្ម មានដូចខាងក្រោម៖

<u>ការកែលម្អប្រចាំឆ្នាំលើស្តង់ដារ ស.រ.ហ.អ.ក ២០១៨ - ២០២០</u>

ការកែលម្អប្រចាំឆ្នាំលើស្តង់ដារកែតម្រូវដូចខាងក្រោម៖

- ស.រ.ហ.អ.ក ១ *ការអនុម័តប្រើលើកដំបូងតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ* ដើម្បីអនុញ្ញាតិឱ្យក្រុមហ៊ុនបុត្រសម្ព័ន្ធដែលអនុវត្តកថាខណ្ឌ ឃ១៦ (ក) នៃស.រ.ហ.អ.ក ១ ដើម្បីវាស់វែងភាពខុសគ្នាពីការបកប្រែបូកបន្ត ដោយប្រើចំនួនទឹកប្រាក់ដែលបានរាយការណ៍ដោយក្រុមហ៊ុនមេ ផ្អែកលើកាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅជា ស.រ.ហ.អ.កររបស់ក្រុមហ៊ុនមេ។
- ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* បញ្ជាក់ពីថ្លៃឈ្នួលដែលបានរាប់បញ្ចូលក្នុង "១០ ភាគរយ" នៃការធ្វើតេស្តក្នុងកថាខណ្ឌ ខ.៣.៣.៦ នៃ ស.រ.ហ.អ.ក ៩ ដើម្បីវាយតម្លៃថាតើគួរតែមិនទទួលស្គាល់បំណុលហរិញ្ញវត្ថុ ដោយហេតុថាមានតែថ្លៃឈ្នួលដែលបានបង់ ឬទទួលស្គាល់រវាងអង្គភាព (អ្នកខ្ចី) និងអ្នកឱ្យខ្ចីរួមបញ្ចូលទាំងឈ្នួលដែលបានបង់ ឬទទួលក្នុងនាមបានដោយអង្គភាព ឬអ្នកឱ្យខ្ចីត្រូវបានរាប់បញ្ចូល។

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត)

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្តមុន៖(ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្មមានដូចខាងក្រោម៖(ត)

<u>ការកែលម្អប្រចាំឆ្នាំលើស្តង់ដារ ស.រ.ហ.អ.ក ២០១៨ - ២០២០(ត)</u>

ការកែលម្អប្រចាំឆ្នាំលើស្តង់ដារកែតម្រូវដូចខាងក្រោម៖(ត)

- ស.រ.ហ.អ.ក ១៦ *ភតិសន្យា* ធ្វើវិសោធនកម្មឧទាហរណ៍ទី ១៣ ដើម្បីលុបឧទាហរណ៍នៃការការសងត្រឡប់នៃការកែលំអអគារដោយភតិបតី ដើម្បីដោះស្រាយការភ័ន្តច្រឡំដែលអាចកើតមានទាក់ទងទៅនឹងប្រព្រឹត្តិកម្មនៃប្រាក់លើកទឹកចិត្តភតិសន្យា ដែលអាចកើតឡើងដោយសារតែការប្រាក់លើកទឹកចិត្តភតិសន្យាត្រូវបានបង្ហាញនៅក្នុងឧទាហរណ៍នោះ និង
- ស.គ.អ.ក ៤១ *កសិកម្ម* ដើម្បីដកចេញនូវតម្រូវការក្នុងការមិនរាប់បញ្ចូលលំហូរសាច់ប្រាក់ពន្ធ នៅពេលវាយតម្លៃសមរម្យនៃទ្រព្យសកម្មជីវសាស្ត្រដោយប្រើបច្ចេកទេសនៃការគណនាតម្លៃបច្ចុប្បន្ន។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ឯកសារយោងទៅនឹងក្របខណ្ឌគណនេយ្យ*</u>

ការធ្វើវិសោធនកម្មត្រូវបានធ្វើឡើងចំពោះស្តង់ដារគណនេយ្យផ្សេងៗដើម្បីឆ្លុះបញ្ចាំងពីបញ្ហានៃ *ក្របខណ្ឌគណនេយ្យសម្រាប់របាយការណ៍ហិរញ្ញវត្ថុ* និងត្រូវបានអនុវត្តចំពោះអង្គភាពដែលរកប្រាក់ចំណេញដែលមានភាពទទួលខុសត្រូវចំពោះសង្គម និងត្រូវបានតម្រូវដោយច្បាប់ដើម្បីអនុលោមតាម ស.រ.ហ.អ.ក និងអង្គភាពសម្រាប់ផលចំណេញផ្សេងទៀតដែលជ្រើសរើសអនុវត្ត ក្របខណ្ឌគណនេយ្យសម្រាប់រយៈពេលរាយការណ៍ប្រចាំឆ្នាំចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

<u>វិសោធនកម្មលើ ស.គ.អ.ក ១៦ *ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ - ចំណូលពីការលក់មុននឹងមានបំណងក្នុងការប្រើប្រាស់*</u>

ការធ្វើវិសោធនកម្មលើស.គ.អ.ក ១៦ *ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ* ហាមឃាត់ការដកថ្លៃដើមនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលចំណូលពីការលក់របស់របរដែលបានផលិតខណៈពេលដែលនាំយកទ្រព្យសម្បត្តិនោះទៅទីតាំង និងលក្ខខណ្ឌចាំបាច់ដើម្បីឱ្យមានប្រតិបត្តិការតាមការគ្រោងទុកដោយអ្នកគ្រប់គ្រង។ ផ្ទុយទៅវិញ ចំណូលពីការលក់របស់របរទាំងនោះ និងថ្លៃដើមនៃការផលិតរបស់របរទាំងនោះត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

<u>វិសោធនកម្មលើ ស.គ.អ.ក ៣៧ *កិច្ចសន្យាស្មុគស្មាញ - ចំណាយនៃការបំពេញកិច្ចសន្យា*</u>

ការធ្វើវិសោធនកម្មលើ ស.គ.អ.ក ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ដើម្បីបញ្ជាក់ថា "ចំណាយបំពេញ" កិច្ចសន្យាមួយមាន "ថ្លៃដើមដែលទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចសន្យា"។ ថ្លៃដើមដែលទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចសន្យា អាចជាថ្លៃដើមបន្ថែមនៃការបំពេញកិច្ចសន្យានោះ (ឧទាហរណ៍ កម្លាំងពលកម្ម និងសម្ភារៈ) ឬការបែងចែកថ្លៃដើមផ្សេងៗដែលទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចសន្យាដែលបានបំពេញ (ឧទាហរណ៍ ការបែងចែកថ្លៃរំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងឧបករណ៍ប្រើប្រាស់ក្នុងការបំពេញកិច្ចសន្យា)។

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤



## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន (ត)

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្តមុន៖(ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្មមានដូចខាងក្រោម៖(ត)

<u>វិសោធនកម្មលើ ស.គ.អ.ក ១ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង*</u>

ស.គ.អ.ក. ១ *ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* ត្រូវបានកែប្រែទៅ៖

- បញ្ជាក់ថាការចាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែងមិនមែនផ្អែកលើសិទ្ធិដែលមាននៅចុងការិយបរិច្ឆេទនៃរបាយការណ៍
- បញ្ជាក់ថាការចាត់ថ្នាក់មិនត្រូវបានប៉ះពាល់ ដោយភាពជឿជាក់ថាតើអង្គភាពមួយនឹងអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការពន្យាពេលនៃការទទួលខុសត្រូវ
- ពន្យល់ថាសិទ្ធិកើតមានឡើង ប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្តនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ និង
- ណែនាំឱ្យបានស្គាល់និយមន័យនៃ "ការទូទាត់" ដើម្បីធ្វើឱ្យច្បាស់ថាការទូទាត់សំដៅទៅលើការផ្ទេរទៅសមភាគីនៃសាច់ប្រាក់ ឧបករណ៍មូលធន ទ្រព្យសម្បត្តិ ឬសេវាកម្មផ្សេងៗ។

<u>ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង*</u>

ស.រ.ហ.អ.ក ១៧ ត្រូវបានជំនួសឱ្យ ស.រ.ហ.អ.ក ៤ និងតម្រូវឱ្យវាស់វែងតាមតម្លៃបច្ចុប្បន្ន ដែលការប៉ាន់ស្មានត្រូវបានវាស់វែងឡើងវិញនៃពេលរបាយការណ៍នីមួយៗ។

កិច្ចសន្យាត្រូវបានវាស់វែងដោយប្រើ៖

- អប្បហានៃប្រូបាប៊ីលីតេលំហូរសាច់ប្រាក់
- និយ័តកម្មហានិភ័យជាក់លាក់ និង
- ចំណេញនៃសេវាកិច្ចសន្យា ("CSM") ដែលតំណាងឱ្យកិច្ចសន្យានៃប្រាក់ចំណេញដែលមិនទាន់បានទទួលស្គាល់ ដែលត្រូវបានគេទទួលស្គាល់ថាជាប្រាក់ចំណូលក្នុងកំឡុងពេលនៃការធានារ៉ាប់រង។

ស្តង់ដារអនុញ្ញាតឱ្យមានជម្រើសរវាងការទទួលស្គាល់ ការផ្លាស់ប្តូរតាមអត្រាអប្បហានៅក្នុងរបាយការណ៍ចំណូល ឬទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណូលផ្សេងៗទៀត។ ជម្រើសនេះ គឺទំនងជាឆ្លុះបញ្ចាំងពីរបៀបដែលក្រុមហ៊ុនធានារ៉ាប់រងបកស្រាយពី ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនក្រោម ស.រ.ហ.អ.ក ៩។

ជម្រើសម្យ៉ាងទៀត គឺវិធីសាស្ត្របែងចែកបុព្វលាភ ត្រូវបានអនុញ្ញាតសម្រាប់បំណុលសម្រាប់ការធានារ៉ាប់រងដែលនៅសល់សម្រាប់កិច្ចសន្យារយៈពេលខ្លីដែលត្រូវបានសរសេរដោយក្រុមហ៊ុនធានារ៉ាប់រងទូទៅ។

ការផ្លាស់ប្តូរគំរូនៃការវាស់ស្ទង់ទូទៅដែលគេហៅថា "វិធីសាស្ត្រតំលៃអថេរ" សម្រាប់កិច្ចសន្យាមួយចំនួនដែលបានបង្ហាញលើការធានារ៉ាប់រងមានជីវិត ដែលអ្នកធ្វើគោលនយោបាយ ចែករំលែកជាការទទួលបានមកវិញនូវតម្លៃមូលដ្ឋាន។ នៅពេលអនុវត្តវិធីកំណត់តម្លៃអថេរ ការប្រែប្រួលតម្លៃទីផ្សារនៃភាគហ៊ុនក្រុមហ៊ុននៃតម្លៃមូលដ្ឋាន ត្រូវបានរួមបញ្ចូលនៅក្នុងចំណេញកម្រិតនៃកិច្ចសន្យាសេវា។ ជាលទ្ធផលក្រុមហ៊ុនធានារ៉ាប់រងដែលប្រើប្រាស់វិធីសាស្ត្រនេះទំនងជាមិនសូវប្រែប្រួលខ្លាំងជាងវិធីសាស្ត្រទូទៅទេ។

ច្បាប់ថ្មីនេះ នឹងប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ និងសូចនាករលទ្ធផលសំខាន់ៗរបស់ក្រុមហ៊ុនទាំងអស់ដែលបានចេញកិច្ចសន្យាធានារ៉ាប់រង ឬកិច្ចសន្យាវិនិយោគដែលមានលក្ខណៈពិសេសនៃការចូលរួម។

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤

១៧

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត)

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្តមុន៖(ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្មមានដូចខាងក្រោម៖(ត)

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង*</u>

វិសោធនកម្មលើ ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* ធ្វើការពន្យារកាលបរិច្ឆេទដែលចូលជាធរមានចាប់ពីរយៈពេលប្រចាំឆ្នាំចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ទៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ សម្រាប់អង្គភាពដែលបានជ្រើសរើសដើម្បីពន្យាពេល ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ* កាលបរិច្ឆេទដែលចាំបាច់ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។

IASB បានធ្វើវិសោធនកម្ម ស.រ.ហ.អ.ក ១៧ ដូចជា៖

- កាត់បន្ថយការចំណាយ (តម្រូវការមួយចំនួនត្រូវបានធ្វើឱ្យសាមញ្ញដើម្បីកាត់បន្ថយការចំណាយដូចជាការចំណាយលើការអភិវឌ្ឍប្រព័ន្ធ);
- ធ្វើឱ្យលទ្ធផលកាន់តែងាយស្រួលពន្យល់; និង
- សម្រួលការផ្លាស់ប្តូរ (កាលបរិច្ឆេទកម្មវិធីដែលបានពន្យាពេលផ្តល់ឱ្យក្រុមហ៊ុនធានារ៉ាប់រងពេលវេលាបន្ថែមទៀតសម្រាប់ការអនុម័តលើកដំបូង ស.រ.ហ.អ.ក ១៧ និងនៅក្នុងករណីមួយចំនួន ស.រ.ហ.អ.ក ៩ ផងដែរ និងផ្តល់នូវការសង្គ្រោះការផ្លាស់ប្តូរបន្ថែមទៀតដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃអនុវត្ត ស.រ.ហ.អ.ក ១៧ ជាលើកដំបូង) ។

<u>វិសោធនកម្មលើ ស.ក.អ.ហ.រ. ៤ *កិច្ចសន្យាធានារ៉ាប់រង - ការពង្រីកការលើកលែងជាបណ្តោះអាសន្នពីការអនុវត្ត ស.ក.អ.ហ.រ. ៩*</u>

ស.រ.ហ.អ.ក ៤ ត្រូវបានធ្វើវិសោធនកម្មដើម្បីតម្រូវឱ្យអ្នកធានារ៉ាប់រងអនុវត្តការលើកលែងជា បណ្តោះអាសន្នពី ស.ក.អ.ហ.រ.៩ (ឧទាហរណ៍៖ ក្រុមហ៊ុនធានារ៉ាប់រងទាំងនោះដែលបន្តអនុវត្ត ស.រ.ហ.អ.ក ៣៩) ដើម្បីអនុវត្ត ការអនុវត្តន៍ជាក់ស្តែងដូចគ្នានឹងអង្គភាពដែលអនុវត្ត ស.រ.ហ.អ.ក ៩)។

<u>*ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក ១ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ)*</u>

ការធ្វើវិសោធនកម្មលើ ស.គ.អ.ក ១ តម្រូវឱ្យក្រុមហ៊ុនបង្ហាញព័ត៌មានអំពីគោលនយោបាយគណនេយ្យដែលសារវន្ត ជាជាងគោលនយោបាយគណនេយ្យសំខាន់ៗរបស់ក្រុមហ៊ុន ។

<u>*ការលាតត្រដាងការប៉ាន់ស្មានគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក ៨ គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង)*</u>

ការធ្វើវិសោធនកម្មនេះបញ្ជាក់ពីរបៀបដែលក្រុមហ៊ុនគួរតែសម្គាល់ការផ្លាស់ប្តូរ គោលនយោបាយគណនេយ្យ ពីការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានគណនេយ្យ ។ ភាពខុសគ្នានោះ គឺមានសារៈសំខាន់ដោយសារតែការផ្លាស់ប្តូរនៃការប៉ាន់ស្មានគណនេយ្យ ត្រូវបានអនុវត្តតែចំពោះប្រតិបត្តិការ និងព្រឹត្តិការណ៍នាពេលអនាគតផ្សេងទៀតប៉ុណ្ណោះ ប៉ុន្តែការផ្លាស់ប្តូរគោលនយោបាយគណនេយ្យជាទូទៅ ក៏ត្រូវបានអនុវត្តឡើងវិញទៅលើ ប្រតិបត្តិការកន្លងមក និងព្រឹត្តិការណ៍កាលពីមុនផ្សេងទៀត ។

<u>*ពន្ធពន្យាទាក់ទងនឹងទ្រព្យសកម្ម និងបំណុល ដែលកើតឡើងពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ ស.គ.អ.ក ១២)*</u>

វិសោធនកម្មបានបង្រួមវិសាលភាពនៃការលើកលែងការទទួលស្គាល់ក្នុងកថាខណ្ឌទី ១៥ និង ២៤ នៃ ស.គ.អ.ក ១២ (ការលើកលែងការទទួលស្គាល់) ដូច្នេះវាមិនអនុវត្តចំពោះប្រតិបត្តិការ ដែលនៅលើការទទួលស្គាល់ដំបូងផ្តល់នូវភាពខុសគ្នាបណ្តោះអាសន្នដែលត្រូវបង់ពន្ធ និងកាត់ទុកស្មើគ្នា។

## ៣. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន (ត)

ខាងក្រោមនេះគឺជាស្តង់ដារគណនេយ្យ និងវិសោធនកម្ម ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ភ ពុំទាន់បានអនុវត្តមុន៖(ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ និងវិសោធនកម្មមានដូចខាងក្រោម៖(ត)

វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.ក.អ.គ. ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាងសហគ្រិន និងញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន*

ការធ្វើវិសោធនកម្មនេះបញ្ជាក់ពីវិសាលភាពនៃការចំណេញ ឬខាតដែលត្រូវទទួលស្គាល់ នៅពេលដែលអង្គភាពលក់ ឬដាក់ទុនជាទ្រព្យសម្បត្តិទៅញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន។ នៅពេលប្រតិបត្តិការទាក់ទងទៅនឹងអាជីវកម្មចំណេញ ឬខាតត្រូវបានទទួលស្គាល់ទាំងស្រុង នៅពេលដែលប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ដែលមិន ឬរួមចំណែកក្នុងអាជីវកម្ម ចំណេញ ឬខាតត្រូវបានទទួលស្គាល់តែចំពោះផលប្រយោជន៍របស់វិនិយោគិនដែលមិនពាក់ព័ន្ធនឹងក្រុមហ៊ុនរួមទុន ឬញាតិសម្ព័ន្ធ។

## ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១<br>ដុល្លារអាមេរិក | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០<br>ដុល្លារអាមេរិក |
|---|---|---|
| ***ថ្លៃដើម*** | | |
| សមតុល្យដើមគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ១១០.២២៦.០៥៣ | ៩៦.៤១៤.៦៩១ |
| ការទិញបន្ថែម | ១០.៤៩១.៣១៣ | ១៤.១៣២.៧៩៨ |
| ការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | - | (១៩៥.៥៣៥) |
| ការជម្រះចេញពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | - | (១២៥.៩០១) |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ១២០.៧១៧.៣៦៦ | ១១០.២២៦.០៥៣ |
| ***រំលស់បង្គរ*** | | |
| សមតុល្យដើមគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ២១.៣៩៦.១៩០ | ១៨.៨៤៦.១៣៥ |
| រំលស់ក្នុងគ្រា/ឆ្នាំ | ២.៣១៣.៧៩២ | ២.៦៨៣.៣៥៣ |
| ការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | - | (១៣៣.២៩៨) |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ២៣.៧០៩.៩៨២ | ២១.៣៩៦.១៩០ |
| **តម្លៃពិតគណនេយ្យ** | | |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៩៧.០០៧.៣៨៤ | ៨៨.៨២៩.៨៦៣ |
| *(គិតជាពាន់រៀល)* | *៣៩៥.៦៩៣.១១៩* | *៣៥៩.៣១៦.៧៩៦* |

## ៥. សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងបំណុលពីការជួល កើតឡើងពីការជួលដីរយៈពេល ៤០ ឆ្នាំពីក្រុមហ៊ុន ហ្វ្រីនត្រេដ ខូអិលធីឌី។

ការជួលត្រូវទទួល កើតឡើងពីការជួលដីដែលមានរយៈពេល ៤០ឆ្នាំ ទៅក្រុមហ៊ុន ហ៊្វួយ បាង អ៊ិនធើណេសិនណាល អ៊ីនវេសមេនគ្រុប ខូអិលធីឌី និងមេគង្គ អូរីហ្សា ត្រេឌីង ខូអិលធីឌី។

## ៦. ទ្រព្យសម្បត្តិវិនិយោគ

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១<br>ដុល្លារអាមេរិក | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០<br>ដុល្លារអាមេរិក |
|---|---|---|
| ***ថ្លៃដើម*** | | |
| សមតុល្យដើមគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៨៥.១៨៦.០១៥ | ៨៥.៣១៨.៨១០ |
| ការជម្រុះចេញពីបញ្ជីនៃទ្រព្យសម្បត្តិវិនិយោគ | - | (១៣២.៧៩៥) |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៨៥.១៨៦.០១៥ | ៨៥.១៨៦.០១៥ |
| ***រំលស់បង្គរ*** | | |
| សមតុល្យដើមគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៤៩៩.០១៥ | ៤៦៤.៦៦៤ |
| រំលស់ក្នុងគ្រា | ៤៥.៦៧០ | ៦៣.៤២០ |
| ការជម្រុះចេញពីបញ្ជីនៃទ្រព្យសម្បត្តិវិនិយោគ | - | (២៩.០៦៩) |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៥៤៤.៦៨៥ | ៤៩៩.០១៥ |
| **តម្លៃពិតគណនេយ្យ** | | |
| សមតុល្យចុងគ្រានៃកំឡុងការិយបរិច្ឆេទ/ឆ្នាំ | ៨៤.៦៤១.៣៣០ | ៨៤.៦៨៧.០០០ |
| *(គិតជាពាន់រៀល)* | *៣៤៥.២៥១.៩៨៥* | *៣៤២.៥៥៨.៩១៥* |

## ៧. គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ

| | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| ប្រាក់កក់ | ៦៧.៥៨៥ | ២៧៥.៦៧៩ | ៦៤.៩៨៦ | ២៦២.៨៦៨ |
| **រយៈពេលខ្លី** | | | | |
| **គណនីពាណិជ្ជ** | | | | |
| ភាគីទីបី | ៥.៨៧៨.៦៥៧ | ២៣.៩៧៩.០៤២ | ៤.០៩០.៩៣៨ | ១៦.៥៤៧.៨៤៤ |
| ដក៖ ឱនភាព | | | | |
| ភាគីទីបី | (៩៤២.៩០៤) | (៣.៨៤៦.១០៦) | (៨៧២.១០១) | (៣.៥២៧.៦៤៨) |
| | ៤.៩៣៥.៧៥៣ | ២០.១៣២.៩៣៦ | ៣.២១៨.៨៣៧ | ១៣.០២០.១៩៦ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| ភាគីទីបី | ៦.០៧២.០៦៧ | ២៤.៧៦៧.៩៦១ | ៦.៤៩៩.៨១៧ | ២៦.២៩១.៧៦០ |
| បុរេប្រទាន | ១៤៦.១៤៤ | ៥៩៦.១២១ | ៨៣.៧៥៣ | ៣៣៨.៧៨១ |
| បញ្ញើ | ១៤៩.១៩២ | ៦០៨.៥៥៤ | ២០៨.៨៧០ | ៨៤៤.៨៧៩ |
| គណនីត្រូវទទួលផ្សេងៗ | ៣៩១.២៤៤ | ១.៥៩៥.៨៨៤ | ២៦៧.៧៥៦ | ១.០៨៣.០៧៣ |
| | ៦.៧៥៨.៦៤៧ | ២៧.៥៦៨.៥២០ | ៧.០៦០.១៩៦ | ២៨.៥៥៨.៤៩៣ |
| **គណនីពាណិជ្ជសរុប** | ១១.៦៩៤.៤០០ | ៤៧.៧០១.៤៥៦ | ១០.២៧៩.០៣៣ | ៤១.៥៧៨.៦៨៧ |
| ការបង់មុន | ៥៤៩.៧៤២ | ២.២៤២.៣៩៩ | ៤៤៥.៦៤០ | ១.៨០២.៦១៤ |
| | ១២.២៤៤.១៤២ | ៤៩.៩៤៣.៨៥៥ | ១០.៧២៤.៦៧៣ | ៤៣.៣៨១.៣០២ |

## ៨. ពន្ធពន្យារ

បម្រែបម្រួលគណនីពន្ធពន្យារ មានដូចខាងក្រោម៖

| | គិតត្រឹមថ្ងៃទី ១ មករា ២០២១ ដុល្លារអាមេរិក | កត់ត្រាជាបន្ទុកក្នុង របាយការណ៍ ចំណេញ-ខាត ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០២១ ដុល្លារអាមេរិក (មិនបានធ្វើសវនកម្ម) |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (២.៧០២.៩៥៩) | ១៧.០៣១ | (២.៦៨៥.៩២៨) |
| កាតព្វកិច្ចសោធននិវត្តន៍ | ១០៨.៣៥៩ | (៣.២០៣) | ១០៥.១៥៦ |
| ចំណូលពន្ធពន្យារ | ២.៨៥០.០០០ | - | ២.៨៥០.០០០ |
| ឱនភាពលើគណនីពាណិជ្ជ | ១៧៤.៤២០ | ១៤.១៦១ | ១៨៨.៥៨១ |
| ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | ១០.១៧១ | (២០.០០៧) | (៩.៨៣៦) |
| | ៤៣៩.៩៩១ | ៧.៩៨២ | ៤៤៧.៩៧៣ |
| *(គិតជាពាន់រៀល)* | | | *១.៨២៧.២៨២* |

| | គិតត្រឹមថ្ងៃទី១ មករា ២០២០ ដុល្លារអាមេរិក | កត់ត្រាជាបន្ទុកក្នុង របាយការណ៍ ចំណេញ-ខាត ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០២០ ដុល្លារអាមេរិក (បានធ្វើសវនកម្ម) |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (២.២៦៥.០២៨) | (៤៣៧.៩៣១) | (២.៧០២.៩៥៩) |
| កាតព្វកិច្ចសោធននិវត្តន៍ | ១២២.៦៨៥ | (១៤.៣២៦) | ១០៨.៣៥៩ |
| ចំណូលពន្ធពន្យារ | ២.៩១៦.២០២ | (៦៦.២០២) | ២.៨៥០.០០០ |
| ឱនភាពគណនីពាណិជ្ជ | ១០២.៩៧៣ | ៧១.៤៤៧ | ១៧៤.៤២០ |
| ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | ១.៦៣២ | ៨.៥៣៩ | ១០.១៧១ |
| | ៨៧៨.៤៦៤ | (៤៣៨.៤៧៣) | ៤៣៩.៩៩១ |
| *(គិតជាពាន់រៀល)* | | | *១.៧៧៩.៧៦៤* |

## ៩. សាច់ប្រាក់ និងសមតុល្យនៅធនាគារ

| | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ៥.៨៤៦ | ២៣.៨៤៦ | ៣.៨០៧ | ១៥.៣៩៩ |
| សាច់ប្រាក់នៅធនាគារ | ៣.៣៥៨.៩៤៨ | ១៣.៧០១.១៤៩ | ២.៦៨០.០៣៤ | ១០.៨៤០.៧៣៨ |
| ប្រាក់បញ្ញើ | ១១.០០១.៥៩៧ | ៤៤.៨៧៥.៥១៤ | ១៥.០០០.០០០ | ៦០.៦៧៥.០០០ |
| កំណត់បង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១៤.៣៦៦.៣៩១ | ៥៨.៦០០.៥០៩ | ១៧.៦៨៣.៨៤១ | ៧១.៥៣១.១៣៧ |
| ដកៈ | | | | |
| ប្រាក់បញ្ញើ (កាលកំណត់ច្រើនជាង៣ខែ) | (១១.០០១.៥៩៧) | (៤៤.៨៧៥.៥១៤) | (១៥.០០០.០០០) | (៦០.៦៧៥.០០០) |
| កំណត់បង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ | ៣.៣៦៤.៧៩៤ | ១៣.៧២៤.៩៩៥ | ២.៦៨៣.៨៤១ | ១០.៨៥៦.១៣៧ |

## ១០. ដើមទុន

| | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ចំនួន | ដុល្លារអាមេរិក | ចំនួន | ដុល្លារអាមេរិក |
| ភាគហ៊ុនបោះឆ្នោត នៃ ១ដុល្លារអាមេរិកៈ | | | | |
| ប្រភេទ ក | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ | ៤.១៣៦.៨៧៣ |
| ប្រភេទ ខ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ |
| | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ភាគហ៊ុនមិនបោះឆ្នោត នៃ ១ដុល្លារអាមេរិកៈ | | | | |
| ប្រភេទ គ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ | ៩៣.៧៦៩.១២០ |
| | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ | ១១៤.៤៥៣.៤៨៥ |
| *(គិតជាពាន់រៀល)* | | *៤៥៧.៨១៣.៩៤០* | | *៤៥៧.៨១៣.៩៤០* |

ភាគហ៊ុនិកប្រភេទ "ក" នឹងទទួលបានការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹង ៥%ក្នុង១ឆ្នាំ ដោយគិតតាមថ្លៃលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ សម្រាប់រយៈពេលយ៉ាងហោច ៥ ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ ២០២០។ តម្លៃបច្ចុប្បន្ននៃការធានាបង់ភាគលាភនេះ មានចំនួន ៩៣៦.១៤៥ ដុល្លារអាមេរិក ហើយត្រូវបានរំពឹងទុកថានឹងធ្វើការទូទាត់ក្នុងរយៈពេល ៥ឆ្នាំ។

ភាគហ៊ុនិកប្រភេទ "គ" ពុំមានសិទ្ធិទទួលបាននូវភាគលាភពី ក.ស.ភ នោះទេ ប៉ុន្តែមានសិទ្ធិអាទិភាពក្នុងការទទួលបានទ្រព្យសម្បត្តិរបស់ ក.ស.ភ នៅក្នុងករណីដែលក្រុមហ៊ុនជម្រះបញ្ជី។

## ១១. បុព្វលាភភាគហ៊ុន

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ ទទួលបានជោគជ័យនៅការចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា ("ផ.ម.ក")។ ចំនួនភាគហ៊ុនសរុប (មានសិទ្ធិបោះឆ្នោត) មានចំនួន ២០.៦៨៤.៣៦៥ភាគហ៊ុន ដែលមាន ៤.១៣៦.៨៧៣ ជាភាគហ៊ុនប្រភេទ "ក" ដែលមានតម្លៃចារឹក ៤.០០០រៀលក្នុងមួយភាគហ៊ុន។ បន្ទាប់ពីបានចុះបញ្ជី ចំនួន៨០%នៃភាគហ៊ុនសរុប ត្រូវបានកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក.ស.ភ បានទទួលសាច់ប្រាក់ពីការលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈបានចំនួន ៥.១៩៣.៩១៥ដុល្លារអាមេរិក និង ចំណាយប្រតិបត្តិការចំនួន ៩០១.៥៤០ដុល្លារអាមេរិក។

បុព្វលាភភាគហ៊ុន សំដៅលើចំនួនទឹកប្រាក់លើសពីតម្លៃចារឹកនៃភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនទទួលបានពីការបោះផ្សាយលក់ភាគហ៊ុន និងបន្ទាប់ពីកាត់កងនូវចំណាយប្រតិបត្តិការផ្សេងៗ ដែលកើតចេញផ្ទាល់ពីការបោះផ្សាយភាគហ៊ុន។

## ១២. ទុនបម្រុង

| | ទុនបម្រុងតាមច្បាប់<br>ដុល្លារអាមេរិក | ទុនបម្រុងទូទៅ<br>ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍<br>សហគ្រាស<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| **ថ្ងៃទី១ មករា ២០២១** | **២.០៤៦.០១០** | **២.០៤៦.០១០** | **៣២.៤៤៧.៥៨៦** | **៣៦.៥៣៩.៦០៦** |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក | ៤៩៣.០៤៤ | ៤៩៣.០៤៤ | ៨.៣៣៥.៦៨៦ | ៩.៣២១.៧៧៤ |
| **ថ្ងៃទី៣០ កញ្ញា ២០២១(មិនបានធ្វើសវនកម្ម)** | **២.៥៣៩.០៥៤** | **២.៥៣៩.០៥៤** | **៤០.៧៨៣.២៧២** | **៤៥.៨៦១.៣៨០** |
| *(គិតជាពាន់រៀល)* | ១០.៣៥៦.៨០១ | ១០.៣៥៦.៨០១ | ១៦៦.៣៥៤.៩៦៧ | ១៨៧.០៦៨.៥៦៩ |
| **ថ្ងៃទី១ មករា ២០២០** | ១.៤៦៨.៤៤០ | ១.៤៦៨.៤៤០ | ២២.៧១៤.៥៣៩ | ២៥.៦៥១.៤១៩ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក | ៥៧៧.៥៧០ | ៥៧៧.៥៧០ | ៩.៧៣៣.០៤៧ | ១០.៨៨៨.១៨៧ |
| **ថ្ងៃទី៣១ ធ្នូ ២០២០ (បានធ្វើសវនកម្ម)** | **២.០៤៦.០១០** | **២.០៤៦.០១០** | **៣២.៤៤៧.៥៨៦** | **៣៦.៥៣៩.៦០៦** |
| *(គិតជាពាន់រៀល)* | *៨.២៧៦.១១០* | *៨.២៧៦.១១០* | *១៣១.២៥០.៤៨៥* | *១៤៧.៨០២.៧០៥* |

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តនូវការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងផ្សេងៗ ចំនួន ៩.៣២១.៧៧៤ដុល្លារអាមេរិក។

យោងតាមលក្ខន្តិកៈរបស់ ក.ស.ភ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០១៦ ត្រង់ប្រការ៦៦ បានចែងថាប្រាក់ចំណេញរបស់ ក.ស.ភ បន្ទាប់ពីកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ទុនបម្រុងតាមច្បាប់ ៥%
- សម្រាប់ទុនបម្រុងទូទៅ ៥%
- សមតុល្យនៅសល់សម្រាប់ភាគលាភ និងមូលនិធិសម្រាប់អភិវឌ្ឍន៍សហគ្រាស

## ១៣. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| **គណនីត្រូវបង់ផ្សេងៗ** | | | | |
| ប្រាក់កក់ | ៣៣.៧៩៣ | ១៣៧.៨៤២ | ៣២.៤៩៣ | ១៣១.៤៣៤ |
| **រយៈពេលខ្លី** | | | | |
| **គណនីអ្នកផ្គត់ផ្គង់** | | | | |
| ភាគីទីបី | ១.១៣៨.៥៨៩ | ៤.៦៤៤.៣០៥ | ២៨២.៦៣១ | ១.១៤៣.២៤២ |
| **គណនីត្រូវបង់ផ្សេងៗ** | | | | |
| ការប្រាក់ត្រូវបង់ | ៩៤.២៩៩ | ៣៨៤.៦៤៦ | ៣៣៦.៤៨៦ | ១.៣៦១.០៨៦ |
| ប្រាក់កក់ | ២៥៧.១៨៤ | ១.០៤៩.០៥៤ | ៣៨៤.៧៨២ | ១.៥៥៦.៤៤៣ |
| ភាគលាភធានាត្រូវបង់ | - | - | ២៦១.៨១៤ | ១.០៥៩.០៣៨ |
| ពន្ធត្រូវបង់ផ្សេងៗ | ២២៩.៥៥២ | ៩៣៦.៣៤៣ | ៧៨.៣៩៦ | ៣១៧.១១២ |
| បំណុលត្រូវបង់ផ្សេងៗ | ១.២១៤.៦៣០ | ៤.៩៥៤.៤៧៦ | ១.៧១១.២៩១ | ៦.៩២២.១៧១ |
| | ១.៧៩៥.៦៦៥ | ៧.៣២៤.៥១៩ | ២.៧៧២.៧៦៩ | ១១.២១៥.៨៥០ |
| | ២.៩៣៤.២៥៤ | ១១.៩៦៨.៨២៤ | ៣.០៥៥.៤០០ | ១២.៣៥៩.០៩២ |

## ១៤. ប្រាក់កម្ចី

| | មិនបានធ្វើសវនកម្ម ៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម ៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| ចំណតផែកុងតឺន័រ LM១៧ | ១៨.៦២៩.៧៦៧ | ៧៥.៩៩០.៨២០ | ២០.៦៩៩.៧៤១ | ៨៣.៧៣០.៤៥២ |
| **រយៈពេលខ្លី** | | | | |
| ចំណតផែកុងតឺន័រ LM១៧ | ២.០៦៩.៩៧៤ | ៨.៤៤៣.៤២៤ | ២.០៦៩.៩៧៤ | ៨.៣៧៣.០៤៥ |
| | ២០.៦៩៩.៧៤១ | ៨៤.៤៣៤.២៤៤ | ២២.៧៦៩.៧១៥ | ៩២.១០៣.៤៩៧ |

ចំណតផែកុងតឺន័រ LM១៧ តំណាងឱ្យកិច្ចព្រមព្រៀងខ្ចីបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក.ស.ភ សម្រាប់ការខ្ចីប្រាក់បានមកពី The Import-Export Bank of China ("the Eximbank") ស្ថិតនៅក្រោមកិច្ចព្រមព្រៀងកម្ចីឥណទានអតិថិជនដែលពេញចិត្ត (Preferred Buyer) លេខ (២០១០)២៩(១៣៦) នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ សម្រាប់ការសាងសង់ចំណតផែកុងតឺន័រ LM១៧។

## ១៤. ប្រាក់កម្ចី (ត)

ចំនួនទឹកប្រាក់ដែលបានប្រគល់ឱ្យ ក.ស.ភ ខ្ចីបន្តនេះ ត្រូវបានចាត់ទុកថាបានឱ្យ ក.ស.ភ នៅថ្ងៃដូចគ្នាតាមរូបិយប័ណ្ណ និងក្នុងចំនួនទឹកប្រាក់ដូចដែលបានបើកដោយធនាគារ Eximbank សម្រាប់កម្មវត្ថុផ្តល់ហិរញ្ញប្បទានដើម្បីអនុវត្តគម្រោង។ ក.ស.ភ បង់ការប្រាក់រៀងរាល់ពាក់កណ្តាលឆ្នាំម្តង ដោយអត្រាការប្រាក់ ៤%ក្នុង១ឆ្នាំ។ ប្រាក់កម្ចីបន្តនេះ គឺសម្រាប់រយៈពេល ២០ឆ្នាំ រួមបញ្ចូលទាំងថេរវេលាអនុគ្រោះមិនលើសពី ៧ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាកិច្ចព្រមព្រៀងកម្ចីនេះ។

## ១៥. សំវិធានធនលើមូលនិធិសោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **កាតព្វកិច្ចសោធននិវត្តន៍** | | | | |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៥៨៣.១២១ | ២.៣៧៨.៥៥១ | ៥៤១.៧៩៥ | ២.១៩១.៥៦១ |
| តម្លៃសមស្របនៃទ្រព្យតម្កល់ | - | - | - | - |
| | ៥៨៣.១២១ | ២.៣៧៨.៥៥១ | ៥៤១.៧៩៥ | ២.១៩១.៥៦១ |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) | ៩៣.៧០៨ | ៣៨២.២៣៤ | ៧៤.៦២៧ | ៣០១.៨៦៨ |
| បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦៧៦.៨២៩ | ២.៧៦០.៧៨៥ | ៦១៦.៤២២ | ២.៤៩៣.៤២៩ |

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងកំឡុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១ | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី១ ខែមករា | ៥៤១.៧៩៥ | ៦១៣.៤២៧ |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៥៧.៤៤១ | ៤៧.៨១៣ |
| ចំណាយការប្រាក់ | ៥៧.៤៤១ | ៣៥.៩១០ |
| អត្ថប្រយោជន៍បានបង់ | (១៥.៨៧៨) | (២៨.២៣២) |
| ការវាយតម្លៃឡើងវិញ | (៥៧.៦៧៨) | (១២៧.១២៣) |
| នាថ្ងៃទី៣០ កញ្ញា/ថ្ងៃទី៣១ ខែធ្នូ | ៥៨៣.១២១ | ៥៤១.៧៩៥ |
| *(គិតជាពាន់រៀល)* | ២.៣៧៨.៥៥១ | *២.១៩១.៥៦១* |

## ១៥. សំវិធានធនលើមូលនិធិសោធននិវត្តន៍ (ត)

បម្រែបម្រួលនៅក្នុងអត្ថប្រយោជន៍ផ្សេងទៀតដែលបានកំណត់ក្នុងកំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១<br>ដុល្លារអាមេរិក | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០<br>ដុល្លារអាមេរិក |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ៧៤.៦២៧ | ៤៩.០៨៨ |
| ចំណាយបន្ថែម | ១៩.០៨១ | ២៥.៥៣៩ |
| នាថ្ងៃទី៣០ កញ្ញា/ថ្ងៃទី៣១ ខែធ្នូ | ៩៣.៧០៨ | ៧៤.៦២៧ |
| *(គិតជាពាន់រៀល)* | *៣៨២.២៣៤* | *៣០១.៨៦៨* |

បម្រែបម្រួលនៅក្នុងអត្ថប្រយោជន៍ផ្សេងទៀតដែលបានកំណត់ក្នុងកំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **កាតព្វកិច្ចសោធននិវត្តន៍** | | | | |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៥៧.៤៤១ | ២៣៣.៥៥៥ | ១២.៥៥០ | ៥១.៤៥៥ |
| ចំណាយការប្រាក់ | ៥៧.៤៤១ | ២៣៣.៥៥៥ | ១២.៥៥០ | ៥១.៤៥៥ |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| ចំណាយបន្ថែម | ១៩.០៨១ | ៧៧.៥៨៤ | ១៩.១០១ | ៧៨.៣១៤ |
| | ១៣៣.៩៦៣ | ៥៤៤.៦៩៤ | ៤៤.២០១ | ១៨១.២២៤ |

## ១៦. កិច្ចសន្យាបំណុល

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **បំណុលរយៈពេលវែង** | | | | |
| ចំណូលពន្យារ | ១៣.៧២៥.០០០ | ៥៥.៩៨៤.២៧៥ | ១៣.៩៥០.០០០ | ៥៦.៤២៧.៧៥០ |
| **បំណុលរយៈពេលខ្លី** | | | | |
| ចំណូលពន្យារ | ៣០០.០០០ | ១.២២៣.៧០០ | ៣០០.០០០ | ១.២១៣.៥០០ |

## ១៧. គតិសន្យាមូលធន

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០២១ | | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ការចំណាយមូលធនទាក់ទងនឹងការទិញ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ៖ | | | | |
| បានចុះកិច្ចសន្យា ប៉ុន្តែមិនទាន់បានទទួល ពីអ្នកផ្គត់ផ្គង់ | ១.៧១២.០៧៦ | ៦.៩៨៣.៥៥៦ | ៨.១៩៨.៣៥២ | ៣៣.១៦២.៣៣៤ |

## ១៨. ចំណូល

| | មិនបានធ្វើសវនកម្ម<br>សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលលើកដាក់ក្រោមដងយោង | ៤.១០៨.៩៩២ | ១៦.៧២៥.១០៩ | ៣.៣៩២.២២១ | ១៣.៨៧៩.៦២២ |
| ចំណូលលើកដាក់លើទីលាន | ៣.២៨៣.៥៧០ | ១៣.៣៦៥.៨៣៩ | ២.៧៧០.៦៣៤ | ១១.៣៣៧.១៩៨ |
| ចំណូលពីកិច្ចការផែ | ៩៨៨.៦៧៩ | ៤.០២៤.៩៦៣ | ៩៤៩.១៤៧ | ៣.៨៨៥.៥៨៥ |
| ចំណូលពីច្រកទ្វារ | ២៧៨.៣៧២ | ១.១៣២.៩៧៩ | ២០២.៧៨៦ | ៨២៩.៧២៦ |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ២២៤.៤១៣ | ៩១៣.៦២៨ | ១៦៨.១១៩ | ៦៨៨.៥៨២ |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ២.៨០៩ | ១១.៤៣៤ | ១.៤៨៥ | ៦.០៦៨ |
| ចំណូលពីការរើរៀបទំនិញ | ៦.៥០៤ | ២៦.៥០៩ | ៧.៣០០ | ២៩.៨៨៩ |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ៥.៨៣៧ | ២៣.៨០០ | ៨.៧២១ | ៣៦.៣៥៩ |
| ចំណូលពីការដឹកជញ្ជូន | ១១០.៧៦៩ | ៤៥០.៩៨៦ | ៦៣.៦៣២ | ២៦០.៥១១ |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ៥៣.៥៨០ | ២១៨.៤៣១ | ១២.០០០ | ៤៩.០៧៨ |
| | ៩.០៦៣.៥២៥ | ៣៦.៨៩៣.៦៧៨ | ៧.៥៧៦.០៤៥ | ៣១.០០២.៦១៨ |

## ១៨. ចំណូល (ត)

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលលើកដាក់ក្រោមដងយោង | ១០.០៩១.៥៨១ | ៤១.០៣២.៣៦៨ | ៨.៨២១.៦៦២ | ៣៦.០១០.០២៤ |
| ចំណូលលើកដាក់លើទីលាន | ៨.២៣១.១៧៩ | ៣៣.៤៦៧.៩៧៤ | ៧.៣៤៨.៨៦២ | ២៩.៩៩៨.០៥៥ |
| ចំណូលពីកិច្ចការផែ | ២.៦៥៣.៤៤៥ | ១០.៧៨៨.៩០៧ | ២.៨១០.៣០៤ | ១១.៤៧១.៦៦១ |
| ចំណូលពីច្រកទ្វារ | ៦៥១.១៧២ | ២.៦៤៧.៦៦៥ | ៥២៨.៤២៩ | ២.១៥៧.០៤៧ |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៦១២.៥៧៧ | ២.៤៩០.៧៣៨ | ៥៥៤.៨៥២ | ២.២៦៤.៩០៦ |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ៦.៩៥៣ | ២៨.២៧១ | ២.៤១២ | ៩.៨៤៦ |
| ចំណូលពីការរើរៀបទំនិញ | ២៧.៨៣៨ | ១១៣.១៨៩ | ២២.៣៥០ | ៩១.២៣៣ |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ២៥.០៨៥ | ១០១.៩៩៦ | ១៣៥.៣១២ | ៥៥២.៣៤៤ |
| ចំណូលពីការវាស់ស្ទង់ | ៣.០០០ | ១២.១៩៨ | - | - |
| ចំណូលពីការដឹកជញ្ជូន | ៣១០.៥២៨ | ១.២៦២.៦០៧ | ១៩១.០៥៨ | ៧៧៩.៨៩៩ |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ២៤៥.៣៤០ | ៩៩៧.៥៥២ | ២៧.៧៤៧ | ១១៣.២៦៣ |
| | ២២.៨៥៨.៦៩៨ | ៩២.៩៤៣.៤៦៥ | ២០.៤៤២.៩៨៨ | ៨៣.៤៤៨.២៧៨ |

## ១៩. ថ្លៃដើមនៃការលក់ និងសេវាកម្ម

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដងយោង | ៦៩៩.៧៩៩ | ២.៨៤៨.៤០៥ | ៦៩៤.៤១៥ | ២.៨៤១.៤៤០ |
| រំលស់ | ៧០៧.៥៧៤ | ២.៨៨០.៥៩៣ | ៥៧២.៩៩៩ | ២.៣៤៥.៥២៩ |
| ប្រេងឥន្ធនៈ | ២៦៣.៨៦០ | ១.០៧៤.១៣១ | ២១៤.០២១ | ៨៧៦.៥១៨ |
| ប្រាក់បៀវត្ស និង ប្រាក់ឈ្នួល | ៤៤៩.១៥៧ | ១.៨២៨.៧៨៩ | ៤០៣.៩៨៦ | ១.៦៥៣.៧៥២ |
| ចំណាយការថែទាំ និង ជួសជុលកុងតឺន័រ | ២០៩.១០៣ | ៨៥០.២១៣ | ១៨០.៤៨៥ | ៧៣៩.៤៥៦ |
| ចំណាយលើសេវាភ័ស្តុភារកម្ម | ៦៦.២៧០ | ២៦៩.៤៥៤ | ១២.៤៤០ | ៥០.៨៩៣ |
| ចំណាយពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្ម ខ្សាច់ | ៤.៦២៥ | ១៨.៨០៥ | - | - |
| ចំណាយផ្សេងៗ | ១៨៧.២០៤ | ៧៦៤.៣៥០ | - | - |
| | ២.៥៨៧.៥៩២ | ១០.៥៣៤.៧៤០ | ២.០៧៨.៣៤៦ | ៨.៥០៧.៥៨៨ |

## ១៩. ថ្លៃដើមនៃការលក់ និងសេវាកម្ម (ត)

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដងយោង | ១.៧០៧.២៧៣ | ៦.៩៤១.៧៧២ | ១.៨៣៣.៩៨៥ | ៧.៤៨៦.៣២៧ |
| រំលស់ | ១.៩០៦.៧៥៨ | ៧.៧៥២.៨៧៨ | ១.៦៦៤.១៧៤ | ៦.៧៩៣.១៥៨ |
| ប្រេងឥន្ធនៈ | ៦៨៩.០៥៨ | ២.៨០១.៧១០ | ៦៩៤.៧៤៥ | ២.៨៣៥.៩៤៩ |
| ប្រាក់បៀវត្ស និង ប្រាក់ឈ្នួល | ១.២៨៨.០៦៧ | ៥.២៣៧.២៨០ | ១.១៨៤.០៩៣ | ៤.៨៣៣.៤៦៨ |
| ចំណាយការថែទាំ និង ជួសជុល | ៨៥៦.៨១០ | ៣.៤៨៣.៧៨៩ | ៥៤៦.៩៥៧ | ២.២៣២.៦៧៨ |
| ចំណាយឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ៤.៦២៥ | ១៨.៨០៥ | - | - |
| ចំណាយការថែទាំ និង ជួសជុលទូរកុងតឺន័រ | - | - | ៣៤៥ | ១.៤០៨ |
| ចំណាយលើសេវាភ័ស្តុភារកម្ម | ២៥៤.០៩០ | ១.០៣៣.១៣០ | ៣០.៩២៥ | ១២៦.២៣៥ |
| ចំណាយផ្សេងៗ | ៤១១.៦២៣ | ១.៦៧៣.៦៥៩ | ៨៦.៤៦១ | ៣៥២.៩៣៤ |
| | ៧.១១៨.៣០៤ | ២៨.៩៤៣.០២៣ | ៦.០៤១.៦៨៥ | ២៤.៦៦២.១៥៧ |

## ២០. ចំណូលផ្សេងៗ

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលពីការជួល | ២២១.១០១ | ៩០០.៣៦០ | ១៩៣.៧៩០ | ៧៩៣.៧២០ |
| ចំណូលពីការប្រាក់៖ | | | | |
| - ប្រាក់បញ្ញើជាមួយស្ថាប័នហិរញ្ញវត្ថុ | ២០១.៦០០ | ៨២១.១៧៧ | ៣០៨.៣៧៣ | ១.២៦២.២៦២ |
| - ថ្លៃជួលត្រូវទទួល | ៤៣.១៦១ | ១៧៥.៧៥១ | ៤៣.២៩៣ | ១៧៧.២៤២ |
| ចំណូលផ្សេងៗ | ១៧០.៨៣៣ | ៦៩៦.០៥១ | ៣៣.៨៤១ | ១៣៨.៩២៣ |
| | ៦៣៦.៦៩៥ | ២.៥៩៣.៣៣៩ | ៥៧៩.២៩៧ | ២.៣៧២.១៤៧ |

## ២០. ចំណូលផ្សេងៗ (ត)

៣០

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលពីការជួល | ៦៧៥.៤៥០ | ២.៧៤៦.៣៨០ | ៦៣៨.៥៨២ | ២.៦០៦.៦៩២ |
| ចំណូលពីការប្រាក់៖ | | | | |
| - ប្រាក់បញ្ញើជាមួយស្ថាប័នហិរញ្ញវត្ថុ | ៦៩២.០១១ | ២.៨១៣.៧១៧ | ៨៨៨.៩០៤ | ៣.៦២៨.៥០៦ |
| - ថ្លៃជួលត្រូវទទួល | ១២៩.៥៨៣ | ៥២៦.៨៨៤ | ១២៩.៩៧៤ | ៥៣០.៥៥៤ |
| ផលប៉ះពាល់នៃប្រាក់កក់ត្រូវបង់រយៈពេលវែង | ២.៥៩៩ | ១០.៥៦៨ | ២.៤៩៩ | ១០.២០១ |
| លុបចោលលើឱនភាពនៃការខាតបង់នៃ គណនីពាណិជ្ជដែលបានកត់ត្រា | ៣៤៤.៧០០ | ១.៤០១.៥៥០ | - | - |
| ចំណូលផ្សេងៗ | ៣០៤.៩០០ | ១.២៣៩.៧២៣ | ១៦១.៩២៩ | ៦៦០.៩៩៤ |
| | ២.១៤៩.២៤៣ | ៨.៧៣៨.៨២២ | ១.៨២១.៨៨៨ | ៧.៤៣៦.៩៤៧ |

## ២១. ចំណាយទូទៅ និងចំណាយរដ្ឋបាល

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ | ៩១២.៩៥៦ | ៣.៧១៨.២២២ | ៩៩៣.៣០១ | ៤.០៦៦.៨៤៤ |
| ចំណាយទឹក ភ្លើង និង ប្រេងឥន្ធនៈ | ១៣៦.៩៨៨ | ៥៥៧.៧៥២ | ១១១.៣៤៨ | ៤៥៥.៩២៣ |
| រំលស់ | ១៧៦.៩៩១ | ៧១៩.៦៤៥ | ១៣២.៩៩០ | ៥៤៤.១៦៧ |
| កម្រៃសម្រាប់ក្រុមប្រឹក្សាភិបាល | ៦១.៨១៥ | ២៥១.៧១២ | ៦១.៥៨៨ | ២៥២.១៩៥ |
| អំណោយសទ្ធាទាន | ៩៥.៣០៤ | ៣៨៧.៨៩៩ | ១៨៦.២១២ | ៧៦០.៩៧៤ |
| ចំណាយផ្គត់ផ្គង់សម្ភារៈការិយាល័យ | ៧២.៣៧៨ | ២៩៤.៥២២ | ៥៨.៣៤២ | ២៣៨.៨៨៤ |
| ចំណាយលើការកំសាន្ត | ២៣.០៤៥ | ៩៣.៨៣៩ | ៣១.៣៦២ | ១២៨.៣៦១ |
| ចំណាយការជួសជុល និងថែទាំ | ៥២.២៥៧ | ២១២.៧១១ | ៣៧.៨៨៨ | ១៥៥.០៥៧ |
| ចំណាយទំនាក់ទំនងផ្សេងៗ | ១៨.៥៧៧ | ៧៥.៦៣៥ | ១៧.៤៤៥ | ៧១.៤០៨ |
| ចំណាយលើថ្លៃវិជ្ជាជីវៈ | ៥.៣២៦ | ២១.៦៩៤ | ៥.១៤០ | ២១.១០៩ |
| ចំណាយលើការធ្វើដំណើរ | ១១.៨៧៤ | ៤៨.៣៧៦ | ៩.០៦២ | ៣៧.១៧៩ |
| ចំណាយពន្ធផ្សេងៗ | ១៥.០០៤ | ៦១.៦២៤ | ១៤.២៩០ | ៦០.០៣៣ |
| ចំណាយផ្សេងៗ | ១៩.០៣៣ | ៧៧.៥៥១ | ១១៧.០៧៣ | ៤៧៩.៦៦០ |
| ឱនភាពលើគណនីត្រូវទទួល | ២៨០.៥៧៨ | ១.១៤២.២៨៩ | ១២៧.០៤០ | ៥១៩.៣៦១ |
| | ១.៨៨២.១២៦ | ៧.៦៦៣.៤៧១ | ១.៩០៣.០៨១ | ៧.៧៩១.១៥៥ |

## ២១. ចំណាយទូទៅ និងចំណាយរដ្ឋបាល (ត)

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ | ២.៩៦០.៥៥៨ | ១២.០៣៧.៦២៩ | ៣.០២៤.៨១១ | ១២.៣៤៧.២៧៩ |
| ចំណាយទឹក ភ្លើង និង ប្រេងឥន្ទនៈ | ៣៩០.១៥៧ | ១.៥៨៦.៣៧៨ | ៣៤៤.៦៧៨ | ១.៤០៦.៩៧៦ |
| រំលស់ | ៥២៨.១០២ | ២.១៤៧.២៦៣ | ៣៤៩.៩៦៨ | ១.៤២៨.៥៦៩ |
| កម្រៃសម្រាប់ក្រុមប្រឹក្សាភិបាល | ១៨៥.៩០៨ | ៧៥៥.៩០២ | ១៩៣.៦០៦ | ៧៩០.៣០០ |
| អំណោយសទ្ធារទាន | ២២៦.២១៦ | ៩១៩.៧៩៤ | ៣២៩.០១៣ | ១.៣៤៣.០៣១ |
| ចំណាយផ្គត់ផ្គង់សម្ភារៈការិយាល័យ | ១៤៩.៩៣៤ | ៦០៩.៦៣២ | ១៨០.២៧៥ | ៧៣៥.៨៨៣ |
| ចំណាយលើការកំសាន្ត | ៦៩.១៨៦ | ២៨១.៣១០ | ៨៨.២៥២ | ៣៦០.២៤៥ |
| ចំណាយការជួសជុល និងថែទាំ | ១៣០.១៩០ | ៥២៩.៣៥៣ | ១០៤.១៧៧ | ៤២៥.២៥១ |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៥២.៣៩៨ | ២១៣.០៥០ | ៥០.៣៤០ | ២០៥.៤៨៨ |
| ចំណាយលើថ្លៃវិជ្ជាជីវៈ | ១៨.១៥៨ | ៧៣.៨៣០ | ២៦.៣៦២ | ១០៧.៦១០ |
| ចំណាយលើការធ្វើដំណើរ | ៤៤.០៧៧ | ១៧៩.២១៧ | ៤០.៣៥០ | ១៦៤.៧០៩ |
| ចំណាយពន្ធផ្សេងៗ | ២២០.៩១៥ | ៨៩៨.២៤០ | ២៩៧.៨៥៦ | ១.២១៥.៨៤៨ |
| ចំណាយផ្សេងៗ | ៧៣.៤១៦ | ២៩៨.៥០៩ | ២៣៦.៧៩៥ | ៩៦៦.៥៩៧ |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ និងទ្រព្យសម្បត្តិវិនិយោគ | - | - | ១៧៤.៩៦២ | ៧១៤.១៩៥ |
| ឱនភាពលើគណនីត្រូវទទួល | ៤១៥.៥០៣ | ១.៦៨៩.៤៣៥ | ២៥៧.៦៨២ | ១.០៥១.៨៥៨ |
| | ៥.៤៦៤.៧១៨ | ២២.២១៩.៥៤២ | ៥.៦៩៩.១២៧ | ២៣.២៦៣.៨៣៩ |

## ២២. ចំណាយហិរញ្ញប្បទាន

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើ៖ | | | | |
| - កម្ចី | ២១៥.០៤៧ | ៨៧៥.៦៧៩ | ២៣៣.៣៣២ | ៩៥៥.៣៥២ |
| - បំណុលពីការជួល | ៨១.១៥១ | ៣៣០.៣៦៥ | ២៨.៨៦១ | ១១៨.១៥៧ |
| ផលប៉ះពាល់នៃ៖ | | | | |
| - ភាគលាភធានាត្រូវបង់ | - | - | ៦.៩១៩ | ២៨.៣៣៤ |
| | ២៩៦.១៩៨ | ១.២០៦.០៤៤ | ២៦៩.១១២ | ១.១០១.៨៤៣ |

## ២២. ចំណាយហិរញ្ញប្បទាន (ត)

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើ៖ | | | | |
| - កម្ចី | ៦៤៧.៩០១ | ២.៦៣៤.៣៦៥ | ៧១៥.០៦១ | ២.៩១៨.៨៧៩ |
| - បំណុលពីការជួល | ២១៤.៦២៦ | ៨៧២.៦៦៩ | ៨៦.៦៤៩ | ៣៥៣.៧០១ |
| ផលប៉ះពាល់នៃ៖ | | | | |
| - ប្រាក់កក់ត្រូវទទួលរយៈពេលវែង | ១.៣០០ | ៥.២៨៧ | ១.២៥០ | ៥.១០៣ |
| - ភាគលាភធានាត្រូវបង់ | - | - | ២០.៨២០ | ៨៤.៩៨៧ |
| | ៨៦៣.៨២៧ | ៣.៥១២.៣២១ | ៨២៣.៧៨០ | ៣.៣៦២.៦៧០ |

## ២៣. ចំណាយពន្ធ

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | | |
| ពន្ធប្រាក់ចំណេញក្នុងគ្រា | ៨៧៦.៥៨០ | ៣.៥៦៧.៧៦៥ | ៧០៣.២១២ | ២.៨៧៧.០៥១ |
| ចំណាយពន្ធពន្យារ ៖ | | | | |
| ភាពខុសគ្នាបណ្តោះអាសន្ន | ១៣១.៥២៦ | ៥៣៤.៣៦៧ | ១១៦.៤០៤ | ៤៧៦.២៩៣ |
| ចំណាយពន្ធសរុប | ១.០០៨.១០៦ | ៤.១០២.១៣២ | ៨១៩.៦១៦ | ៣.៣៥៣.៣៤៤ |

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | | |
| ពន្ធប្រាក់ចំណេញក្នុងគ្រា | ២.០៤៣.៥៣៤ | ៨.៣០៩.០០៩ | ១.៧៥៩.២៨៩ | ៧.១៨១.៤១៨ |
| ខ្វះទទួលស្គាល់ចំណូលពន្ធក្នុងឆ្នាំមុន | ៣០.១៥៥ | ១២២.៦១០ | ៣៣.៨៥៤ | ១៣៨.១៩២ |
| | ២.០៧៣.៦៨៩ | ៨.៤៣១.៦១៩ | ១.៧៩៣.១៤៣ | ៧.៣១៩.៦១០ |
| ចំណាយពន្ធពន្យារ ៖ | | | | |
| ភាពខុសគ្នាបណ្តោះអាសន្ន | (៧.៩៨២) | (៣២.៤៥៤) | ៣០៥.០៧៦ | ១.២៤៥.៣២០ |
| ចំណាយពន្ធសរុប | ២.០៦៥.៧០៧ | ៨.៣៩៩.១៦៥ | ២.០៩៨.២១៩ | ៨.៥៦៤.៩៣០ |

## ២៣. ចំណាយពន្ធ (ត)

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក.ស.ភ មានកាតព្វកិច្ច ក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (២០២០៖ ២០%) លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% (២០២០៖ ១%)។

## ២៤. ចំណេញក្នុងមួយភាគហ៊ុន

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិកធម្មតា | ៣.៨៥៨.៦៨៧ | ១៥.៧០៦.០៩២ | ៣.១១៦.០៥៨ | ១២.៧៤៦.៩០៩ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់គិតជាមធ្យម | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០,១៩ | ០,៧៦ | ០,១៥ | ០,៦២ |
| ចំណេញក្នុងមួយភាគហ៊ុនដែលថយចុះ | ០,១៩ | ០,៧៦ | ០,១៥ | ០,៦២ |

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិកធម្មតា | ៩.៤១៥.០៦៥ | ៣៨.២៨១.៦៥១ | ៧.៦៤២.៧៧៤ | ៣១.១៩៧.៨០៣ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់គិតជាមធ្យម | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០,៤៦ | ១,៨៥ | ០,៣៧ | ១,៥១ |
| ចំណេញក្នុងមួយភាគហ៊ុនដែលថយចុះ | ០,៤៦ | ១,៨៥ | ០,៣៧ | ១,៥១ |

ចំណេញក្នុងមួយភាគហ៊ុនដែលថយចុះ ត្រូវបានគណនាដោយកាត់តងចំនួនភាគហ៊ុនធម្មតា ដែលមិនទាន់បានដាក់លក់ជាមធ្យម ដើម្បីសន្មតនូវការផ្លាស់ប្តូរនូវភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃទាំងអស់។

ក.ស.ភ មិនមានភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃទេក្នុងការិយបរិច្ឆេទនេះ។ ដូច្នេះចំណេញក្នុងមួយភាគហ៊ុនដែលថយចុះមានតម្លៃស្មើចំណេញក្នុងមួយភាគហ៊ុនគោល។

## ២៥. ភាគលាភត្រូវបង់

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាល បានអនុម័តនៅក្នុងការចែកភាគលាភសម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ទៅកាន់ភាគហ៊ុនិកតាមប្រភេទភាគហ៊ុនដូចខាងក្រោម៖

- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ក" ទទួលបានភាគលាភបន្ថែមចំនួន ៧៨.៤៤៦ដុល្លារអាមេរិក (សមមូលទៅនឹង៣១៧.៧១១.៨៤៦រៀល) ទៅលើភាគលាភសរុប។
- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ខ" ទទួលបានភាគលាភសរុបចំនួន ៦៧៩.០១២ដុល្លារអារមេរិក (សមមូលទៅនឹង ២.៧៥០.០០០.០០០រៀល)។

ភាគលាភទាំងនោះត្រូវបានទូទាត់នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១។

## ២៦. កំណាត់បន្ទាញញាតិសម្ព័ន្ធ

(ក) ក.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយនឹងញាតិសម្ព័ន្ធនៅក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ញាតិសម្ព័ន្ធ | | | | |
| ក.ស.ហ | | | | |
| ចំណាយការប្រាក់ | ២១៥.០៤៧ | ៨៧៥.៦៧៩ | ២៣៣.៣៣២ | ៩៥៥.៣៥២ |
| ក.ស.ហ និង ក.ស.ដ | | | | |
| អំណោយសទ្ធាទាន | ៣១.៤៨០ | ១២៨.០០៩ | ២៧.៣៦១ | ១១១.៧៤៥ |

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ញាតិសម្ព័ន្ធ | | | | |
| ក.ស.ហ | | | | |
| ចំណាយការប្រាក់ | ៦៤៧.៩០១ | ២.៦៣៤.៣៦៥ | ៧១៥.០៦១ | ២.៩១៨.៨៧៩ |
| ក.ស.ហ និង ក.ស.ដ | | | | |
| អំណោយសទ្ធាទាន | ៣៥.១៧៥ | ១៤៣.០២២ | ៣៦.៩៥៤ | ១៥០.៨៤៦ |

## ២៦. កំណត់បន្ទាញញាតិសម្ព័ន្ធ (ត)

(ខ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ

អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ការិយបរិច្ឆេទមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៣ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី | ៦១.៨១៥ | ២៥១.៧១៣ | ៦១.៥៨៨ | ២៥២.១៩៥ |

| | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០២១ | | ៣០ កញ្ញា ២០២០ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី | ១៨៥.៥០៨ | ៧៥៥.៥០៣ | ១៩៣.៦០៦ | ៧៩០.៣០០ |

## ២៧. កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អ ដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបានបង្កើតគោលការណ៍លំអិតដូចជា កម្រិតសិទ្ធិអំណាចត្រួតពិនិត្យ ការទទួលខុសត្រូវការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

### ក. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ ក.ស.ភ ដោយដៃគូពាណិជ្ជកម្មមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ តាមគោលការណ៍ ក.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុដៃគូពាណិជ្ជកម្មសមភាគីដើម្បីធានាថា ក.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែល ក.ស.ភ ងាយរងផលប៉ះពាល់ គឺតាមរយៈគណនីត្រូវទទួលពីអតិថិជន។ អាយុកាលឥណទានរបស់ក.ស.ភ មានរយៈពេលពី១ ទៅ ៣ខែ (២០២០៖១ ទៅ ៣ខែ) ហើយ ក.ស.ភ ព្យាយាមធ្វើការគ្រប់គ្រងយ៉ាងជិតដល់លើគណនីត្រូវទទួលដែលមិនទាន់ប្រមូល ដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។ សមតុល្យដែលហួសកាលកំណត់ ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

## ២៧. កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ(ត)

### ខ. ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់កើតឡើងពីការគ្រប់គ្រងរបស់ ក.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល ក.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក.ស.ភ គ្រប់គ្រងយ៉ាងយកចិត្តទុកដាក់លើកាលកំណត់នៃបំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក.ស.ភ ធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ ក.ស.ភ។

### គ. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ ក.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ ក.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារ ហើយសំខាន់ជាងនេះទៀត គឺរក្សាដោយប្រុងប្រយ័ត្នអោយបាននូវការលាយឡំគ្នានៃកម្ចីដែលមានអត្រាថេរ និងអត្រាប្រែប្រួល។ ក.ស.ភ ពុំបានប្រើប្រាស់ឧបករណ៍និស្សន្ទហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

## ២៨. យថាភាពនៃពន្ធ

នៅក្នុងប្រទេសកម្ពុជា បទបញ្ញត្តិស្តីពីពន្ធដារ រួមមាន អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ ដែលជារឿយៗតែងមានការកែតម្រូវតាមរយៈការធ្វើវិសោធនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលកត្តានេះអាចនាំឱ្យភាគីពាក់ព័ន្ធអាចនឹងធ្វើការបកស្រាយផ្សេងៗពីគ្នា ទៅលើបទដ្ឋានគតិយុត្តិទាំងនោះ។ តាមនីតិវិធីច្បាប់ មន្ត្រីពន្ធដារនឹងចុះធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីធ្វើការផាកពិន័យ តាមកំរិតទោសទណ្ឌ និងការពិន័យលើការប្រាក់ជាដើម ចំពោះបទល្មើស ពាក់ព័ន្ធនឹងពន្ធដារ។ ភាពបំរែបំរួលជាញឹកញាប់នៃច្បាប់ពន្ធដារ អាចនាំឱ្យកើតមានជាហានិភ័យយ៉ាងខ្ពស់ចំពោះអង្គភាពនាពេលខាងមុខ។ ថ្នាក់គ្រប់គ្រងជឿជាក់ថា ខ្លួនមានហេតុផលសមរម្យ និងគ្រប់គ្រាន់សម្រាប់បំណុលពន្ធ ដោយផ្អែកលើការបកស្រាយរបស់បទបញ្ញត្តិនៃពន្ធនាពេលបច្ចុប្បន្ន។

## ២៩. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

តម្រូវការសេវាលើសេវាកម្មរបស់ ក.ស.ភ គឺផ្អែកទៅលើបម្រែបម្រួលតាមរដូវកាល ដែលជាលទ្ធផលពីតម្រូវការដ៏ខ្ពស់សម្រាប់ផលិតផលកាត់ដេរ វត្ថុធាតុដើមវាយនភណ្ឌ ស្រូវអង្ករ និងសម្ភារៈសំណង់។ តាមប្រវត្តិនៃប្រតិបត្តិការអាជីវកម្ម តម្រូវការខ្ពស់បំផុតនៃសេវាកម្មរបស់ក្រុមហ៊ុន គឺស្ថិតនៅក្នុងត្រីមាសទី៣ នៃការិយបរិច្ឆេទដែលបណ្តាលមកពីតម្រូវការខ្ពស់នៃការនាំចេញទៅសហរដ្ឋអាមេរិក និងការនាំចូលពីប្រទេសចិន។

## ៣០. ព្រឹត្តិការណ៍សំខាន់ៗក្នុងកំឡុងពេល

(ក) អង្គការសុខភាពពិភពលោកបានប្រកាសថាជម្ងឺឆ្លងវីរុសណូវែលកូរ៉ូណា ("កូវីដ-១៩") ជាជម្ងឺរាតត្បាតនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

ផ្អែកលើការវាយតម្លៃ និងព័ត៌មានដែលមាននៅក្នុងការិយបរិច្ឆេទនៃការអនុញ្ញាតរបាយការណ៍ហិរញ្ញវត្ថុ។ ដោយផ្អែកលើការវាយតម្លៃ ក.ស.ភ មិនមានផលប៉ះពាល់ដ៏សំខាន់ណាមួយកើតឡើងពីជំងឺរាតត្បាតកូវីដ-១៩ពាក់ព័ន្ធនឹងការវិនិច្ឆ័យនិង ការសន្មតដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់រយៈពេលហិរញ្ញវត្ថុ ដែល បានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ឡើយ ។ ក.ស.ភ នឹងបន្តវាយតម្លៃផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ សម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ក.ស.ភ ក៏បានចាត់ទុកផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩នៅទូទាំងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន និងបានធ្វើការប្រុងប្រយ័ត្ន និងសំវិធានធនដែលចាំបាច់។ ក.ស.ភ ក៏នឹងបន្តតាមដានយ៉ាងសកម្ម និងគ្រប់គ្រងមូលនិធិ និងប្រតិបត្តិការរបស់ខ្លួនដើម្បីកាត់បន្ថយផលប៉ះពាល់ណាមួយដែលកើតឡើងពីជម្ងឺរាតត្បាតកូវីដ-១៩។

(ខ) នៅថ្ងៃទី១ ខែមករាឆ្នាំ ២០២១ ដីដែលមានទីតាំងស្ថិតនៅសង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ និងក្រុងព្រះសីហនុមានទំហំ ៣៤.៦៨៧.២៩ ម៉ែតការ៉េ ត្រូវបានប្រគល់អោយ ក.ស.ភ ដោយអនុលោមតាមកិច្ចព្រមព្រៀងជួលរយៈពេល ៤០ ឆ្នាំដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន ហ្គ្រីនត្រេដ ខូអិលធីឌី នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ។

# ផ្នែកទី ៤

# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក. ស. ភ. គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមកំពង់ផែអន្តរជាតិទាំងពីរក្នុងប្រទេសកម្ពុជា។ ក. ស. ភ. មានមណ្ឌលអាជីវកម្មលាតសន្ធឹងពីភ្នំពេញ ដល់ទន្លេមេគង្គក្រោម (អ្នកលឿង) និងពីភ្នំពេញដល់ទន្លេមេគង្គលើ (ទន្លេបិទ) ដែលកំណត់ក្នុងអនុក្រឹត្យលេខ០១ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩។ ក. ស. ភ. មានមុខងារជាអាជ្ញាធរផែ និងជាប្រតិបត្តិករផែ ដូចមានលម្អិតក្នុងផ្នែក១ ចំណុចទី២ នៃរបាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ២០២១នេះ។

បរិមាណកុងតឺន័រឆ្លងកាត់ ក. ស. ភ. ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានការកើនឡើងចំនួន ២៣ ៤៤៣ TEUs ស្មើនឹង ២៧,៣៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ចំនួននាវាដឹកទំនិញសរុបក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានការធ្លាក់ចុះចំនួន ២៣គ្រឿង ឬស្មើនឹង ៣,៦៩% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ចំណែកនាវាដឹកអ្នកដំណើរកម្ពុជា និងអន្តរជាតិ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ពុំមានឆ្លងកាត់ និងពុំមានការប្រែប្រួល ឬស្មើនឹង ០% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ដោយឡែកទំនិញរាយឆ្លងកាត់ ក.ស.ភ. ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ មានការធ្លាក់ចុះចំនួន ៥០ ០១៧ តោន ឬស្មើនឹង ២១,៩១% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ **ក.ស.ភ.** និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដែលត្រូវបានធ្វើការត្រួតពិនិត្យរួចរាល់ដោយសវនករឯករាជ្យសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ និងត្រីមាសទី៣ ឆ្នាំ២០២១ (គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា) ដូចបង្ហាញក្នុងផ្នែកទី៣ នៃរបាយការណ៍ប្រចាំត្រីមាសទី២នេះ។

*ក.ស.ភ. មានប្រភពចំណូលសំខាន់ៗចំនួន ៤ប្រភេទ៖*

***១. ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring)*** ៖ សំដៅលើចំណូលដែលបានមកពីសេវាកម្មផ្ទេរ-ផ្ទុកទំនិញ/កុងតឺន័រពីនាវា និងដឹកជញ្ជូនពីស្ពានផែទៅទីលាននិងពីទីលានមកស្ពានផែ។

***២. ចំណូលពីការលើកដាក់លើទីលាន (LOLO)***៖សំដៅលើចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញ/កុងតឺន័រពីទីលានដាក់លើរថយន្ត និងពីរថយន្តដាក់លើទីលាន។

***៣. ចំណូលពីកិច្ចការផែ (PortDue & Charge)***៖សំដៅលើចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ពន្ធលើចំណុះផ្ទុក ពន្ធសំចត ពន្ធប្រឡាយ ថ្លៃឈ្នួលកណ្តាធារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និង ថ្លៃឈ្នួលបោសសម្អាតឃ្លប់នាវា។

***៤. ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ (Storage Fee)***៖សំដៅលើចំណូលដែលបានមកពីការស្តុកទំនិញ/កុងតឺន័រនៅលើទីលាន ឬក្នុងឃ្លាំង។ ទំនិញរាយ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃទាំងនាំចេញ និងនាំចូល និងទំនិញជាកុងតឺន័រ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃសម្រាប់ការនាំចេញ និង៧ថ្ងៃសម្រាប់ការនាំចូល។

## ១. ការវិភាគចំណូល

### ១.១.ការវិភាគចំណូល

### សម្រាប់ត្រីមាសទី២ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី២ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | | | | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលប្រតិបត្តិការផែ | ៨ ០១៥ ៤២៩ | ៣២ ៦២៦ ៨៨៤ | ៦ ៦០៦ ១៧៧ | ២៧ ០៣១ ៥៩៦ | ១ ៤០៩ ២៥២ | ២១,៣៣% | ៥ ៥៩៤ ៨៨៨ | ២០,៧០% |
| ចំណូលអាជ្ញាធរផែ | ៩៨៨ ៦៧៩ | ៤ ០២៤ ៩៦៣ | ៩៤៩ ១៤៧ | ៣ ៨៨៥ ៥៨៥ | ៣៩ ៥៣២ | ៤,១៧% | ១៣៩ ៣៧៨ | ៣,៥៩% |
| សេវាផ្សេងៗ | ៥៩ ៤១៧ | ២៤២ ២៣១ | ២០ ៧២១ | ៨៥ ៤៣៧ | ៣៨ ៦៩៦ | ១៨៦,៧៥% | ១៥៦ ៧៩៤ | ១៨៣,៥២% |
| សរុប: | ៩ ០៦៣ ៥២៥ | ៣៦ ៨៩៣ ៦៧៨ | ៧ ៥៧៦ ០៤៥ | ៣១ ០០២ ៦១៨ | ១ ៤៨៧ ៤៨០ | ១៩,៦៣% | ៥ ៨៩១ ០៦០ | ១៩,០០% |

ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម បានកើនឡើងចំនួន ៥ ៨៩១ ០៦០ ពាន់រៀល (១ ៤៨៧ ៤៨០ ដុល្លារអាមេរិក) ឬស្មើនឹង ១៩,០០% ពី ៣១ ០០២ ៦១៨ ពាន់រៀល (៧ ៥៧៦ ០៤៥ ដុល្លារអាមេរិក) សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ ដល់ ៣៦ ៨៩៣ ៦៧៨ ពាន់រៀល (៩ ០៦៣ ៥២៥ ដុល្លារអាមេរិក)សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១។ ការកើនឡើងនេះ បណ្តាលមកពីកំណើននៃចំណូលប្រតិបត្តិការផែ (ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO) និងកំណើននៃចំណូលអាជ្ញាធរផែ (ចំណូលពីកិច្ចការផែ)។

## ១.២. ការវិភាគចំណូលតាមផ្នែក

សម្រាប់ត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់សម្រាប់ត្រីមាសទី៣ | | សម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់សម្រាប់ត្រីមាសទី៣ | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | |
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង | ១៦ ៧២៥ ១០៩ | ៤៥,៣៣% | ១៣ ៨៧៩ ៦២២ | ៤៤,៧៧% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ១៣ ៣៦៥ ៨៣៩ | ៣៦,២៣% | ១១ ៣៣៧ ១៩៨ | ៣៦,៥៧% |
| ចំណូលពីកិច្ចការផែ | ៤ ០២៤ ៩៦៣ | ១០,៩១% | ៣ ៨៨៥ ៥៨៥ | ១២,៥៣% |
| ចំណូលពីច្រកទ្វារ | ១ ១៣២ ៩៧៩ | ៣,០៧% | ៨២៩ ៧២៦ | ២,៦៨% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៩១៣ ៦២៨ | ២,៤៨% | ៦៨៨ ៥៨២ | ២,២២% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងទម្ងន់កុងតឺន័រ | ១១ ៤៣៤ | ០,០៣% | ៦ ០៦៨ | ០,០២% |
| ចំណូលពីការរើរៀបទំនិញ | ២៦ ៥០៩ | ០,០៧% | ២៩ ៨៨៩ | ០,១០% |
| ចំណូលពីការដឹកជញ្ជូន | ៤៥០ ៩៨៦ | ១,២២% | ២៦០ ៥១១ | ០,៨៤% |
| ចំណូលពីសេវាភ័ស្តុភារកម្ម | ២១៨ ៤៣១ | ០,៥៩% | ៤៩ ០៧៨ | ០,១៦% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ២៣ ៨០០ | ០,០៦% | ៣៦ ៣៥៩ | ០,១២% |
| សរុប: | **៣៦ ៨៩៣ ៦៧៨** | **១០០,០០%** | **៣១ ០០២ ៦១៨** | **១០០,០០%** |

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ក.ស.ភ. ចំណូល ៣ប្រភេទធំៗ មានចំនួនប្រមាណ ៩២ % នៃចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ។ ចំណូលទាំងនោះរួមមាន៖ ចំណូលលើកដាក់ក្រោមដងយោង ចំណូលលើកដាក់លើទីលាន និងចំណូលពីកិច្ចការផែ។

## សម្រាប់ត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ចំណូល ៣ប្រភេទធំៗ បានកើនឡើងចំនួន ៥ ០១៣ ៥០៦ ពាន់រៀល (១ ២៦៩ ២៣៩ ដុល្លារអាមេរិក) ឬស្មើនឹង ១៧,២៣% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ៤ ១០៨ ៩៩២ | ១៦ ៧២៥ ១០៩ | ៣ ៣៩២ ២២១ | ១៣ ៨៧៩ ៦២២ | ៧១៦ ៧៧១ | ២១,១៣% | ២ ៨៤៥ ៤៨៧ | ២០,៥០% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ៣ ២៨៣ ៥៧០ | ១៣ ៣៦៥ ៨៣៩ | ២ ៧៧០ ៦៣៤ | ១១ ៣៣៧ ១៩៨ | ៥១២ ៩៣៦ | ១៨,៥១% | ២ ០២៨ ៦៤១ | ១៧,៨៩% |
| ចំណូលពីកិច្ចការផែ | ៩៨៨ ៦៧៩ | ៤ ០២៤ ៩៦៣ | ៩៤៩ ១៤៧ | ៣ ៨៨៥ ៥៨៥ | ៣៩ ៥៣២ | ៤,១៧% | ១៣៩ ៣៧៨ | ៣,៥៩% |

## *២.ការវិភាគតំលាតប្រាក់ចំណេញដុល*

ប្រាក់ចំណេញដុលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត របស់ **ក.ស.ភ.** ដែលបានមកពីចំណូលសរុបនៃផលអាជីវកម្ម និងសេវាកម្ម ដកនឹងចំណាយថ្លៃដើមនៃសេវាកម្ម(ចំណាយប្រតិបត្តិការ)។

សម្រាប់ត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ចំណូល** | **៩ ០៦៣ ៥២៥** | **៣៦ ៨៩៣ ៦៧៨** | **៧ ៥៧៦ ០៤៥** | **៣១ ០០២ ៦១៨** | **១ ៤៨៧ ៤៨០** | **១៩,៦៣%** | **៥ ៨៩១ ០៦០** | **១៩,០០%** |
| **ថ្លៃដើមនៃសេវាកម្ម** | | | | | | | | |
| រំលស់ទ្រព្យពោងចក្រ បរិក្ខារ | ៧០៧ ៥៧៤ | ២ ៨៨០ ៥៩៣ | ៥៧២ ៩៩៩ | ២ ៣៤៥ ៥២៩ | ១៣៤ ៥៧៥ | ២៣,៤៩% | ៥៣៥ ០៦៤ | ២២,៨១% |
| ថ្លៃដងយោង | ៦៩៩ ៧៩៩ | ២ ៨៤៨ ៤០៥ | ៦៩៤ ៤១៥ | ២ ៨៤១ ៤៤០ | ៥ ៣៨៤ | ០,៧៨% | ៦ ៩៦៥ | ០,២៥% |
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ៤៤៩ ១៥៧ | ១ ៨២៨ ៧៨៩ | ៤០៣ ៩៨៦ | ១ ៦៥៣ ៧៥២ | ៤៥ ១៧១ | ១១,១៨% | ១៧៥ ០៣៧ | ១០,៥៨% |
| ប្រេងឥន្ធនៈ (ប្រតិបត្តិការ និងថែទាំប្រឡាយ) | ២៦៣ ៨៦០ | ១ ០៧៤ ១៣១ | ២១៤ ០២១ | ៨៧៦ ៥១៨ | ៤៩ ៨៣៩ | ២៣,២៩% | ១៩៧.៦១៣ | ២២,៥៥% |
| ចំណាយការការថែទាំ និងជួសជុល | ២០៩ ១០៣ | ៨៥០ ២១៣ | ១៨០ ៤៨៥ | ៧៣៩ ៤៥៦ | ២០ ៤៤៣ | ១០,៨៤% | ៧៩ ៨៩៧ | ១០,៣៥% |
| ចំណាយពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ៤ ៦២៥ | ១៨ ៨០៥ | - | - | ៤ ៦២៥ | N/A | ១៨ ៨០៥ | N/A |
| ចំណាយលើសេវាភ័ស្តុភារកម្ម | ៦៦ ២៧០ | ២៦៩ ៤៥៤ | ១២ ៤៤០ | ៥០ ៨៩៣ | ៥៣ ៨៣០ | ៤៣២,៧២% | ២១៨ ៥៦១ | ៤២៩,៤៥% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | ១៨៧ ២០៤ | ៧៦៤ ៣៥០ | - | - | ១៨៧ ២០៤ | N/A | ៧៦៤ ៣៥០ | N/A |
| សរុបថ្លៃដើមនៃការលក់ និងសេវាកម្ម | ២ ៥៨៧ ៥៩២ | ១០ ៥៣៤ ៧៤០ | ២ ០៧៨ ៣៤៦ | ៨ ៥០៧ ៥៨៨ | ៥០៩ ២៤៦ | ២៤,៥០% | ២ ០២៧ ១៥២ | ២៣,៨៣% |
| ប្រាក់ចំណេញដុល | ៦ ៨៧៥ ៩៣៣ | ២៦ ៣៥៨ ៩៣៨ | ៥ ៨៩៧ ៦៩៩ | ២២ ៨៩៥ ០៣០ | ៩៧៨ ២៣៤ | ១៧,៧៩% | ៣ ៤៦៣ ៩០៨ | ១៧,១៨% |
| អត្រាគំលាតប្រាក់ចំណេញដុល | ៧១,៤៥% | ៧១,៤៥% | ៧២,៥៧% | ៧២,៥៦% | | | | |

- អត្រាគំលាតប្រាក់ចំណេញដុល

អត្រាគំលាតប្រាក់ចំណេញដុលបានថយចុះចំនួន ១,១១% ពីអត្រា ៧២,៥៦% ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ទៅ ៧១,៤៥%ក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ ការថយចុះនៃអត្រាគំលាតប្រាក់ចំណេញដុលដោយសារតែចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានការកើនឡើងចំនួន ៥ ៨៩១ ០៦០ ពាន់រៀល (១ ៤៨៧ ៤៨០ ដុល្លារអាមេរិក) ឬស្មើនឹង ១៩,០០%។ ចំណែកឯចំណាយថ្លៃដើមនៃសេវាកម្មសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ បានកើនឡើងចំនួន ២ ០២៧ ១៥២ ពាន់រៀល (៥០៩ ២៤៦ ដុល្លារអាមេរិក) ឬស្មើនឹង ២៣,៨៣% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០ គឺដោយសារមានការកើនឡើងទៅលើចំណាយថ្លៃដើមនៃសេវាកម្មមួយចំនួនដូចជា ចំណាយទៅលើការជួសជុល និងថែទាំ រលស់ទ្រព្យរោងចក្របរិក្ខារ និងចំណាយប្រេងឥន្ធនៈ (ប្រតិបត្តិការ និងថែទាំប្រឡាយ) ជាដើម។

## ៣. *ការវិភាគប្រាក់ចំណេញមុនបង់ពន្ធ*

ប្រាក់ចំណេញមុនបង់ពន្ធ គឺបានមកពីប្រាក់ចំណេញដុល បូកចំណូលផ្សេងៗ ដកនឹងចំណាយរដ្ឋបាលទូទៅ និងចំណាយហិរញ្ញប្បទាន។

សម្រាប់ត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | | | | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ប្រាក់ចំណេញដុល | **៦ ៤៧៥ ៩៣៣** | **២៦ ៣៥៨ ៩៣៨** | **៥ ៤៩៧ ៦៩៩** | **២២ ៤៩៥ ០៣០** | **៩៧៨ ២៣៤** | **១៧,៧៩%** | **៣ ៨៦៣ ៩០៨** | **១៧,១៨%** |
| ចំណូលផ្សេងៗ | **៦៣៦ ៦៩៥** | **២ ៥៩៣ ៣៣៩** | **៥៧៩ ២៩៧** | **២ ៣៧២ ១៤៧** | **៥៧ ៣៩៨** | **៩,៩១%** | **២២១ ១៩២** | **៩,៣២%** |
| **ចំណាយរដ្ឋបាលទូទៅនិងការលក់** | | | | | | | | |
| ចំណាយប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗ | ៩១២ ៩៥៦ | ៣ ៧១៨ ២២២ | ៩៩៣ ៣០១ | ៤ ០៦៦ ៨៤៤ | (៨០ ៣៤៥) | -៨,០៩% | (៣៤៨ ៦២២) | -៨,៥៧% |
| អំណោយសទ្ធាទាន | ៩៥ ៣០៤ | ៣៨៧ ៨៩៩ | ១៨៦ ២១២ | ៧៦០ ៩៧៤ | (៩០ ៩០៨) | -៤៨,៨២% | (៣៧៣ ០៧៥) | -៤៩,០៣% |
| ចំណាយទឹក-ភ្លើង និងប្រេងឥន្ទនៈ | ១៣៦ ៩៨៨ | ៥៥៧ ៧៥២ | ១១១ ៣៤៨ | ៤៥៥ ៩២៣ | ២៥ ៦៤០ | ២៣,០៣% | ១០១ ៨២៩ | ២២,៣៣% |
| ចំណាយរំលស់លើទ្រព្យវិនិយោគ និង ទ្រព្យរោងចក្របរិក្ខារ | ១៧១ ៩៩១ | ៧១៩ ៦៤៥ | ១៣២ ៩៩០ | ៥៤៤ ១៦៧ | ១៨ ៨៦៨ | ១៤,១៩% | ៧៤ ១៩០ | ១៣,៦៣% |
| ចំណាយជួសជុល និង ថែទាំ | ៥២ ២៥៧ | ២១២ ៧១១ | ៣៧ ៨៨៨ | ១៥៥ ០៥៧ | ១៤ ៣៦៩ | ៣៧,៩២% | ៥៧ ៦៥៤ | ៣៧,១៨% |
| ចំណាយលើការកំសាន្ត | ២៣ ០៤៥ | ៩៣ ៨៣៩ | ៣១ ៣៦២ | ១២៨ ៣៦១ | (៨ ៣១៧) | -២៦,៥២% | (៣៤ ៥២២) | -២៦,៨៩% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយការធ្វើដំណើរ | ១១ ៨៧៤ | ៤៨ ៣៧៦ | ៩ ០៦២ | ៣៧ ១៧៩ | ២ ８១២ | ៣១,០៣% | ១១ ១៩៧ | ៣០,១២% |
| ចំណាយជំនាញវិជ្ជាជីវៈ | ៥ ៣២៦ | ២១ ៦៩៤ | ៥ ១៤០ | ២១ ១០៩ | ១៨៦ | ៣,៦២% | ៥៨៥ | ២,៧៧% |
| ចំណាយកម្រៃក្រុមប្រឹក្សាភិបាល | ៦១ ៨១៥ | ២៥១ ៧១២ | ៦១ ៥៨៨ | ២៥២ ១៩៥ | ២២៧ | ០,៣៧% | (៤៨៣) | -០,១៩% |
| ចំណាយសម្ភារផ្គត់ផ្គង់ការិយាល័យ | ៧២ ៣៧៨ | ២៩៤ ៥២២ | ៥៨ ៣៤២ | ២៣៨ ៨៨៤ | ១៤ ០៣៦ | ២៤,០៦% | ៥៥ ៦៣៨ | ២៣,២៩% |
| ចំណាយទំនាក់ទំនងផ្សេងៗ | ១៨ ៥៧៧ | ៧៥ ៦៣៥ | ១៧ ៤៤៥ | ៧១ ៤០៨ | ១ ១៣២ | ៦,៤៩% | ៤ ២២៧ | ៥,៩២% |
| ចំណាយពន្ធផ្សេងៗ | ១៥ ០០៤ | ៦១ ៦២៤ | ១៤ ២៩០ | ៦០ ០៣៣ | ៧១៤ | ៥,០០% | ១ ៥៩១ | ២,៦៥% |
| ចំណាយផ្សេងៗ | ១៩ ០៣៣ | ៧៧ ៥៥១ | ១១៧ ០៧៣ | ៤៧៩ ៦៦០ | (៩៨ ០៤០) | -៨៣,៧៤% | (៤០២ １០៩) | -៨៣,៨៣% |
| ឱនភាពនៃការខាតបង់គណនីពាណិជ្ជ | ២៨០ ៥៧៨ | ១ ១៤២ ២៨៩ | １២៧ ០៤០ | ៥១៩ ៣៦១ | １៥៣ ៥៣៨ | ១២០,៨៦% | ៦២២ ៩២៨ | ១១៩,៩៤% |
| **សរុបចំណាយរដ្ឋបាលទូទៅ និងការលក់** | **១ ៨៨២ ១២៦** | **៧ ៦៦៣ ៤៧១** | **១ ៩០៣ ០៨១** | **៧ ៧៩១ ១៥៥** | **(២០ ៩៥៥)** | **-១,១០%** | **(១២៧ ៦៨៤)** | **-១,៦៤%** |
| ចំណេញប្រតិបត្តិការ | **៥ ២៣០ ៥០២** | **២១ ២៨៨ ៨០៦** | **៤ ១៧៣ ៩១៥** | **១៧ ០៧៦ ០២២** | **១ ០៥៦ ៥៨៧** | **២៥,៣១%** | **៤ ២១២ ៧៨៤** | **២៤,៦៧%** |
| ចំណាយហិរញ្ញប្បទាន | **(២៩៦ ១៩៨)** | **(១ ២០៦ ០៤៤)** | **(២៦៩ ១១២)** | **(១ ១០១ ８៤៣)** | **(២៧ ០៨៦)** | **១០,០៦%** | **(១០៤ ២០១)** | **៩,៤៦%** |
| ប្រាក់ចំណេញមុនបង់ពន្ធ | **៤ ៩៣៤ ៣០៤** | **២០ ០៨២ ៧៦២** | **៣ ៩០៤ ៨០៣** | **១៥ ៩៧៤ ១៧៩** | **១ ០២៩ ៥០១** | **២៦,៣៦%** | **៤ ១០៨ ៥៨៣** | **២៥,៧២%** |

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ចំណាយរដ្ឋបាលទូទៅ និងការលក់បានថយចុះចំនួន ១២៧ ៦៨៤ ពាន់រៀល (២០ ៩៥៥ ដុល្លារអាមេរិក) ឬស្មើនឹង១,៦៤% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។

## ៤. *ការវិភាគប្រាក់ចំណេញក្រោយបង់ពន្ធ*

ក.ស.ភ. ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា២០%។ ជាមួយគ្នានេះដែរ ចាប់ពីឆ្នាំ ២០១៩ តទៅ ក.ស.ភ. ឈប់ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ បន្ទាប់ពី ក.ស.ភ. ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចំនួន៣(បី)ឆ្នាំរួចហើយ (ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨) ។

### សម្រាប់ត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រៀបធៀបនឹងត្រីមាសទី៣ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

| បរិយាយ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់សម្រាប់ត្រីមាសទី៣ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ៤ ៩៣៤ ៣០៤ | ២០ ០៨២ ៧៦២ | ៣ ៩០៤ ៨០៣ | ១៥ ៩៧៤ ១៧៩ | ១ ០២៩ ៥០១ | ២៦,៣៦% | ៤ ១០៨ ៥៨៣ | ២៥,៧២% |
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | (១ ០០៨ ១០៦) | (៤ ១០២ ១៣២) | (៨១៩ ៦១៦) | (៣ ៣៥៣ ៣៤៤) | (១៨៨ ៤៩០) | ២៣,០០% | (៧៤៨ ៧៨៨) | ២២,៣៣% |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ៣ ៩២៦ ១៩៨ | ១៥ ៩៨០ ៦៣០ | ៣ ០៨៥ ១៨៧ | ១២ ៦២០ ៨៣៥ | ៨៤១ ០១១ | ២៧,២៦% | ៣ ៣៥៩ ៧៩៥ | ២៦,៦២% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៣ ៨៥៨ ៦៨៧ | ១៥ ៧០៦ ០៩២ | ៣ ១១៦ ០៥៨ | ១២ ៧៤៦ ៩០៩ | ៧៤២ ៦២៩ | ២៣,៨៣% | ២ ៩៥៩ ១៨៣ | ២៣,២១% |
| **អត្រាពន្ធមធ្យម(ខ)/(ក)** | **-២០,៤៣%** | **-២០,៤៣%** | **-២០,៩៩%** | **-២០,៩៩%** | | | | |

ក.ស.ភ. ទទួលបានប្រាក់ចំណេញសុទ្ធសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ចំនួន ១៥ ៩៨០ ៦៣០ ពាន់រៀល (៣ ៩២៦ ១៩៨ ដុល្លារអាមេរិក) និងសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ ចំនួន ១២ ៦២០ ៨៣៥ ពាន់រៀល (៣ ០៨៥ ១៨៧ ដុល្លារអាមេរិក) ដែលបង្ហាញឱ្យឃើញការកើនឡើងនូវប្រាក់ចំណេញសុទ្ធមានចំនួន ៣ ៣៥៩ ៧៩៥ ពាន់រៀល (៨៤១ ០១១ ដុល្លារអាមេរិក) ឬស្មើនឹង ២៦,៦២%។ ការកើនឡើងនៃអត្រាពន្ធមធ្យមចំនួន ០,៥៦% ពី ២០,៩៩% ក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ទៅ ២០,៤៣% ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ដោយសារចំណាយពន្ធលើប្រាក់ចំណេញមានការកើនឡើងចំនួន ៧៤៨ ៧៨៨ ពាន់រៀល (១៨៨ ៤៩០ ដុល្លារអាមេរិក) ឬស្មើនឹង ២២,៣៣% ។

## ៥. ការវិភាគពីកត្តានិងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ

### ៥.១. កំរិតនៃការជួញដូរក្នុងតំបន់និងជាសកលនិងសកលភាវូបនីយកម្ម

ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ ក. ស. ភ. អាស្រ័យលើបរិមាណកុងតឺន័រឆ្លងកាត់ និង សកម្មភាពដឹកជញ្ជូនឆ្លងកាត់កំពង់ផែដែលពឹងផ្អែកលើទំហំពាណិជ្ជកម្មក្នុងស្រុក និងទូទាំងពិភពលោក ព្រមទាំងបរិមាណនៃការនាំចេញនិងការនាំចូលក្នុងតំបន់ដែលត្រូវបានធ្វើប្រតិបត្តិការ។ បរិមាណនៃការជួញដូរក្នុងស្រុក និងទូទាំងពិភពលោក និងបរិមាណនៃការនាំចេញ និងនាំចូលក្នុងស្រុកដែលបានធ្វើប្រតិបត្តិការនេះទទួលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ចហិរញ្ញវត្ថុ និងនយោបាយក្នុងតំបន់ និងសកលដែលហួសពីការគ្រប់គ្រងរបស់ ក. ស. ភ.។

### ៥.២. សមត្ថភាពទទួលកុងតឺន័រនៅចំណតផែកុងតឺន័រLM១៧

ការលើកដាក់ចំបងៗត្រូវបានធ្វើឡើងនៅចំណតផែកុងតឺន័រLM១៧។ ក. ស. ភ. មានសមត្ថភាពលើកដាក់ទំនិញជាកុងតឺន័រប្រមាណ ២៩០.៨៥៧ TEU ក្នុងមួយឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ក. ស. ភ. ដើម្បីឆ្លើយតបនឹងកំណើននាឆ្នាំបន្ទាប់ ក. ស. ភ. មានគម្រោងនឹងបញ្ចប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី៣ ដែលនឹងបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅចំណតផែកុងតឺន័រLM១៧ បន្ថែមចំនួន ២០០.០០០ ធីអ៊ីយូ។

| បរិយាយ | សមត្ថភាពលើកដាក់ | | | | |
|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ផែនការ ឆ្នាំ២០២១ |
| ចំណតផែកុងតឺន័រ LM១៧ (ធីអ៊ីយូ) | ១៨៨.៨០៥ | ២១៣.៥៧១ | ២៨១.០៨៥ | ២៩០.៨៥៧ | ៣២១.០៦៦ |

### ៥.៣.ប្រសិទ្ធភាពនៃប្រតិបត្តិការ

ដើម្បីបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការ ក. ស. ភ. មានគោលការណ៍កាត់បន្ថយចំណាយថ្លៃដើមដោយប្រើធនធានដែលមានស្រាប់ និងការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗសម្រាប់បំរើឱ្យប្រតិបត្តិការ។ ជាក់ស្តែង ក. ស. ភ. បានអនុវត្តនូវវិធានការដូចខាងក្រោម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការៈ

- បន្តបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗដើម្បីបង្កើនល្បឿននៃការលើកដាក់ទំនិញនិង កាត់បន្ថយការរង់ចាំដោយសារការខូចខាតគ្រឿងចក្រ
- បន្តជម្រុញសមត្ថភាពផ្នែកប្រតិបត្តិកា រតាមរយៈការបណ្តុះបណ្តាល
- ពង្រីកចំណតផែដើម្បីធានាថានាវាដឹកកុងតឺន័រអាចដឹកជញ្ជូនចេញចូលបានលឿន និង ប្រកបដោយប្រសិទ្ធភាព
- ការពង្រីកទីលានស្តុកកុងតឺន័រជំហានទី៣ នៅចំណតផែកុងតឺន័រ LM១៧

- គ្រប់គ្រងទីលានស្តុកកុងតឺន័រឱ្យមានប្រសិទ្ធភាព ដោយកាត់បន្ថយការរក្សាទុកកុងតឺន័រនៅលើទីលានក្នុងរយៈពេលយូរ
- ប្រើប្រាស់ចំណតផែឲ្យមានប្រសិទ្ធភាព ដោយការរៀបចំទីតាំងចូលចតនាវាទៅតាមផែនការច្បាស់លាស់។

### ៥.៤. *តម្លៃ*

ក្នុងគោលបំណងដើម្បីរក្សាអតិថិជន ដែលមានស្រាប់ និងទាក់ទាញអតិថិជនថ្មី បន្ថែមទៀត ក. ស. ភ. បានផ្តល់តម្លៃអនុគ្រោះ លើសេវាពន្ធនាវា ដល់នាវាទេសចរណ៍ នាវាដឹកជញ្ជូនទំនិញរាយ និងនាវាដឹកជញ្ជូនកុងតឺន័រ និងប្រភេទនាវាដឹកជញ្ជូនទំនិញផ្សេងៗទៀត។ ជាមួយគ្នានេះដែរ ក. ស. ភ. ក៏បានផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ទំនិញរាយ ទាំងនៅចំណតផែកុងតឺន័ររបស់ ក. ស. ភ. និងនៅក្រៅចំណតផែរបស់ ក. ស. ភ.។ ក្រៅពីការអនុគ្រោះថ្លៃសេវាកម្មលើកដាក់ទំនិញរាយ ក. ស. ភ. ក៏បានផ្តល់តម្លៃអនុគ្រោះជាកញ្ចប់សម្រាប់សេវាកម្មលើកដាក់កុងតឺន័រ (Stevedore) ដល់ក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រទាំងអស់ដោយផ្អែកតាមបរិមាណកុងតឺន័រដែលដឹកជញ្ជូនបាន។ នេះមានន័យថា បើនាវាដឹកជញ្ជូនកុងតឺន័ររបស់ក្រុមហ៊ុនណាមួយ ដែលដឹកជញ្ជូនកុងតឺន័របានកាន់តែច្រើន នឹងទទួលបានការបញ្ចុះតម្លៃលើកទឹកចិត្តកាន់តែច្រើន។

### ៥.៥. *ការតភ្ជាប់រវាងផែរណប*

ការតភ្ជាប់រវាងផែរណបដើរតួនាទីយ៉ាងសំខាន់ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការជ្រើសរើសកំពង់ផែសម្រាប់ការដឹកជញ្ជូនទំនិញ។ ការតភ្ជាប់រវាងផែរណបដែលមានប្រសិទ្ធភាពអាចជំរុញឱ្យ អ្នកដឹកជញ្ជូនកាត់បន្ថយពេលវេលាដឹកជញ្ជូន។ ប្រសិទ្ធភាពចរាចរណ៍រវាងផែរណប អាស្រ័យទៅលើសេវាកម្មផែរណបផ្សេងទៀតដែលគ្រប់គ្រងលើចរាចរណ៍នៃការដឹកជញ្ជូនទំនិញ ព្រោះថាទីតាំងរបស់ ក. ស. ភ. មានអំណោយផលសម្រាប់ការប្រមូលទំនិញដើម្បីដឹកជញ្ជូនតាមផ្លូវទឹក។

### ៥.៦. *ការរំលស់*

ការរំលស់កើតឡើងពីការរំលស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារកំពង់ផែ រួមទាំង ចំណតនាវា អគារឃ្លាំង និងគ្រឿងចក្រលើកដាក់។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសំខាន់ៗ មានដូចជាចំណតនាវា អគារ (១០-៥០ឆ្នាំ) គ្រឿងចក្រគ្រឿងម៉ាស៊ីន (១០-១៥ឆ្នាំ) គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ (៥ឆ្នាំ) កុំព្យូទ័រ (៥-១៥ឆ្នាំ) សម្ភារការិយាល័យ និងផ្សេងៗ (៥-១៥ឆ្នាំ) និងយានយន្ត (៨-១៥ឆ្នាំ)។ វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ត្រូវបានពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. កត្តាសេដ្ឋកិច្ចជាតិ តំបន់ និងសកល

បរិមាណទំនិញឆ្លងកាត់ **ក.ស.ភ.** ទាក់ទងដោយផ្ទាល់ទៅនឹង កត្តាសេដ្ឋកិច្ចជាតិតំបន់ ឬ សកល។ ជាការចាំបាច់ដែល **ក.ស.ភ.** ត្រូវធ្វើការវិភាគសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបានដឹងនូវនិន្នាការ កំណើន ឬការធ្លាក់ចុះនៃតម្រូវការដឹកជញ្ជូន។ នេះជាមូលដ្ឋាន ដើម្បីរៀបចំឆ្លើយតបបានទាន់ពេលវេលា ក៏ដូចជាធ្វើផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬក៏បំពាក់គ្រឿងចក្របានសមស្រប។ នេះក៏អាចជួយឲ្យ **ក.ស.ភ.** ជៀសបានពីការវិនិយោគហួសតម្រូវការ ដែលធ្វើឲ្យខាតប្រយោជន៍ពីការប្រើប្រាស់ទុន ឬកប់ទុន ក្នុងករណីដែលតម្រូវការដឹកជញ្ជូនអាចធ្លាក់ចុះ។

### ២. ការគ្រប់គ្រងថ្លៃដើមនៃសេវាកម្ម

ការរក្សាបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ជាកត្តាសំខាន់សម្រាប់និរន្តភាពនៃការរីកលូតលាស់របស់ **ក.ស.ភ.** ក្នុងនោះ គឺគុណភាពសេវាកម្ម និងតម្លៃសេវាកម្មសមរម្យ។ ដើម្បីធានាបាននូវតម្លៃថ្លៃដើមនៃសេវាកម្មប្រកួតប្រជែង **ក.ស.ភ.** យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយប្រតិបត្តិការមួយចំនួនដូចខាងក្រោម៖

#### ២.១. ចំណាយបៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតលើបុគ្គលិក

ផ្នែកមួយនៃការចំណាយច្រើន គឺទៅលើបៀវត្សបុគ្គលិក និងអត្ថប្រយោជន៍ផ្សេងៗដែលស្មើនឹងអត្រា **១៥,០៤%** (អត្រា ៤,៩៦% ជាបៀវត្សបុគ្គលិកផ្នែកប្រតិបត្តិការ និងអត្រា ១០,០៨% ជាបៀវត្សបុគ្គលិកផ្នែករដ្ឋបាល និងអត្ថប្រយោជន៍ផ្សេងៗ) ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ដែលបានកត់ត្រាជាចំណាយថ្លៃដើមនៃសេវាកម្ម និងចំណាយរដ្ឋបាលទូទៅ។ ទោះជាយ៉ាងណា ក.ស.ភ. បានរៀបចំផែនការធនធានមនុស្សត្រឹមត្រូវតាមទំហំការងារ និងការរៀបចំប្រាក់បៀវត្ស យោងតាមបរិមាណកុងតឺន័រឆ្លងកាត់(ធីអ៊ីយូ) ដែលជួយឲ្យការចំណាយលើបុគ្គលិកមិនមានការប៉ះពាល់ខ្លាំងលើប្រាក់ចំណេញ។

#### ២.២. ចំណាយថ្លៃដងយោង

ចំណាយថ្លៃដើមនៃសេវាកម្មដ៏ធំមួយផ្នែកទៀតគឺចំណាយថ្លៃដងយោងដែលស្មើនឹង **៧,៧២%** បើធៀបទៅនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ ក.ស.ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាដៃគូអាជីវកម្មចំនួនបី ក្នុងការប្រើប្រាស់ដងយោង សម្រាប់សេវាកម្មលើកដាក់លើស្ពានផែ។ យោងតាមកិច្ចសន្យាភាគរយនៃការបែងចែកប្រាក់ចំណូលទៅកាន់ក្រុមហ៊ុនជាដៃគូនៅត្រឹម ៩០% និង៨០% បន្ទាប់ពីការធ្វើប្រតិបត្តិការបានរយៈពេល៣ ទៅ ៥ឆ្នាំ។ ក.ស.ភ. រំពឹងថាចំណាយថ្លៃដងយោងនឹងបន្តកើនឡើង ព្រោះកំណើនបរិមាណទំនិញឆ្លងកាត់ត្រូវបានព្យាករណ៍ថាបន្តឡើងខ្ពស់ក្នុងពេលខាងមុខ។ យ៉ាងណាមិញការចំណាយនេះ គឺប៉ះពាល់ដល់ផលចំណេញតិចតួចប៉ុណ្ណោះ ពីព្រោះការកើនឡើងនៃបរិមាណកុងតឺន័របានធ្វើឲ្យចំណូលរបស់ ក.ស.ភ. មានការកើនឡើងដូចគ្នា។ តារាងខាងក្រោមនេះបង្ហាញពីភាគរយនៃការបែងចែកប្រាក់ចំណូល៖

| ម្ចាស់ដងយោង | ឈ្មោះដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ដងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកិច្ចសន្យា |
|---|---|---|---|---|---|---|
| Sovereign | ដងយោងបណ្តែតទី១ | ១ | ៨០ | ៨០% | ២០% | ០១/០២/២០២១-៣១/០១/២០២២ |
| | ដងយោងបណ្តែតទី២ | ១ | ៦០ | ៨០% | ២០% | |
| Jeong Myeong International Co..Ltd | ដងយោងចល័តទី១ | ១ | ៤១ | ៩០% | ១០% | ០១/០១/២០១៣-៣១/១២/២០១៣ |
| | | | | ៨៥% | ១៥% | ០១/០១/២០១៤-៣១/១២/២០១៤ |
| | | | | ៨០% | ២០% | *០១/០១/២០១៥-៣១/១២/២០២៤* |
| Port Stevedoring Company Limited | ដងយោង FCC (៣គ្រឿង) | ៣ | ៤០ | ៩០% | ១០% | *០៧/០៩/២០២១- ០៧/០៩/២០២៤* |
| | | | | ៨៥% | ១៥% | *០៨/០៩/២០២៤- ០៨/០៩/២០២៥* |
| | | | | ៨០% | ២០% | *០៩/០៩/ ២០២៥-០៩/០៩/ ២០៤១* |

* *ក្រុមហ៊ុន* Sung kwang *បានប្តូរឈ្មោះទៅជាក្រុមហ៊ុន Jeong Myeong International Co., Ltd.។*

## ៣.*កាតព្វកិច្ចពន្ធផ្សេងៗ*

**ក.ស.ភ.** ស្ថិតក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មពាក់ព័ន្ធនឹងបញ្ហាពន្ធដារ។ ក.ស.ភ. ស្ថិតនៅក្រោមរបបស្វ័យប្រកាស និងចាត់ទុកជាអ្នកជាប់ពន្ធធំចំពោះការបង់ពន្ធ។ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធ និងអាករតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ៣.១. *ពន្ធលើប្រាក់ចំណេញ*

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% ដោយបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% នៃផលរបរប្រចាំខែ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែនឹងត្រូវទូទាត់កាត់កងជាមួយពន្ធលើប្រាក់ចំណេញ ២០% នៃចុងឆ្នាំសារពើពន្ធនីមួយៗ។ ក.ស.ភ. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមអនុក្រឹត្យលេខ០១អនក្រ.បកចុះថ្ងៃទី៨ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រសហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់សម្រាប់រយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។ ជាមួយគ្នានេះដែរ ចាប់ពីឆ្នាំ២០១៩ តទៅ ក.ស.ភ. ឈប់ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចនេះ ក.ស.ភ. នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។

### ៣.២. *អាករលើតម្លៃបន្ថែម*

ក.ស.ភ. ជាក្រុមហ៊ុនដែលចុះបញ្ជីអាករលើតម្លៃបន្ថែម។ ក.ស.ភ. បានគិតអាករលើតម្លៃបន្ថែមតាមអត្រា១០% នៃចំនួនទឹកប្រាក់លើវិក្កយបត្រពេលដែលចេញវិក្កយបត្រទៅអតិថិជន។ ក.ស.ភ

. ជាភ្នាក់ងារប្រមូលពន្ធនេះជូនរាជរដ្ឋាភិបាលព្រោះនេះជាអាករលើធាតុចេញរបស់ ក.ស.ភ.។ អាករលើធាតុចេញនេះនឹងត្រូវកាត់កងជាមួយអាករលើធាតុចូល១០%នៅពេលដែល ក.ស.ភ. បង់ប្រាក់ទៅអ្នកផ្គត់ផ្គង់សម្រាប់ការទិញ។

### ៣.៣. *ពន្ធកាត់ទុកលើចំណូលការប្រាក់*

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់តាមអត្រា ៤% លើបញ្ញើទូទៅនិង ៦% លើបញ្ញើមានកាលកំណត់។ បច្ចុប្បន្ន ក.ស.ភ. មានបញ្ញើមានកាលកំណត់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)។

### ៣.៤. *ពន្ធនាំចូល*

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធនាំចូលលើសម្ភារ និងវត្ថុធាតុដើមតាមអត្រាចន្លោះពី ៧% ទៅ ៣៥% អាស្រ័យលើប្រភេទទំនិញនីមួយៗដែលកំណត់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលបន្ទាប់ នៅចំណតផែកុងតឺន័រ LM១៧ នៅឆ្នាំ ២០២១ ក.ស.ភ. នឹងគ្រោងនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ ដូចនេះ ចំណាយលើពន្ធនាំចូលនឹងមានការកើនឡើង។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ ក.ស.ភ. រួមមានប្រាក់ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring) ការលើកដាក់នៅទីលាន (LOLO) និងចំណូលកិច្ចការផែដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកុងតឺន័រ ដែលស្មើប្រមាណ **៩២%** ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ក្នុងត្រីមាសទី៣ ឆ្នាំ២០២១។ កត្តាសំខាន់នៃការកើនឡើងប្រាក់ចំណូល គឺបានមកពីកំណើនចំនួនកុងតឺន័រ ទំនិញរាយ នាវាឆ្លងកាត់ និងចំណុះនាវា ស្របតាមការលូតលាស់ វិស័យសំណង់ វិស័យកសិកម្មវិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្មវាយនភណ្ឌ(សំលៀកបំពាក់និងស្បែកជើង)។ ជាមួយគ្នានេះដែរ ការដាក់ឱ្យដំណើរការនូវកំពង់ផែមេ គៃម៉េបប្រទេសវៀតណាម ក៏ជាប្រភពនៃកំណើនបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ.។ ជាក់ស្តែង ការដឹកជញ្ជូនឆ្លងកាត់ ក.ស.ភ. ទៅកាន់កំពង់ផែមេ គៃម៉េប មានការចំណេញពេលវេលាដោយដឹកជញ្ជូនទៅផ្ទាល់ទៅកាន់ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកប៉ែកខាងកើត និងសហរដ្ឋអាមេរិកប៉ែកខាងលិច។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណអត្រាការប្រាក់និងថ្លៃទំនិញ

### ១. *ផលប៉ះពាល់ពីអត្រាប្តូរប្រាក់*

ក.ស.ភ. បានកត់ត្រាបញ្ជីគណនេយ្យ ដោយប្រើប្រាស់រូបិយបណ្ណដុល្លារអាមេរិក ដោយសារចំណូលពីប្រតិបត្តិការអាជីវកម្ម និងសេវាកម្មភាគច្រើនជាប្រាក់ដុល្លារអាមេរិក និងការទូទាត់លើការងារជួសជុលគ្រឿងចក្រធំៗ ប្រេងឥន្ធនៈ និងចំណាយផ្សេងៗមួយចំនួនទៀត ក៏ជាប្រាក់ដុល្លារអាមេរិកដែរ

លើកលែងតែការចំណាយលើប្រាក់បៀវត្ស និងការបង់ពន្ធ។ហេតុដូចនេះផលប៉ះពាល់ពីអត្រាប្តូរប្រាក់សម្រាប់ ក.ស.ភ. គឺមានកម្រិតអប្បបរមា។

### ២. ផលប៉ះពាល់ពីអត្រាការប្រាក់

ក.ស.ភ. មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃទីផ្សារដោយសារភាពលំអៀងត្រូវបានបញ្ចូលក្នុងរបាយការណ៍លចំណេញ ឬខាតនោះទេហើយ ក.ស.ភ. ក៏ពុំមានឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវនាចុងការិយបរិច្ឆេទនេះដែរ។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយ-បរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ របស់ ក.ស.ភ.។

### ៣. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ប្រតិបត្តិការរបស់ ក.ស.ភ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រ ដែលមានតម្រូវការប្រើប្រាស់ប្រេងឥន្ធនៈខ្ពស់។ ការប្រែប្រួលតម្លៃប្រេងឥន្ធនៈ នឹងប៉ះពាល់ដល់ថ្លៃដើមសេវាកម្ម។ អាស្រ័យហេតុនេះ ក.ស.ភ. បានពង្រឹងការគ្រប់គ្រងលើចំណាយប្រតិបត្តិការតាមរយៈការបង្កើនប្រសិទ្ធភាពការងារលើកដាក់ការរៀបចំទីលានស្តុកកុងតឺន័រ ដែលអាចកាត់បន្ថយការលើកដាក់ និងការចល័តគ្រឿងចក្រច្រើនដែលមិនចាំបាច់។ ជាមួយគ្នានេះដែរ ក.ស.ភ. បានបំពាក់គ្រឿងចក្រទំនើបៗក្នុងការលើកដាក់ដែលប្រើប្រាស់ថាមពលអគ្គិសនីជំនួសវិញ។

## ខ- ផលប៉ះពាល់ពីអតិផរណា

កំណើននៃត្រាអតិផរណាអាចមានផលប៉ះពាល់ដល់ការចំណាយ និងការវិនិយោគរបស់ក្រុមហ៊ុនព្រោះតម្លៃទំនិញមានការកើនឡើង ហើយអំណាចទិញបានថយចុះ។ ប៉ុន្តែ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកកម្ពុជាមានអត្រាអតិផរណាជាមធ្យម ៣.១% ក្នុងឆ្នាំ២០២១ ដែលកម្រិតអតិផរណានេះ ពុំប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ ក.ស.ភ. នោះទេ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ក.ស.ភ. បាន និងកំពុងទទួលផលពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមាន ដូចខាងក្រោម៖

- គោលនយោបាយស្តីពីការជម្រុញការនាំចេញអង្ករបាននិងកំពុងផ្តល់ផលវិជ្ជមានដល់កំណើននៃការនាំចេញផលិតផលនេះតាមក.ស.ភ.
- គោលនយោបាយក្នុងការអនុគ្រោះពន្ធលើការនាំចូលឧបករណ៍/គ្រឿងចក្រកសិកម្មនាំឱ្យមានការវិនិយោគខ្លាំងលើវិស័យកសិកម្ម
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកការអនុគ្រោះពន្ធនិងកូតាពីប្រទេសជាដៃគូ បាននិងកំពុងជម្រុញឱ្យមានការនាំចេញខ្ពស់
- ការរៀបចំឱ្យមានតំបន់សេដ្ឋកិច្ចពិសេសនិងភណ្ឌាគារគយមានដែនកំណត់បាននិងកំពុងទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស

- គោលនយោបាយឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បាននិងកំពុងទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅប្រទេសកម្ពុជានិងការបង្កើតរោងចក្រធុនធ្ងន់ព្រមទាំងសហគ្រាសធុនតូចនិងមធ្យម
- គោលនយោបាយរបស់រាជរដ្ឋាភិបាលជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- ធនាគារជាតិនៃកម្ពុជា បាននិងកំពង់បន្តអនុវត្តគោលនយោបាយរូបិយវត្ថុតឹងរឹងនិងអត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង។គោលនយោបាយនេះបាននិងកំពុងរួមចំណែកក្នុងការបង្កើនទំនុកចិត្តសាធារណៈក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជានិងជម្រុញការធ្វើអាជីវកម្មពីវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជាបាននិងកំពុងជម្រុញឱ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋចូលទីផ្សារមូលបត្រកាន់តែច្រើនដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ផ្នែកទី ៥

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១ ក. ស. ភ. មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម៖

- បានសម្រេចអនុម័តរបាយការណ៍ស្ដីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេល ៦ខែ ដើមឆ្នាំ២០២១ របស់ ក. ស. ភ.
- បានសម្រេចឱ្យ ក. ស. ភ. ពិនិត្យ និងកែសម្រួលឡើងវិញនូវ កិច្ចព្រមព្រៀងស្ដីពីកិច្ចសហការវិនិយោគលើការអភិវឌ្ឍចំណតផែរណបពហុបំណង TS១១ រវាង ក. ស. ភ និងក្រុមហ៊ុន ភីធីអិលអេស ខូអបភើរេសិន (PTLS COOPERATION CO.,LTD) និងលើកសំណើសុំការពិនិត្យ និងសម្រេចឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើសំណើទៅក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីពិនិត្យ និងសម្រេចលើការកំណត់គោលការណ៍រួម សម្រាប់កិច្ចសហការវិនិយោគជាមួយឯកជនក្នុងការអភិវឌ្ឍចំណតផែរណបរបស់ ក. ស. ភ. នៅទន្លេបិទ, កោះរកា, ព្រែកអញ្ចាញ, ព្រែកក្ដាម, ខេត្តកំពង់ឆ្នាំង និងនៅឆ្លងខេត្តក្រចេះ ព្រមទាំងទីតាំងសមស្របផ្សេងៗទៀតនាពេលអនាគត
- បានពិនិត្យ និងសម្រេចលើសំណើសុំពន្យារពេលសងប្រាក់ត្រលប់មក ក. ស. ភ. របស់ ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប
- បានពិភាក្សា និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើសំណើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីកំណត់ឈ្មោះចំណតផែរណបរបស់ ក. ស. ភ. នៅកោះរកា ជា "ចំណតផែរណបពហុបំណងកោះរកា LM២៦" និងចំណតផែនៅក្អមសំណា ជា "ចំណតផែក្អមសំណា LM២៧"
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ផ្ទេរប៉ុងតុងចំនួន ១ គ្រឿង នៅចំណតផែបណ្ដែត TS១ យកទៅដាក់នៅចំណតផែកោះរកា ដើម្បីបម្រើឱ្យប្រតិបត្តិការលើកដាក់ទំនិញ។

# ហត្ថលេខារបស់អភិបាលកំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១
បានអាន និងឯកភាព

ហត្ថលេខា

**សួន រចនា**

សមាជិកក្រុមប្រឹក្សាភិបាលតំណាង
ក្រសួងសាធារណការ និងដឹកជញ្ជូន

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១
បានអាន និងឯកភាព

ហត្ថលេខា

**ឌិត សុចល**

សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិ

PHNOM PENH AUTONOMOUS PORT




## អាសយដ្ឋាន / Address

**ចំណតផែកុងតឺន័រ LM១៧ / Container Terminal LM17**

ភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល
Kandal Leu Village, Bantey Dek Commune,
Kien Svay District, Kandal Province.

**ចំណតផែពហុបំណង TS៣ / Container Terminal TS3**

#៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
#649, Street 1 (Preah Sisowath), Sras Chork Commune,
Daun Penh District, Phnom Penh City.

**ចំណតផែ អ្នកដំណើរ និងទេសចរ TS១ / Passenger and Tourist Terminal TS1**

តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Street 1 (Preah Sisowath), Wat Phnom Commune,
Daun Penh District, Phnom Penh City.

**ចំណតផែពហុបំណងកោះរកា / Multipurpose Terminal Koh Roka**

ភូមិកោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង
Koh Roka Village, Koh Roka Commune,
Peam Chor District, Prey Veng Province.

**ចំណតផែទន្លេបិទ UM២ / Tonle Bet Port UM2**

ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
Tonle Bet Village, Tonle Bet Commune,
Thbong Khmoum District, Thbong Khmoum Province.

**មជ្ឈមណ្ឌលពាណិជ្ជកម្មទ្រាយអ៊ឹម / Triumph Commercial Center**

ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Boeung Salang Village, Reusseykeo Commune
Reusseykeo District, Phnom Penh City.

## ទំនាក់ទំនង / Contact

Email : ppapmpwt@online.com.kh
Tel/Fax : +855 23 427 802
Website : www.ppap.com.kh